ភាពងាយរងគ្រោះដោយការជួញដូរមនុស្សនៅអាស៊ី

# ការសិក្សាស្រាវជ្រាវស្តីពី ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរវាង កម្ពុជា និង ចិន


Australian Aid
NORWEGIAN EMBASSY
RATANAK INTERNATIONAL
SWEDEN
UN-ACT
United Nations Action for Cooperation against Trafficking in Persons
UNDP
Empowered lives. Resilient nations.

© 2016 United Nations Action for Cooperation against Trafficking in Persons

UN-ACT. (2016). *Human Trafficking Vulnerabilities in Asia: A Study on Forced Marriage between Cambodia and China*. Bangkok: UNDP

UN-ACT publications can be obtained by contacting the UN-ACT Regional Management Office:

UN-ACT Regional Management Office
1st Floor, United Nations Service Building
Rajdamnern Nok Avenue
Bangkok 10200

Or download reports on our website at www.un-act.org

The views expressed in this publication are those of the author(s) and do not necessarily represent those of the United Nations, including UNDP, or the UN Member States.

ភាពងាយរងគ្រោះដោយការជួញដូរមនុស្សនៅអាស៊ី

# ការសិក្សាស្រាវជ្រាវស្តីពី ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរវាង កម្ពុជា និង ចិន

Australian Aid
NORWEGIAN EMBASSY
RATANAK INTERNATIONAL
SWEDEN
UN-ACT
United Nations Action for Cooperation against Trafficking in Persons
U N D P
Empowered lives.
Resilient nations.

# សេចក្តីថ្លែងអំណរគុណ

UN-ACT សូមថ្លែងអំណរគុណ និងកោតសរសើរដល់បុគ្គល និងអង្គការជាច្រើនដែលបានរួមចំណែកក្នុងការសិក្សាស្រាវជ្រាវ*ភាពងាយរងគ្រោះនៃការជួញដូរមនុស្សនៅអាស៊ីៈ ការសិក្សាស្រាវជ្រាវស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរវាងកម្ពុជា និងចិន។*

ការសិក្សាស្រាវជ្រាវ និងអនុសាសន៍កើតមានឡើងក៏ដោយសារកិច្ចសហការពីមន្ត្រីជំនាញក្នុងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលដៃគូ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា និងជាពិសេសស្ត្រីខ្មែរដែលបានផ្តល់កិច្ចសម្ភាសន៍ និងបានចែករំលែកបទពិសោធន៍របស់ខ្លួនដោយក្តីសោមនស្ស។

យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួងកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសសូមថ្លែងអរគុណដល់**លោកជំទាវ សាន្ត អរុណ** ប្រធានក្រុមការងារខមមីតកម្ពុជា និងជារដ្ឋលេខាធិការក្រសួងកិច្ចការនារី ដែលជានិច្ចជាកាលតែងតែគាំទ្រដល់កិច្ចការសិក្សាស្រាវជ្រាវស្តីពីការជួញដូរមនុស្សអស់រយៈពេលជាយូរឆ្នាំមកហើយ។

UN-ACT ក៏សូមថ្លែងអំណរគុណផងដែ ដល់ក្រសួងមហាផ្ទៃ ជាពិសេស**លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គស្នងការនគរ បាលជាតិជាពិសេសដល់ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដល់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងដល់ស្នងការរដ្ឋាននគរបាលខេត្តកំពង់ចាម។ លើសពីនេះទៀតសូមថ្លែងអំណរគុណដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងកិច្ចសហការ និងរួមចំណែកចែករំលែកព័ត៌មានសម្រាប់កិច្ចការស្រាវជ្រាវនេះ។

សូមថ្លែងអំណរគុណដល់អង្គការរតនៈអន្តរជាតិ ដែលបានផ្តល់ការគាំទ្រទាំងថវិកា និងបច្ចេកទេសដែលជាជំនួយមិនអាចកាត់ថ្លៃបាននៃការស្រាវជ្រាវ។

សូមថ្លែងការដឹងគុណដល់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ អង្គការអាហ្គាប៉េ បេសកកម្មអន្តរជាតិ អង្គការជំនួយផ្នែកច្បាប់សម្រាប់កុមារ និងស្ត្រី មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស អង្គការវីនរ៉ក់អន្តរជាតិ អង្គការចាប់ដៃ

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ក្នុងការចែករំលែកព័ត៌មាន និងសម្របសម្រួលក្នុងការស្វែងរកអ្នកតបសម្ភាសន៍។

យើងក៏ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកស្រី Annie George ទីប្រឹក្សាអន្តរជាតិ ក្នុងការវិភាគទិន្នន័យ និងចងក្រងរបាយការណ៍សិក្សាស្រាវជ្រាវ រួមទាំងការផ្តល់អនុសាសន៍សម្រាប់ក្រុមអ្នកធ្វើការងារពាក់ព័ន្ធសំខាន់ៗ។ យើងក៏ថ្លែងអំណរគុណជាអនេកដល់លោក ហ្វូត វិច្ឆិកា នៅប្រទេសកម្ពុជា និងលោកស្រី Jialing Han នៅប្រទេសចិន ក្នុងការរៀបចំសម្ភាស ក៏ដូចជាការរួមចំណែកក្នុងការវិភាគទិន្នន័យទាំងឡាយផងដែរ។

សូមថ្លែងអំណរគុណដល់អាហ្គាប៉េបេសកកម្មអន្តរជាតិ មជ្ឈមណ្ឌលសម្ព័ន្ធភាពពលកម្ម និងសិទ្ធិមនុស្ស ការិយាល័យសម្របសម្រួលទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងមជ្ឈមណ្ឌលប្រចាំក្រុងបាងកករបស់កម្មវិធីអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ ក្នុងការផ្តល់ព័ត៌មានត្រឡប់ និងអនុសាសន៍ល្អៗក្នុងសេចក្តីព្រាងរបាយការណ៍សិក្សាស្រាវជ្រាវនេះ។

UN-ACT ក៏សូមថ្លែងអំណរគុណដល់ក្រសួងការបរទេសណរវ៉េ និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត ដែលជាម្ចាស់ជំនួយ។ កិច្ចសិក្សាស្រាវជ្រាវនេះនឹងមិនអាចលេចរូបរាងបានឡើយ ប្រសិនបើគ្មានការជួយឧបត្ថម្ភគាំទ្រពីសំណាក់ម្ចាស់ជំនួយខាងលើទនោះ។

សកម្មភាពអង្គការសហប្រជាជាតិសម្រាប់កិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជួញដូរមនុស្ស (UN-ACT) ខែមិថុនា ឆ្នាំ២០១៦

## មាតិកា


# សេចក្តីថ្លែងអំណរគុណ ....................

# បញ្ជីពាក្យកាត់ .................... i

# សេចក្តីសង្ខេប .................... iii

# សេចក្តីផ្តើម .................... 1

ការធ្វើចំណាកស្រុកដើម្បីរៀបអាពាហ៍ពិពាហ៍ រវាងកម្ពុជា និងចិន .................... 1

ការជួញដូរមនុស្ស និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងច្បាប់អន្តរជាតិ .................... 4

អំពើជួញដូរមនុស្ស និងរបៀបវារៈនៃការអភិវឌ្ឍប្រកបដោយចីរភាពរហូតដល់ឆ្នាំ ២០៣០ .................... 7

ការជួញដូរមនុស្ស និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងក្របខណ្ឌជាតិ .................... 8

ក្របខណ្ឌគោលនយោបាយជាតិស្តីពីការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស .................... 10

គោលបំណងនៃកិច្ចការស្រាវជ្រាវ .................... 12

# វិធីសាស្ត្រ .................... 12

ទំហំសំណាក .................... 12

ឧបករណ៍សម្រាប់ស្រាវជ្រាវ និងការប្រមូលទិន្នន័យ .................... 15

ក្រមសីលធម៌ និងសុវត្ថិភាព .................... 16

ការវិភាគទិន្នន័យ .................... 17

ដែនកំណត់នៃការសិក្សាស្រាវជ្រាវ .................... 18

# របកគំហើញ៖ លក្ខណៈនៃសំណាក .................... 20

# របកគំហើញ៖ ដំណាក់កាលនៃការជ្រើសរើស .................... 22

មេខ្យល់ទីមួយ .................... 22

មេខ្យល់ទីពីរ និងមេខ្យល់ទីបី .................... 25

របកគំហើញ៖ ដំណាក់កាលចំណាកស្រុក ..................................... 27

រកគំហើញ៖ ដំណើរការនៃការរៀបអាពាហ៍ពិពាហ៍........................................ 28

ការផ្សំផ្គុំគូស្វាមីភរិយា........................................................................ 28

ការចុះសំបុត្រអាពាហ៍ពិពាហ៍ ................................................................ 31

រកគំហើញ៖ ការរត់គេចខ្លួន និងការវិលត្រឡប់មកវិញ.......... 35

ការរៀបចំផែនការរត់គេច និងការត្រឡប់មកវិញ ........................................ 35

បណ្តាញសង្គម និងទូរស័ព្ទចល័ត............................................................. 37

នគរបាល .......................................................................................... 39

ស្ថានកុងស៊ុល និងស្ថានឯកអគ្គរាជទូតកម្ពុជា ........................................... 41

ក្រុមអ្នកស្ម័គ្រចិត្ត និងអង្គការនានា ........................................................ 43

រកគំហើញ៖ ស្ថានភាពក្រោយការវិលត្រឡប់មកប្រទេសកម្ពុជាវិញ............................................ 44

ការត្រឡប់មកដល់ប្រទេសកម្ពុជាវិញ ....................................................... 44

ស្ថានភាពរបស់អ្នកតបសម្ភាសបន្ទាប់ពីការវិលត្រឡប់វិញរយៈពេលពីរឬបីខែដំបូង............................. 45

វិធានការប្រឆាំងនឹងមេខ្យល់ ................................................................. 46

ស្លាកស្នាមជិតជាប់អ្នកវិលត្រឡប់ពីប្រទេសចិនវិញ...................................... 47

សន្និដ្ឋាន .......................................................................... 48

# បញ្ជីពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍអាស៊ី |
| AIM | អាហ្គាប៉េ បេសកកម្មអន្តរជាតិ |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ |
| COMMIT | កិច្ចសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គ ប្រឆាំងការជួញដូរមនុស្ស |
| CWCC | មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ |
| GMS | មហាអនុតំបន់មេគង្គ |
| HCMC | ទីក្រុងហូជីមិញ |
| ID | អត្តសញ្ញាណប័ណ្ណ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IOM | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| Lao PDR | សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ |
| LICADHO | សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស |
| LSCW | អង្គការជំនួយផ្នែកច្បាប់សម្រាប់កុមារ និងស្ត្រី |
| MOFAIC | ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ |
| MOI | ក្រសួងមហាផ្ទៃ |
| MOSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា |
| NCCT | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| UN-ACT | សកម្មភាពអង្គការសហប្រជាជាតិសម្រាប់កិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជួញដូរមនុស្ស |
| UNIAP | កម្មវិធីអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ |
| UNTOC | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង |

# សេចក្ដីសង្ខេប

របាយការណ៍នេះពិនិត្យមើលលើលំនាំនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងបរិបទនៃការធ្វើចំណាកស្រុកទ្រង់ទ្រាយធំពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិន។ ស្ត្រីខ្មែរ៤២រូបឆ្លងកាត់ជីវិតរៀបការដោយបង្ខំនោះបានចែករំលែកបទពិសោធន៍របស់ខ្លួនតាមរយៈកិច្ចសម្ភាសន៍នៅប្រទេសទាំងពីរ។ មន្ត្រីបច្ចេកទេសរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារពាក់ព័ន្ធនៃប្រទេសកម្ពុជានិងចិន ក៏ត្រូវបានជួបសម្ភាស និងទទួលយកយោបល់ផងដែរ។

របាយការណ៍នេះមានគោលបំណងវិភាគពីទំនាក់ទំនងនៃការជ្រើសរើស ការអូសទាញ ការដឹកជញ្ជូន និងបែបផែននៃការកេងប្រវ័ញ្ច ស្វែងយល់ពីតម្រូវការសេវាដែលស្ត្រីខ្មែរត្រូវគេជួញដូរទៅប្រទេសចិនដើម្បីរៀបការដោយបង្ខំ ខណៈពួកគេកំពុងស្នាក់នៅ និងក្នុងដំណើរការការធ្វើមាតុភូមនិវត្តពីប្រទេសចិន និងសេវានានាដែលពួកគេត្រូវការក្នុងពេលវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក៏ដូចជាស្វែងយល់ពីឱកាសធ្វើអន្តរាគមន៍ដើម្បីបង្ការការរៀបការដោយបង្ខំ និងបង្កើនសេវាគាំពារទាំងនៅថ្នាក់គោលនយោបាយ និងថ្នាក់អនុវត្តកម្មវិធី។

ប្រទេសនៅក្នុងមហាអនុតំបន់មេគង្គទទួលស្គាល់ និងចាប់អារម្មណ៍កាន់ខ្លាំងឡើងលើការរៀបការដោយបង្ខំ។ កាលដើមឡើយ បាតុភាពនេះកើតមានឡើងចំពោះតែពីប្រទេស មីយ៉ាន់ម៉ា វៀតណាម និងចិនខ្លួនឯងតែប៉ុណ្ណោះ។ ប៉ុន្តែថ្មីៗនេះវាក៏កើតមានរាលដាលដល់ប្រទេសមួយចំនួនដែលស្ថិតនៅឆ្ងាយពីប្រទេសចិន ជាពិសេសប្រទេសកម្ពុជា។

ដោយសារកង្វះឱកាសការងារ និងអត្ថប្រយោជន៍ទាប រួមផ្សំនឹងកត្តាផ្សេងទៀត បានរុញច្រានយុវជនកម្ពុជាស្វែងរកជម្រើសឱកាសការងារនៅក្រៅពីមាតុប្រទេសរបស់ខ្លួន។ ស្ត្រីកម្ពុជាទទួលបានការអប់រំ និងការងារនៅមានកម្រិត ខណៈដែលពួកគេទទួលរងនូវអម្រែកយ៉ាងធ្ងន់ក្នុងការជួយរកចំណូល ទ្រទ្រង់ជីវភាពគ្រួសារ។ ដោយសារគោលនយោបាយទេសន្តរប្រវេសន៍រកការងារធ្វើមានភាពរឹតត្បិត ជាពិសេសអ្នកដែលពុំមានជំនាញនៅក្នុងតំបន់នោះ គេយល់ថាការធ្វើចំណាកស្រុកដើម្បី រៀបការក្នុងគោលបំណងកែលម្អជីវភាពគ្រួសារខ្លួននោះជាជម្រើសដ៏គាប់ប្រសើរមួយ។

ម្យ៉ាងវិញទៀតប្រទេសចិនជាប្រទេសមួយដែលរងវិបត្តិវិសមភាពភេទយ៉ាងខ្លាំងដោយសារគោលនយោបាយកូនតែមួយបានអនុវត្តជាង៣០ឆ្នាំហើយនោះ ហើយគ្រួសារចិននីមួយៗមានទំនោរចង់បានកូនប្រុសជាងកូនស្រី។ តាមទំនៀមទម្លាប់គ្រួសារចិនប្រាថ្នាយកកូនប្រុសដើម្បីស្នងត្រកូល និងមើលថែរក្សាម្ដាយឪពុកពេលចាស់ជរាជាមួយភរិយាដែលគេបានរៀបការចូលមកនៅក្នុងគ្រួសារនោះ។ ដោយវិបត្តិវិសមភាពភេទនេះហើយទើបធ្វើឱ្យបុរសចិនដែលរស់នៅក្នុងជីវភាពមិនសូវធូរធារនៅទីជនបទ ស្វែងរកប្រពន្ធពីប្រទេសក្រៅវិញ មានជាអាទិ៍ពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងប្រទេសវៀតណាមជាដើម។

ទាំងប្រទេសកម្ពុជា និងប្រទេសចិនបានហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ឆ្លងដែនតាមរយៈសេវាទីភ្នាក់ងារជ្រើសរើសគូស្រករ ដោយយល់ឃើញថាទីភ្នាក់ងារទាំងនោះធ្វើឡើងដោយពុំមានចុះបញ្ជី អនុញ្ញាត និងពុំមានការត្រួតពិនិត្យត្រឹមត្រូវឡើយ។

ភស្តុតាងមួយចំនួនដែលទទួលបានពីកិច្ចសម្ភាសន៍បញ្ជាក់ថាមានស្ត្រីខ្មែរមួយចំនួនកំពុងរស់នៅដោយក្ដីរីករាយ ទោះបីក្នុងជីវភាពជីវិតអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ។ ការសិក្សាស្រាវជ្រាវនេះសង្ខេបពីការពាក់ព័ន្ធដែលកើតឡើងពីភាពមិនប្រក្រតីតែប៉ុណ្ណោះ។

របាយការណ៍នេះបែងចែកជាដំណាក់កាលធំៗចំនួនប្រាំ តាមបទពិសោធន៍របស់អ្នកឆ្លើយតបសំណួរ ១)ការជ្រើសរើស ២)ការធ្វើចំណាកស្រុក ៣)ការរៀបការ ៤)ការរត់គេច និងត្រឡប់ និង៥)ស្ថានភាពក្រោយពីមកដល់ប្រទេសកម្ពុជាវិញ។ ការរកឃើញតាមដំណាក់កាលនីមួយៗមានដូចជា៖

## ១. ការជ្រើសរើស

- មេខ្យល់ទីមួយតែងតែជាអ្នកស្គាល់គ្នាជាមួយស្ត្រីដែលផ្ដល់សម្ភាស ឬស្គាល់សមាជិកក្នុងក្រុមគ្រួសាររបស់គេ មានដូចជា៖ អ្នកជិតខាង អ្នករួមការងារ ឬអតិថិជនក្នុងកន្លែងកាត់សក់ជាដើម។ មេខ្យល់មួយចំនួនប្រាប់ថាគេមានកូនស្រីរៀបការរស់នៅប្រទេសចិន និងថានាងតែងតែផ្ញើប្រាក់មកផ្ទះជាប្រចាំ។
- ចំណុចដែលទាក់អារម្មណ៍នោះគឺស្ត្រីទាំងនោះអាចផ្ញើប្រាក់មកផ្ទះដោយសារគេបានរៀបការជាមួយបុរសចិនដែលជាអ្នកមានម្នាក់ ឬក៏ធ្វើការសន្សំប្រាក់បានច្រើនជាងការធ្វើការ

ងារនៅប្រទេសកម្ពុជា ឬគេអាចរៀបការជាមួយអ្នកមានផង និងធ្វើការងារសន្សំប្រាក់បានច្រើនផង។ ក្នុងករណីខ្លះទៀត មេខ្យល់ប្រាប់ថាដើម្បីរកការងារល្អធ្វើបានទាល់តែរៀបការជាមួយនឹងបុរសចិន។

- មេខ្យល់មួយចំនួនបានឱ្យលុយទៅស្ត្រីទាំងនោះមុនពេលចេញដំណើរ ក្នុងការសម្ភាសនាងហៅវាថា "ប្រាក់បណ្ណាការ" ប្រាក់សម្រាប់ធ្វើដំណើរ ឬប្រាក់ខែបើកមុន។ ប្រាក់នោះមានចំនួនខុសៗគ្នា ចាប់ពី១០០$ ទៅដល់១០០០$។
- គ្រួសាររបស់គេនីមួយៗមានការយល់ឃើញផ្សេងៗគ្នាក្នុងការចាកចេញទៅប្រទេសចិនរបស់កូនស្រីខ្លួន។ មានគ្រួសារខ្លះលើកទឹកចិត្តយ៉ាងខ្លាំងដល់កូនស្រីឱ្យទៅប្រទេសចិន ប៉ុន្តែមានគ្រួសារមួយចំនួនប្រឆាំងដាច់ខាត រីឯគ្រួសារមួយចំនួនទៀតទុកឱ្យសម៉ីខ្លួនជាអ្នកសម្រេចចិត្តដោយខ្លួនឯង។
- មេខ្យល់ទីពីរ ឬមេខ្យល់ទីបីជាអ្នកចាត់ចែងធ្វើលិខិតឆ្លងដែន ទិដ្ឋាការ និងសំបុត្រយន្តហោះ។ គេតម្រូវឱ្យសម៉ីខ្លួនយករូបថត សៀវភៅគ្រួសារ និងសំបុត្រកំណើត។

## ២. ការធ្វើចំណាកស្រុក

- មានស្ត្រីជាច្រើននាក់ប្រាប់ឱ្យយើងដឹងថាមេខ្យល់បានជូនពួកនាងមកកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ពួកនាងត្រូវធ្វើដំណើរជាក្រុមដោយគ្មានភ្នាក់ងារណាទៅជាមួយឡើយ ហើយពេលមកដល់ប្រទេសចិន ទើបមានមេខ្យល់ចិនមកទទួល។ មានស្ត្រីមួយចំនួនតូចតែប៉ុណ្ណោះប្រាប់ថាមានមេខ្យល់មកជាមួយពួកនាងតាមយន្តហោះ។
- ជាធម្មតាគេធ្វើដំណើរពីភ្នំពេញទៅកាន់ក្រុងសៀងហៃ ឬខេត្តក្វាងចូវ ហើយបន្តដំណើរទៅកាន់ទីជនបទឆ្ងាយៗដទៃទៀត។
- មានស្ត្រីមួយចំនួននិយាយថាពួកនាងត្រូវគេនាំទៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។ ពួកនាងស្នាក់នៅទីនោះរយៈពេលពីរឬបីថ្ងៃសិន រង់ចាំទទួលបានទិដ្ឋាការទៅកាន់ប្រទេសចិន។ ពីទីក្រុងភ្នំពេញទៅក្រុងហូជីមិញ ពួកគេធ្វើដំណើរតាមផ្លូវគោក ហើយមានមេខ្យល់ទៅតាមជាមួយផង។

- នៅឯគោលដៅចុងក្រោយ ស្ត្រីទាំងនោះស្នាក់នៅផ្ទះមេខ្យល់ ឬស្នាក់នៅក្បែរៗផ្ទះមេខ្យល់រយៈពេលពីរបីថ្ងៃ ឬរហូតដល់ពីរបីសប្តាហ៍សិន។ ពួកនាងត្រូវគេណែនាំឱ្យបុរសចិនរហូតដល់មានគេជ្រើសរើសជាកូនក្រមុំ និងយល់ព្រមរៀបការ។

## ៣. ការរៀបអាពាហ៍ពិពាហ៍

- ស្ត្រីទាំងនោះត្រូវគេបោកបញ្ឆោត និងបង្ខិតបង្ខំឱ្យរៀបការក្នុងកម្រិតផ្សេងៗគ្នាៈ
  - ក) ស្ត្រីមួយចំនួនធ្វើដំណើរទៅប្រទេសចិនក្នុងគោលបំណងស្វែងរកការងារធ្វើ ប៉ុន្តែក្រោយមកទើបដឹងថានាងត្រូវតែរៀបការទៅវិញ។
  - ខ) ស្ត្រីមួយចំនួនគេប្រាប់ថាត្រូវរៀបការជាមុនសិនដើម្បីរកការងារ ឬការងារដែលមានប្រាក់ខែខ្ពស់ក្នុងប្រទេសចិន។ នេះគ្រាន់តែជាពាក្យបោកប្រាស់តែប៉ុណ្ណោះ ព្រោះថាបន្ទាប់ពីរៀបការរួចហើយនាងគ្មានឱកាសធ្វើការងារទេ លុះណាតែពួកគេរស់នៅជាជនបរទេសនៅក្នុងប្រទេសចិនស្របច្បាប់រយៈពេលយ៉ាងតិច ៥ ឆ្នាំសិន។ លើសពីនេះទៀតការរៀបការនេះគឺខុសគ្នាស្រឡះទៅនឹងអ្វី ដែលមេខ្យល់បានប្រាប់កាលពីដំបូង។

  ក្នុងករណីទាំងពីរខាងលើស្ត្រីទាំងនោះមិនមានសិទ្ធិក្នុងការប្រកែកឡើយ។
- កត្តាដែលស្ត្រីទាំងនោះបង្ខំចិត្តទទួលយកការរៀបការនោះគឺៈ
  - ក) លិខិតឆ្លងដែនរបស់ពួកគេស្ថិតនៅក្នុងដៃមេខ្យល់ ដូច្នេះពួកគេមិនអាចធ្វើដំណើរទៅកន្លែងណាមួយ ឬត្រឡប់មកផ្ទះឡើយ
  - ខ) មេខ្យល់មិនឱ្យម្ហូបអាហារ មិនឱ្យទាក់ទងជាមួយអ្នកដទៃ និងគម្រាមចាប់រំលោភ
  - គ) អ្នកឆ្លើយតបសំណួរមិនមានការជួយគាំទ្រពីបណ្តាញសង្គម មិនសូវយល់ដឹងពីរបៀបរបបរស់នៅក្នុងប្រទេសចិនឱ្យបានទូលំទូលាយ ដូចជាការមិនស្គាល់អង្គការដែលអាចទៅរកជំនួយបាន និងការមិនចេះនិយាយភាសា
  - ឃ) ស្ត្រីទាំងនោះមិនដឹងទាល់តែសោះថាខ្លួនចូលមកប្រទេសចិនតាមរយៈទិដ្ឋាការទេសចរណ៍ដោយមានសុពលភាពត្រឹមតែមួយខែតែប៉ុណ្ណោះ ហើយក្រោយមកពួកគេត្រឹមដឹងថាទាល់តែរៀបការទើបមានឱកាសរស់នៅក្នុងប្រទេសចិនបន្តទៀត។
  - ង) ជាទូទៅមេខ្យល់គម្រាមថានឹងរាយការណ៍ឱ្យនគរបាលចាប់ សំអាងថាស្ត្រីទាំងនោះ

ស្នាក់នៅប្រទេសចិនផុតកំណត់សុពលភាពនៃទិដ្ឋាការ ឬបើចង់ត្រឡប់មកកម្ពុជាវិញ គេត្រូវបង់ ប្រាក់សម្រាប់រាល់ចំណាយក្នុងការធ្វើដំណើរ មានចំនួនចាប់ពី ២០០០$ ទៅដល់ ៨០០០$។

- បុរសចិនបង់ប្រាក់ឱ្យមេខ្យល់ដើម្បីបានស្ត្រីខ្មែរទៅរៀបការជាមួយ មានតម្លៃពី១០០០០$ រហូតដល់២០០០០$។
- ស្ត្រីខ្មែរទាំងនោះប្រាប់ឱ្យដឹងផងដែរថាបន្ទាប់ពីនាង "យល់ព្រម" រៀបការជាមួយបុរសចិនណាម្នាក់ គេក៏នាំនាងទៅចុះសំបុត្រអាពាហ៍ពិពាហ៍ រួចបន្តទិដ្ឋាការរបស់នាងឱ្យស្នាក់នៅតទៅទៀត។ ក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍គេទាមទារឱ្យនាងយល់ព្រមដោយស្ម័គ្រចិត្តក្នុងការរៀបការជាមួយបុរសម្នាក់នោះចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ថ្វីត្បិតតែនៅចំពោះមុខអាជ្ញាធរក្តីនាងក៏មិនអាចសុំឱ្យគេជួយឡើយ។

## ៤. ការរត់គេច និងត្រឡប់មកវិញ

- ព័ត៌មាន និងលេខទូរស័ព្ទសម្រាប់ទាក់ទងគ្នាត្រូវគេប្រាប់តៗគ្នាពីម្នាក់ទៅម្នាក់ទៀតនៅឯទីផ្សារ ឬតាមរយៈទូរស័ព្ទដៃ ដែលជួយឱ្យស្ត្រីនោះអាចរៀបចំគម្រោងរត់គេចបាន។
- ពួកគេត្រូវធ្វើដំណើរដ៏វែងឆ្ងាយដើម្បីស្វែងរកជំនួយ។ ជួនកាលមន្ត្រីកុងស៊ុលកម្ពុជាមានការលំបាកក្នុងការជួយពួកគេ ដោយហេតុថាកន្លែងដែលគេរត់ចេញនោះមិនមែននៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដូច្នេះគេត្រូវបង្វែករណីនេះទៅកាន់កុងស៊ុលមួយផ្សេងទៀត ឬទៅកាន់ស្ថានឯកអគ្គរាជទូតតែម្តង។
- ពេលជួបនគរបាលនៅមូលដ្ឋាន ឬខេត្តដែលនាងកំពុងរត់គេចចេញនោះ ជាទូទៅពួកគេតែងតែបញ្ជូននាងឱ្យត្រឡប់ទៅកាន់ផ្ទះសម្បែងរបស់ប្តីនាងវិញ ហើយណែនាំឱ្យដោះស្រាយវិវាទក្នុងគ្រួសារ។ ចំណែកឯនគរបាលនៅតាមក្រុងធំៗឆ្ងាយពីកន្លែងដែលស្ត្រីរស់នៅ តែងតែអនុញ្ញាតឱ្យស្ត្រីទាំងនោះប្តឹង ហើយទាក់ទងទៅកាន់ស្ថានកុងស៊ុល ឬស្ថានឯកអគ្គរាជទូតដើម្បីជួយក្នុងដំណើរមាតុភូមិនិវត្តបន្តទៀត។
- ស្ថានកុងស៊ុល ឬស្ថានឯកអគ្គរាជទូតកម្ពុជាផ្តល់សេវាគាំទ្រ និងមាតុភូមិនិវត្តន៍ដល់ស្ត្រីដែលផ្តល់សម្ភាសក្នុងការសិក្សាស្រាវជ្រាវនេះ។ ប៉ុន្តែមានស្ត្រីមួយចំនួនមិនសប្បាយចិត្ត

ចំពោះការឃើតយ៉ាវ ការមិនគោរព និងមានការចោទប្រកាន់ថាមានការរំលោភបំពានផង ដែរ។

## ៥. ស្ថានភាពក្រោយមកដល់ប្រទេសកម្ពុជាវិញ

- ពេលមកដល់មាតុប្រទេសវិញ នគរបាលអន្តោប្រវេសន៍ និងនគរបាលប្រឆាំងការជួញដូរមនុស្សសម្ភាសយកព័ត៌មានពិស្តារអំពីមេខ្យល់។ ស្ត្រីដែលយើងបានសម្ភាសទទួលបានការជួយឧបត្ថម្ភជាប្រាក់ និងសម្ភារៈពីអង្គការសង្គមស៊ីវិល និងជួយឱ្យនាងវិលត្រឡប់ដល់គេហដ្ឋានវិញ។
- ជម្រើសការបណ្តុះបណ្តាលវិជ្ជាជីវៈក៏មានសម្រាប់ពួកគេ ប៉ុន្តែមានមួយចំនួនតែប៉ុណ្ណោះអាចបញ្ចប់កម្មវិធីបណ្តុះបណ្តាលនោះ។
- ស្ត្រីទាំងនោះពេលត្រឡប់មកវិញ ធ្វើការងារតាមរោងចក្រនៅទីក្រុងភ្នំពេញ ឬការងារណាដែលមិនត្រូវការជំនាញ។
- ស្ត្រីមួយចំនួន និងគ្រួសារនៅជំពាក់បំណុលគេ ខណៈខ្ចីប្រាក់ដើម្បីធ្វើដំណើរទៅ ឬត្រឡប់មកពីប្រទេសចិនវិញ។
- ស្ត្រីមួយចំនួនប្រាប់ថាខ្លួនបានដាក់ពាក្យប្តឹងមេខ្យល់ ផ្ទុយទៅវិញមានស្ត្រីមួយចំនួនទៀតថាខ្លួនមិនប្តឹងទេហើយគេក៏មិនចង់ពាក់ព័ន្ធនឹងផ្លូវច្បាប់ទេ។
- ស្ត្រីមួយចំនួនជិតដាមជាប់នូវបទពិសោធន៍មិនល្អ ពួកគេមានការភ័យខ្លាចចំពោះពាក្យពេបជ្រាយ ពេលដែលខ្លួនត្រឡប់មកពីប្រទេសចិន។
- មានស្ត្រីមួយចំនួនត្រឡប់មកវិញទាំងមានផ្ទៃពោះ នេះជាបន្ទុកមួយទៀតរបស់នាងដែលទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់ទារកនោះពេលកើតមក។

ផ្អែកតាមការវិភាគ និងរបកគំហើញ របាយការណ៍នេះបង្ហាញពីអនុសាសន៍មួយចំនួនជូនដល់អ្នកតាក់តែងគោលនយោបាយ អ្នកអនុវត្តកម្មវិធីសម្រាប់ពិចារណាក្នុងការបង្ការ កំណត់អត្តសញ្ញាណ និងកិច្ចគាំពារដំបូង ដោយរួមបញ្ចូលទាំងការធ្វើមាតុភូមិនិវត្តផងដែរ។ អនុសាសន៍មួយចំនួនផ្តោតលើប្រទេសទាំងពីរស្តីពីភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការទ្វេភាគី រីឯអនុសាសន៍មួយចំនួនទៀតផ្តោតជាក់លាក់លើប្រទេសចិនឬផ្តោតជាក់លាក់លើតែបរិបទកម្ពុជាប៉ុណ្ណោះ។

# សេចក្តីផ្តើម

ការជួញដូរមនុស្សជាការរំលោភសិទ្ធិដែលមានទម្រង់ធ្ងន់ធ្ងរបំផុត ដោយជនរងគ្រោះទទួលរងនិងស្ថិតនៅក្នុងស្ថានភាពកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរ តាមរយៈការបោកបញ្ឆោត ការគម្រាមកំហែង ឬការបង្ខិតបង្ខំ។ វាជាឧក្រិដ្ឋកម្មមួយដែលបង្កផលប៉ះពាល់ដល់មនុស្សរាប់លាននាក់នៅលើពិភពលោក ហើយក៏ជាឧក្រិដ្ឋកម្មមួយដែលរកប្រាក់ចំណូលបានជាង១៥០កោដ (ប៊ីលៀន) ដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ។[1]

មនុស្សត្រូវគេជួញដូរនៅក្នុងតំបន់ដោយទម្រង់ និងក្រោមឥទ្ធិពលផ្សេងៗពីគ្នា។ អំពើជួញដូរមនុស្សកើតមានឡើងយ៉ាងច្រើននៅក្នុងនិងរវាងប្រទេសទាំងប្រាំមួយក្នុងមហាអនុតំបន់មេគង្គ មានដូចជាកម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

ការរៀបការដោយបង្ខំទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងនៅក្នុងមហាអនុតំបន់មេគង្គ។ ដើមឡើយ ស្ត្រីពីប្រទេសមីយ៉ាន់ម៉ា និងប្រទេសវៀតណាមត្រូវគេបង្ខំឱ្យរៀបការជាមួយបុរសក្នុងប្រទេសចិន ស្ត្រីជនជាតិចិនត្រូវគេបង្ខំឱ្យរៀបការក្នុងប្រទេសចិនខ្លួនឯងផងដែរ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយ បាតុភាពនេះលេចកើតមានឡើងក្នុងប្រទេសដែលស្ថិតនៅឆ្ងាយពីព្រំដែនចិនជាពិសេសប្រទេសកម្ពុជា។[2]

## ការធ្វើចំណាកស្រុកដើម្បីរៀបអាពាហ៍ពិពាហ៍ រវាងកម្ពុជា និងចិន

ថ្វីត្បិតតែកំណើនសេដ្ឋកិច្ចបន្តកើនឡើងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះក្តី ក៏កម្ពុជានៅតែជាប្រទេសមួយដែលមានការរីកចំរើនដ៏តិចតួចបំផុតនៅអាស៊ីអគ្នេយ៍នៅឡើយ។ របាយការណ៍ធនាគារពិភពលោកដែលបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៤ បង្ហាញថាប្រជាជន

---

[1] របាយការណ៍ ILO: *ការប៉ាន់ប្រមាណលើការធ្វើពលកម្មដោយបង្ខំនៅលើពិភពលោក: លទ្ធផល និងវិធីសាស្ត្រ*(ILO 2012) និងការបោះពុម្ពផ្សាយរំលឹកឡើងវិញរបស់ILO *ប្រាក់ចំណូល និងភាពក្រីក្រ: សេដ្ឋកិច្ចដែលបានមកពីពលកម្មដោយបង្ខំ* (ILO 2014). របាយការណ៍នោះពុំបានបញ្ជាក់ថាពលកម្មដោយបង្ខំ មិនមែនការជួញដូរមនុស្សក៏ដោយចុះ ប៉ុន្តែការរងគ្រោះ និងខ្លឹមសារនៃរបាយការណ៍ជារឿយៗត្រូវប្រើប្រាស់ជាឯកសារយោងពាក់ព័ន្ធនឹងការជួញដូរមនុស្សផងដែរ។

[2] អានអត្ថបទរបស់Jina Moore, 'កម្ពុជាជាទីផ្សារកូនក្រមុំបរទេសដ៏ថ្មីស្រឡាងរបស់ចិនក្នុងព្រឹត្តិបត្រព័ត)មាន *BuzzFeed News*(ភ្នំពេញ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥) <http://www.buzzfeed.com/jinamoore/cambodia-is-chinas-newest-market-for-foreign-brides#.cf3O5VJ6d> accessed 2 October 2015.

ប្រមាណ២០%ទូទាំងប្រទេស បន្តរស់នៅក្នុងភាពក្រីក្រនៅឡើយ។[3] កង្វះខាតឱកាសការងារ និងប្រាក់ខែតិច រួមផ្សំជាមួយនឹងកត្តាផ្សេងទៀត ធ្វើឱ្យយុវជនកម្ពុជាមានជម្រើសតិច ហើយត្រូវស្វែងរកឱកាសការងារនៅក្រៅមាតុភូមិរបស់ខ្លួន។

ស្ត្រីកម្ពុជាទទួលបានការអប់រំ និងការងារដោយមានកម្រិត[4] ខណៈពួកគេទទួលរងនូវអម្រែកយ៉ាងធ្ងន់ក្នុងការរកចំណូលសម្រាប់ទ្រទ្រង់ជីវភាពគ្រួសាររបស់ខ្លួនផង។ ដោយសារគោលនយោបាយទេសន្តរប្រវេសន៍មានលក្ខណៈរឹតត្បិត ជាពិសេសអ្នកដែលពុំមានជំនាញនៅក្នុងតំបន់នោះ គេក្រឡេកមើលឃើញការធ្វើចំណាកស្រុកទៅរៀបការក្នុងគោលបំណងកែលម្អជីវភាពគ្រួសារខ្លួននោះជាជម្រើសដ៏គាប់ប្រសើរមួយ។

ប្រទេសចិនជាប្រទេសមួយដែលរងវិបត្តិវិសមភាពភេទយ៉ាងខ្លាំង ដោយសារគោលនយោបាយកូនតែមួយបានអនុវត្តជាង៣០ឆ្នាំ ហើយគ្រួសារចិននីមួយៗមានទំនោរចង់បានកូនប្រុសជាងកូនស្រី។ តាមទំនៀមទម្លាប់គ្រួសារចិនយកកូនប្រុសដើម្បីស្នងត្រកូល ក៏ដូចជាសម្រាប់មើលថែរក្សាម្ដាយឪពុកពេលចាស់ជរាជាមួយភរិយាដែលគេបានរៀបការចូលមកនៅក្នុងគ្រួសារនោះ។

វិទ្យាស្ថានសិក្សាវិទ្យាសាស្ត្រសង្គមមួយរបស់ចិនរកឃើញគម្លាតខុសគ្នារវាងភេទទាំងពីរថា មានបុរសរហូតដល់១២៤នាក់ខណៈស្ត្រីមានចំនួនត្រឹមតែ១០០នាក់តែប៉ុណ្ណោះ នេះគិតតែអត្រាមនុស្សដែលកើតរវាងឆ្នាំ២០០០ដល់ឆ្នាំ២០០៤។ នេះជាវិសមភាពយ៉ាងខ្ពស់បំផុតរវាងបុរសនិងស្ត្រីក្នុងពិភពលោក។ បុរសដល់វ័យរៀបការមានចំនួនច្រើនរហូតដល់៣០ទៅ

[3]ធនាគារពិភពលោក: *តើអ្នកក្រទៅឯណាហើយ?ការប៉ាន់ប្រមាណភាពក្រីក្រ ឆ្នាំ២០១៣*(ធនាគារពិភពលោក ២០១៤).

[4] ILO &ធនគារអភិវឌ្ឍអាស៊ី[ADB], សមភាពយ៉េនឌ័រ ក្នុងទីផ្សារការងារក្នុងប្រទេសកម្ពុជា(ADB 2013).

៩០លាននាក់នៅឆ្នាំ២០២៥[5] ដោយភាគច្រើនរស់នៅជនបទដាច់ស្រយាល ឬក្នុងតំបន់ក្រីក្រ។[6][7][8]

ក្នុងបរិយាកាសនេះជាពិសេសស្ថានភាពសេដ្ឋកិច្ចមិនអំណោយផលផងនោះ បុរសនៅជនបទត្រូវបង្ខំចិត្តស្វែងរកស្ត្រីមកពីប្រទេសផ្សេងមានដូចជា កម្ពុជា មីយ៉ានម៉ា ឬវៀតណាមជាដើមមកធ្វើជាប្រពន្ធ។ [9][10] ថ្វីត្បិតតែការរកប្រពន្ធពីបរទេសត្រូវចំណាយថ្លៃសម្រាប់ឱ្យមេខ្យល់

---

[5] ——, 'Gendercide: The Worldwide War on Baby Girls' *The Economist* (London, 4 មីនា 2010)<http://www. economist.com/node/15636231> accessed 4 October 2015.

[6] Lan Fang,កូនក្រមុំកម្ពុជារបស់ប្ដីចិន' *Worldcrunch*(Huanggang, 2 សីហា 2014) <http://www.worldcrunch.com/culture-society/the-cambodian-brides-of-china/immigration-cambodian-brides-matchmakers-weddings/c3s16538/> accessed2 October 2015.

[7]Chen Youhuaនិង Ulrich Mueller, '*ការពិបាករកប្រពន្ធរៀបការ និងទស្សនវិស័យក្នុងប្រទេសចិន (2002) 3 ការសិក្សាស្រាវជ្រាវលើពលរដ្ឋ,* 56.

[8] Jessica Levine, 'វណ្ណភាពថ្មីរបស់កម្លោះចាស់ចិន' *The Atlantic* (Washington D.C., 11 កុម្ភៈ 2013) <http://www.theatlantic.com/international/archive/2013/02/chinas-new-bachelor-class/273040/> accessed 5 October 2015.

[9]QuanbaoJiang, Ying Li និង Jesus Sanchez-Barricarte,'ការជួញដូរស្ត្រីពីប្រទេសជិតខាងចូលមកប្រទេសចិនដើម្បីរៀបការដោយសារវិសមភាពភេទ' (2011) <https://www.google.co.th/url?sa=t&rct=j&q=&esrc=s&source=web&cd=1&ved=0ahUKEwiSpsOFqPTLAhUJkY4KHSDiCHUQFggbMAA&url=http%3A%2F%2Fwww.mecon.nomadit.co.uk%2Fpub%2Fconference_epaper_download.php5%3FPaperID%3D8111%26&usg=AFQjCNFciwxC5FA2wb1_-h-o2aFHNUKZEA> accessed 7 October 2015

[10] ផ្អែកតាមមជ្ឈមណ្ឌលចុះបញ្ជីអាពាហ៍ពិពាហ៍ជាមួយជនបរទេសខេត្តជាងស៊ី កូនក្រមុំទាំងអស់ដែលបានមកចុះឈ្មោះនៅខេត្តជាងស៊ីមកពីប្រទេសវៀតណាម ផ្ទុយទៅវិញរដ្ឋាភិបាលវៀតណាមបានដាក់ចេញនូវនីតិវិធីគ្រប់គ្រង និងអនុញ្ញាតអាពាហ៍ពិពាហ៍ជាមួយជនបរទេសយ៉ាងតឹងរ៉ឹង។ ហើយក៏បង្កើតឱ្យមានយុទ្ធនាការប្រឆាំងនឹងការរៀបការដោយបង្ខំ បន្ទាប់ពីមានការលេចឡើងនូវ 'ការរៀបការក្លែងក្លាយ'កើតឡើងចំពោះស្ត្រីវៀតណាមជាច្រើននាក់មក (——, មនុស្សចំនួន១១នាក់ត្រូវបានឃុំខ្លួនពាក់ព័ន្ធនឹងការរៀបការក្លែងក្លាយនៅភាគខាងកើតនៃប្រទេសចិន' *China Daily USA* (Nanchang, 27 មីនា 2015)<http://usa.chinadaily.com.cn/china/2015-03/27/content_19933370.htm> accessed 10 October 2015; Jamil Anderlini, 'Chinese mystery of vanishing foreign brides' *Financial Times* (Beijing, 12 December 2014) <http://www.ft.com/cms/s/0/7d7242cc-81e9-11e4-b9d0-00144feabdc0.html#axzz3oKPrxnOP> accessed 18 October 2015).

ចំណាយសម្រាប់ការចាត់ចែងរៀបការក្ដី ក៏នៅតែអស់តិចជាងការរៀបការជាមួយស្ត្រីចិនដែរ។[11]ស្ត្រីទាំងនោះជាច្រើនមកពីប្រទេសកម្ពុជា។[12]

ទោះបីជាវិសាលភាពនៃគំរូជាក់លាក់ក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំតាមរយៈការធ្វើចំណាកស្រុករវាងប្រទេសទាំងពីរពុំទាន់ដឹងច្បាស់យ៉ាងណាក្ដី ក៏យើងសង្កេតឃើញថាមានការកើនឡើងជាលំដាប់ក្នុងបណ្ដាខេត្តមួយចំនួនក្នុងប្រទេសចិន មានជាអាទ៍ខេត្តជាំងស៊ីនិងខេត្តហ្វូជៀនដែលជាទីកន្លែងដែលអ្នកសិក្សាស្រាវជ្រាវបានចុះទៅសម្ភាស។ ក្នុងឆ្នាំ២០១៣ រដ្ឋាភិបាលកម្ពុជាបានរាយការណ៍ថាខ្លួនបានជួយសង្គ្រោះនិងធ្វើមាតុភូមិនិវត្តស្ត្រីពីប្រទេសចិន២១នាក់ ចំនួនជួយសង្គ្រោះបានកើនឡើងរហូតដល់៥៨នាក់ក្នុងឆ្នាំ២០១៤ [13] ហើយបន្តកើនឡើងដល់ទៅ១៥០នាក់ក្នុងឆ្នាំ២០១៥។[14]

## ការជួញដូរមនុស្ស និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងច្បាប់អន្តរជាតិ

ការជួញដូរមនុស្សត្រូវគេកំណត់និយមន័យជាអន្តរជាតិនៅក្នុងពិធីសារប៉ាឡឺម៉ូស្ដីពីការបង្ការ ផ្ដន្ទាទោស និងដាក់ទណ្ឌកម្មការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ (ហៅដោយខ្លីថាពិធីសារប៉ាឡឺម៉ូ) ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដោយមានអង្គការចាត់តាំង (UNTOC)។ ពិធីសារប៉ាឡឺម៉ូត្រូវបានគេ

[11] បុរសដែលរកប្រពន្ធដែលមានតម្លៃខ្ពស់ក្លាយជាទម្លាប់ធម្មតា។ ឧទាហរណ៍——, 'តម្លៃនៃការរៀបការក្នុងប្រទេសចិន: បង្ហាញទិន្នន័យមួយគួរឱ្យភ្ញាក់ផ្អើល' *eChinacities.com* (Beijing, 11 មិថុនា 2013) <http://www.echinacities.com/china-media/The-Price-of-Marriage-in-China-Infographic-Shows-Astounding-Data> accessed 10 October 2015; or Luo Wen, 'Caili a Huge Burden for Grooms in China'*CRIENGLISH.com* (Beijing, 25 កុម្ភៈ 2016) <http://english.cri.cn/12394/2016/02/25/4203s917917.htm> accessed 26 February 2016.

[12] Mark O'Neill, 'ចិនរៀបការជាមួយកូនក្រមុំកម្ពុជាតែមួយចំនួនមិនបានរស់នៅជាមួយគ្នាដោយក្ដីសុខសាន្តឡើយ' *ejinsight* (Nanchang, 23 កក្កដា 2014) <http://www.ejinsight.com/20140723-cambodian-brides/?> accessed 2 October 2015.

[13] ក្នុងឆ្នាំដដែលនោះ អង្គការក្នុងស្រុកនៅកម្ពុជារាយការណ៍ថាខ្លួនបានទទួលការស្នើសុំឱ្យជួយស្ត្រីពីប្រទេសចិនចំនួនជាង ១៥០(Jina Moore (n 2)).

[14]Alice Cuddy and Neil Loughlin, 'អាពាហ៍ពិពាហ៍ពិឋាននរក: កូនក្រមុំកម្ពុជាត្រូវបានជួញដូរទៅប្រទេសចិន *The Guardian* (Phnom Penh, 1 February 2016) <http://www.theguardian.com/global-development/2016/feb/01/weddings-from-hell-cambodian-brides-trafficked-china> accessed 1 February 2016.

ផ្តល់សច្ចាប័នក្នុងឆ្នាំ២០០០ និងចូលជាធរមានក្នុងឆ្នាំ២០០៣ ដោយកំណត់និយមន័យនៃអំពើជួញដូរមនុស្សដូចតទៅ៖

"ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងឱ្យសំចត និងការទទួលមនុស្ស" (អំពើ)

"ដោយមធ្យោបាយគម្រាមកំហែង ឬការប្រើប្រាស់កម្លាំង ឬរាល់ទម្រង់នៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការបន្លំ ការបោកបញ្ឆោត ការរំលោភអំណាច ការដាក់ឱ្យធ្លាក់ចូលក្នុងភាពងាយរងគ្រោះ ឬការផ្តល់ឬទទួលប្រាក់ ឬអត្ថប្រយោជន៍ផ្សេងៗ ដើម្បីទទួលបានការយល់ព្រមពីបុគ្គលម្នាក់ដើម្បីត្រួតត្រាលើបុគ្គលនោះ (មធ្យោបាយ)

"ក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ច [ដោយរាប់បញ្ចូលទាំង] គឺការកេងប្រវញ្ចពេស្យាលើបុគ្គលដទៃឬទម្រង់នានានៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មដោយបង្ខំ ឬសេវាកម្មដោយបង្ខំ ទាសភាព ឬទម្រង់ប្រហាក់ប្រហែលនឹងទាសភាព អ្នកបម្រើដាច់ថ្លៃ ឬ ដើម្បី យកហូតសរីរាង្គ។" (គោលបំណង)[15]

គេសង្កេតឃើញថាការរៀបការដោយបង្ខំពុំមានលើកឡើងនៅក្នុងនិយមន័យនេះនិងក្នុងច្បាប់អន្តរជាតិនានាឡើយ។ ដោយឡែកប្រភពមួយចំនួនលើកឡើងពីការរៀបការ និងសារៈសំខាន់នៃការយល់ព្រមតាមគោលការណ៍ស្មគ្រចិត្ត [16] តែពុំមានការពន្យល់អំពីអ្វីដែលនាំឱ្យ

[15] ពិធីសារអង្គការសហប្រជាជាតិស្តីពីការបង្ការទបស់ការបង្ការ ផ្តន្ទាទោស និងដាក់ទណ្ឌកម្មការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ (ហៅដោយខ្លីថាពិធីសារប៉ាឡឺម៉ូ) ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដោយមានអង្គការចាត់តាំង (UNTOC) (ត្រូវបានអនុម័តថ្ងៃទី១៥ ខែវិច្ឆិការ ឆ្នាំ២០០០ ហើយចូលជាធរមាននៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៣ ត្រង់មាត្រា ៣ (ក))។

[16]នេះរួមបញ្ចូលទាំងសេចក្តីថ្លែងការណ៍សាកលស្តីពីសិទ្ធិមនុស្សបញ្ជាក់ថា "ការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើទៅបានដរាបណាមានការយល់ព្រមព្រៀងដោយមិនបង្ខំរវាងភាគីស្វាមីភរិយាទាំងពីរ" (សេចក្តីថ្លែងការសាកលស្តីពីសិទ្ធិមនុស្ស(អនុម័ត 10 ធ្នូ 1948 UNGA Re 217 A(III)) មាត្រ 2);អនុសាសន៍ទូទៅ លេខ 21 ក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងស្ត្រីថ្លែងថា "សិទ្ធិរបស់ស្ត្រីក្នុងការជ្រើសរើសដៃគូរបស់ខ្លួនដោយសេរីដើម្បីរៀបការសំខាន់ណាស់ក្នុងជីវិតរស់នៅសេក្តីថ្លៃថ្នូរ និងភាពស្មើគ្នាជាមនុស្ស" (គណកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងស្ត្រី(នីតិកាលទី13) "អនុសាសន៍ទូទៅ លេខ 21" (1994));ឬ មាត្រា១ នៃអនុសញ្ញាស្តីពីការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ អាយុអប្បបរមា និងការចុះសំបុត្រអាពាហ៍ពិពាហ៍ បានបញ្ជាក់ថា "រាល់ការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ត្រូវធ្វើឡើងក្រោមបរិយាកាសព្រមព្រៀងដោយសេរីដោយភាគីទាំងសងខាង ការយល់ព្រមត្រូវធ្វើឡើងដោយសម៉ីខ្លួនផ្ទាល់ជាសាធារណៈក្រោមវត្តមានអាជ្ញាធរមានសមត្ថកិច្ចជាសាក្សីកំណត់ដោយច្បាប់" (អនុសញ្ញាស្តីពីការយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍ អាយុអប្បបរមាសម្រាប់ការរៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអាពាហ៍ពិពាហ៍ (អនុម័តកាលពីថ្ងៃទី 7 ខែវិច្ឆិកា 1962, ចូលជាធរមាននៅថ្ងៃទី 9 ខែធ្នូ 1964) មាត្រា 1).

មានការរៀបការដោយបង្ខំឡើយ។[17]

ការពិភាក្សាពីការរៀបការដោយបង្ខំ និងការពាក់ព័ន្ធរបស់វាក្នុងការជួញដូរមនុស្សនៅតែបន្ត ។ ការពិភាក្សាដែលផ្តោតលើការជួញដូរមនុស្ស ផ្តោតការយកចិត្តទុកដាក់យ៉ាងទូលំទូលាយលើវិសាលភាពនៃការកេងប្រវ័ញ្ចក្នុងការរៀបការនោះ។ មានទស្សនៈមួយចំនួនលើកឡើងថា ឱ្យតែមានការកេងប្រវ័ញ្ចដែលមានចែងក្នុងពិធីសារប៉ាឡឺម៉ូ ជាពិសេសសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម វាសុទ្ធតែជាអំពើជួញដូរមនុស្សទាំងអស់ ទោះបីជាការរៀបការនោះកើតឡើងដោយរបៀបណាទេ ។

អំណះអំណាងមួយចំនួនទៀតផ្អែកលើអនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់ទាសភាព ការជួញដូរទាសភាព និងការអនុវត្តប្រហាក់ប្រហែលនឹងទាសភាព លើកឡើងថាការរៀបការដោយបង្ខិតបង្ខំគឺជា 'ការអនុវត្តប្រហាក់ប្រហែលនឹងទាសភាព'[18], ដែលពិធីសារប៉ាឡឺម៉ូកំណត់ថាជាទម្រង់នៃការកេងប្រវ័ញ្ច។ គេក៏លើកឡើងផងដែរថាអ្នកដែលធ្វើសេចក្តី

---

[17] ខុសគ្នារវាងបរិបទជាតិមួយ មានប្រទេសមួយចំនួនបានបង្កើតច្បាប់ដែលឱ្យនិយមន័យ និងផ្តន្ទាទោសចំពោះការបង្ខំនរណាម្នាក់ឱ្យរៀបអាពាហ៍ពិពាហ៍។ ឧទាហរណ៍ប្រទេសអង់គ្លេស "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានន័យថា ការរៀបអាពាហ៍ពិពាហ៍មួយដែលធ្វើឡើងដោយពុំមានការយល់ព្រមពីភាគីទាំងសងខាង ដោយមានការបង្ខិតបង្ខំ[បញ្ជាក់ដោយសាលាឧទ្ធរ]ថាការធ្វើតេស្តដើម្បីរក 'ការបង្ខិតបង្ខំ' ថាតើ 'ក្នុងចិត្ត [ជនរងគ្រោះ] ទទួលរងការសង្កត់សង្កិន ជាមូលហេតុ'។ (...) ការបង្ខិតបង្ខំរួមមានទាំងលើផ្លូវកាយ ផ្លូវចិត្ត ផ្នែកហិរញ្ញវត្ថុ និងការដាក់សម្ពាធលើផ្លូវភេទ និងស្មារតីផងដែរ" (Nicola Sharp, *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងប្រទេសអង់គ្លេស: ការសិក្សាស្រាវជ្រាវមួយស្តីពីបទពិសោធន៍របស់ស្ត្រីក្នុងសហគមន៍មជ្ឈឹមបូព៌ា និងស្ត្រីអាព្រិចប៉ែកឦសាន* (Refuge2008) <http://www.refuge.org.uk/files/1001-Forced-Marriage-Middle-East-North-East-Africa.pdf> accessed 4 October 2015).

[18] ក្នុងអនុសញ្ញា 'ទីកន្លែង និងការអនុវត្តប្រហាក់ប្រហែលនឹងទាសភាព' រួមបញ្ចូលទាំង "ស្ត្រី គ្មានសិទ្ធិបដិសេធន៍ ដោយយល់ព្រមរៀបការជាថ្នូរនឹងប្រាក់ ឬជាសារគុណដល់ម្តាយឪពុក អាណាព្យាបាល គ្រួសារ ឬនរណាម្នាក់ ឬក្រុមណាមួយ"(អនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាំអំពើទាសភាព ការធ្វើពាណិជ្ជកម្មទាសករ និងទីកន្លែង និងការអនុវត្តប្រហាក់ប្រហែលនឹងទាសភាព(ផ្តល់សច្ចាប័នកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៥៦ និងចូលជាធរមានថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៥៧) មាត្រា១(c)).

ព្រាងអនុសញ្ញាបំពេញបន្ថែមមានការយល់ឃើញផ្សេងៗគ្នាអំពីការរៀបការដោយបង្ខំ។ ដូចនេះ ការបកស្រាយគួរធ្វើឡើងអំពីបាតុភូតដែលកើតមានឡើង។[19] [20]

ការរៀបការមួយដែលកើតមានឡើងដោយគ្មានការយល់ព្រមពីភាគីម្ខាងទៀតក្នុងចំណោមភាគីទាំងពីរនោះ ត្រូវចាត់ទុកថាជាទម្រង់នៃការជួញដូរមនុស្ស។ ចំណុចនេះក៏ស្របគ្នាទៅនឹងការបកស្រាយរបស់រដ្ឋាភិបាលចិនស្តីពីការរៀបការដោយបង្ខំផងដែរគឺនៅក្នុងកិច្ចខិតខំប្រឹងប្រែងនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ អាជ្ញាធរចិនពិនិត្យមើលថាតើមានសមាសភាពនៃការបោកបញ្ឆោត ឬការបង្ខិតបង្ខំដែរឬទេ ចូលក្នុងចំណងអាពាហ៍ពិពាហ៍ ហើយការពិនិត្យរកធាតុផ្សំនេះហាក់បីដូចជាការអនុវត្តនៅក្នុងបរិបទប្រទេសកម្ពុជាផងដែរ។

## អំពើជួញដូរមនុស្ស និងរបៀបវារៈនៃការអភិវឌ្ឍប្រកបដោយចីរភាពរហូតដល់ឆ្នាំ ២០៣០

របៀបវារៈនៃការអភិវឌ្ឍប្រកបដោយចីរភាពរហូតដល់ឆ្នាំ២០៣០ ដែលជាទូទៅគេហៅថាគោលដៅអភិវឌ្ឍន៍ប្រកបចីរភាព (SDGs) ទទួលស្គាល់ថា ការជួញដូរមនុស្ស និងទម្រង់នៃការកេងប្រវ័ញ្ចជាស្នូលក្នុងការពិចារណាសម្រាប់ការអភិវឌ្ឍ ដោយបានលើកឡើងនៅក្នុងគោលដៅបីក្នុងចំណោមគោលដៅទាំង១៦នៃគោលដៅអភិវឌ្ឍន៍សហាសវត្សប្រកបដោយចីរភាពមានដូចជា គោលដៅទី៥ ស្តីអំពីសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីគ្រប់រូប គោលដៅទី៨ ស្តីពីកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ដែលមានការងារ

---

[19]MacLean ជំទាស់ថា“(...) ដោយផ្តោតលើតែអ្វីដែលកើតឡើងក្នុងការរៀបការដោយបង្ខំប៉ុណ្ណោះដោយមិនលើកយកពីដើមចមនៃអំពីការកេងប្រវ័ញ្ចៈ ក្នុងអំពើនេះឡើយ។ បុគ្គលណា មិនថាជាមេខ្យល់ ប្តី ឬអន្តរការី បានបោកបញ្ឆោត ឬជម្រុញឱ្យបុគ្គលម្នាក់ទៀតធ្លាក់ចូលទៅក្នុងកិច្ចសន្យារៀបការផ្ទុយពីឆន្ទៈ ព្រោះការរៀបការរបស់នាងនឹងផ្តល់ប្រយោជន៍មកដល់ខ្លួន (...). ទោះបីជាការរៀបអាពាហ៍ពិពាហ៍នោះធ្វើឡើងក្នុងរូបភាពណាក្តី មិនថានាងត្រូវបានគេយកចិត្តទុកដាក់ជាលក្ខណៈពិសេសយ៉ាងណាក្តី (លួងលោមនាងមិនឱ្យផ្អាកការៀបការ) ឬអ្នកបំរើដាច់ថ្លៃក្នុងផ្ទះ ឬកេងប្រវ័ញ្ចផ្លូវភេទក្តី ក៏សកម្មភាពកេងប្រវ័ញ្ចកើតមានចំពោះការរៀបការដោយបង្ខំជាដរាប” (“អាជីវកម្មជួញដូរមនុស្សសម្រាប់រៀបការ៖ ការលាតត្រដាងពីទម្រង់ថ្មីដែលកើតមានឡើងក្នុងការជួញដូរមនុស្សឆ្លងដែន និងក្របខណ្ឌនៃការឆ្លើយតបរបស់ច្បាប់អន្តរជាតិ” និពន្ធដោយDouglas MacLean (2012) កំណត់ត្រារបស់ UC Davis អំពីច្បាប់ និងគោលនយោបាយអន្តរជាតិ 68, 85).

[20]លើសពីនេះ ថ្វីត្បិតការបកស្រាយតាមបែបអភិរក្សនិយម ទាមទារឱ្យមានភស្តុតាងដោយឡែកដែលបញ្ជាក់ពីការកេងប្រវ័ញ្ចកើតមានឡើងចំពោះការរៀបការដោយបង្ខំនោះក៏ដោយចុះ យើងឃើញច្បាស់ក្រឡែតថាបរិយាកាសនៃការរៀបការដោយបង្ខំស្ទើរតែទាំងអស់ប្រាកដជាមិនចុះសម្រុងក្នុងការរួមភេទឡើយគឺថាវាជាការកេងប្រវ័ញ្ចផ្លូវភេទទៅវិញទេ។

ប្រកបដោយផលិតភាពពេញលេញ និងសមរម្យសម្រាប់ទាំងអស់គ្នា និង គោលដៅទី១៦ ស្តីអំពីសង្គមមួយមានសន្តិភាព ការអភិវឌ្ឍប្រកបដោយនិរន្តរភាព មានយុត្តិធម៌ដល់ពលរដ្ឋគ្រប់រូប និងមានគណនេយ្យភាពនៅស្ថាប័នគ្រប់ជាន់ថ្នាក់។[21] រដ្ឋដែលប្តេជ្ញាលុបបំបាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ទាំងអស់ដោយផ្តោតសំខាន់ចំពោះស្ត្រី និងក្មេងស្រី(ក្នុង SDG 5) កម្មករ (ក្នុង SDG 8) និងកុមារ (ក្នុង SDG 16)។

ក្នុងបរិបថនៃការសិក្សាស្រាវជ្រាវ និងភាពជាប់ទាក់ទងគ្នារវាងការជួញដូរមនុស្ស ការធ្វើចំណាកស្រុកសម្រាប់កេងប្រវ័ញ្ចន៍កម្លាំងពលកម្ម កំណត់ក្នុងគោលដៅទី៧ ក្រោម SDG ទី១០[22] ស្តីពី "ការធ្វើចំណាកស្រុក និងការផ្លាស់ទីប្រកបដោយមានសណ្តាប់ធ្នាប់ សុវត្ថិភាព ភាពទៀងទាត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ តាមរយៈការអនុវត្តគោលនយោបាយទេសន្តប្រវេសន៍ដែលមានផែនការជាក់លាក់ និងគ្រប់គ្រងបានល្អ" និងគោលដៅទី៨ ក្រោម SDG ទី៨ ស្តីពីកិច្ចគាំពារ និងលើកកម្ពស់ "សិទ្ធិពលករ និង(...)បរិយាកាសការងារប្រកបដោយសុវត្ថិភាព និងសន្តិសុខដល់ពលករទាំងអស់គ្នា ជាពិសេសស្ត្រីពលករចំណាកស្រុក និងជាពិសេសពលករដែលមានការងារប្រកបដោយគ្រោះថ្នាក់" មានភាពពាក់ព័ន្ធស្មើគ្នាក្នុងគម្រោងនេះ។

## ការជួញដូរមនុស្ស និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងក្របខណ្ឌជាតិ

ចិនបានកំណត់និយមន័យនៃអំពើជួញដូរមនុស្សក្នុងច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន (មាត្រា ២១០)។ អំពើនេះកំណត់ចំពោះតែស្ត្រី និងកុមារតែប៉ុណ្ណោះ ប៉ុន្តែវាគ្របដណ្តប់លើគោលបំណងនានា រួមបញ្ចូលទាំងការរៀបការដោយបង្ខំ ការសុំកូនចិញ្ចឹមដោយខុសច្បាប់ និងការកេងប្រវ័ញ្ចផ្លូវភេទជាដើម។ បុរសមិនត្រូវបានគេចាត់ជាជនរងគ្រោះដោយអំពើជួញដូរដូចស្ត្រី

[21] ការផ្លាស់ប្តូររបស់ភពផែនដីយើង: របៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងឆ្នាំ២០៣០(អនុម័តថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៦)។

[22] SDG 10 ទាមទារឱ្យពិភពលោក "កាត់បន្ថយវិសមភាពក្នុងប្រទេស និងក្នុងចំណោមប្រទេស លើវិសមភាពដែលខ្លួនបានកាត់បន្ថយរួចហើយ" (ibid).

និងកុមារនោះឡើយ ក៏ប៉ុន្តែបុរសត្រូវបានកំណត់ជាជនរងគ្រោះនៃពលកម្មដោយបង្ខំដូចដែលមានចែងក្នុងបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌ (មាត្រា២៤៤)។

បន្ទាប់ពីការការកំណត់ករណីណាមួយជាករណីជួញដូរមនុស្សរួច អ្នកដែលទទួលរងអំពើទាំងនោះ ត្រូវបានចាត់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយស្វ័យប្រវត្តិ។ និយមន័យនៃបទល្មើសនៃការជួញដូរមនុស្ស និងជនរងគ្រោះដោយសារការជួញដូរមនុស្ស គឺផ្តោតសំខាន់ទៅលើធាតុផ្សំអំពើនិងមធ្យោបាយដែលមានចែងក្នុងពិធីសារប៉ាឡឺម៉ូ។ ក្នុងករណីរៀបការដោយបង្ខំ វាបង្កប់ន័យថា ប្រសិនបើអាពាហ៍ពិពាហ៍មួយកើតឡើងតាមរយៈការបង្ខិតបង្ខំ [23] សកម្មភាពល្មើសមួយត្រូវបានប្រព្រឹត្តិក្រោមនិយមន័យ នៃការជួញដូរមនុស្សក្នុងច្បាប់ប្រទេសចិន ដោយស្ត្រីនោះត្រូវកំណត់ថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

ក្នុងប្រទេសកម្ពុជា អំពើជួញដូរមនុស្សត្រូវបានកំណត់ដោយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨។ អំពើកេងប្រវ័ញ្ចន៍ដែលចែងក្នុងច្បាប់រួមមាន "គោលបំណងនៃការស្វែងរកប្រយោជន៍ ការបៀតបៀនផ្លូវភេទ ផលិតរូបអាសអាភាស រៀបការផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់នៃការកេងប្រវ័ញ្ចដទៃទៀត" ក្នុងនោះទម្រង់នៃការកេងប្រវ័ញ្ចដទៃទៀតរួមមាន "ការកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ រូបភាពនិងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវាឬពលកម្មដោយបង្ខំ ទាសភាព ឬការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដើម្បីដោះបំណុល សេវភាពមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬការដកហូតសរីរាង្គ"។

"មធ្យោបាយ" រួមមាន "ក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬរបស់តតិយជន តាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលួងលោម"។ យើងអាចមើលឃើញពីការលើកឡើងបន្ថែមអំពី "ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ" នេះសំដៅទៅលើ

---

[23] ការវិភាគនឹងបង្ហាញថា ជាធម្មតាការជ្រើសរើសដោយការបោកបញ្ឆោតមាននៅកម្ពុជា រីឯនៅប្រទេសចិនវិញមានការបង្ខំដើម្បីទទួលបាន "ការយល់ព្រម" ពីនារីនោះឱ្យបានរៀបការ។ វាសរបញ្ជាក់ឱ្យឃើញថានេះជាការរៀបការដោយបង្ខំ ក្នុងបរិបទនៃការសិក្សាស្រាវជ្រាវនេះ។

ការរៀបអាពាហ៍ពិពាហ៍ គឺថាការរៀបការមួយដោយមានការបង្ខិតបង្ខំ បោកបញ្ឆោត គម្រាមកំហែង ។ល។ ត្រូវចាត់ទុកថាជាអំពើជួញដូរមនុស្ស។

បច្ចុប្បន្ននេះពុំទាន់មានយន្តការផ្លូវការទ្វេភាគីណាមួយរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្សនៅឡើយទេ។ ថ្មីៗនេះរដ្ឋាភិបាលទាំងពីរបានចរចារគ្នា និងបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាយ៉ាងមុតមាំក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ របាយការណ៍សិក្សាស្រាវជ្រាវនេះក៏មានគោលបំណងបង្ហាញពីដំណើរការនៃកិច្ចចរចារគ្នានេះផងដែរ។

## ក្របខណ្ឌគោលនយោបាយជាតិស្តីពីការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស

ក្នុងប្រទេសកម្ពុជា អនុក្រិតឆ្នាំ២០០៨ ចែងលម្អិតស្តីពីនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជាជាមួយជនបរទេស ។ មាត្រា២ចែងថាការរៀបការរវាងពលរដ្ឋកម្ពុជា និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សម៉ីខ្លួន។ មាត្រា៧និងមាត្រា៨ហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងារជ្រើសរើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម ក៏ដូចជាការរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ។

លើសពីនេះទៅទៀត ជនបរទេសដែលមានបំណងរៀបការជាមួយពលរដ្ឋកម្ពុជាត្រូវតែមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធី មានដូចជាការបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MOFAIC) និងក្រសួងមហាផ្ទៃ (MOI)។ ពលរដ្ឋកម្ពុជាត្រូវដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ទៅកាន់ការិយាល័យអត្រានុកូលដ្ឋាននៅឃុំ/សង្កាត់ដែលខ្លួនរស់នៅជាអចិន្ត្រៃយ៍។ វានឹងក្លាយជាការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់លុះត្រាតែសម៉ីខ្លួនទាំងពីរនាក់បានផ្តិតមេដៃលើសំបុត្រអាពាហ៍ពិពាហ៍នៅការិយាល័យអត្រានុកូលដ្ឋាននៅឃុំ/សង្កាត់ដោយមានវត្តមានសាក្សីដែលជាមនុស្សពេញវ័យចំនួនពីរនាក់ផងដែរ។

ក្នុងការរួមចំណែកក្នុងការឆ្លើយតប និងរាយការណ៍ករណីរៀបការដោយបង្ខំ អាជ្ញាធរកម្ពុជាបានចាត់វិធានការរឹតបន្តឹងចំពោះការធ្វើចំណាកស្រុកដើម្បីរៀបការនៅប្រទេសចិន។ មានជាអាទ៍ស្ថានអគ្គរាជទូត និងស្ថានកុងស៊ុល ក្នុងប្រទេសចិនទទួលបានការណែនាំពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងឆ្នាំ២០១៤ ឱ្យបញ្ឈប់រាល់ការចេញលិខិតបញ្ជាក់ភាពនៅលីវដល់ស្ត្រីកម្ពុជា [24] តែវិសាលភាពនៃការអនុវត្តរបស់កុងស៊ុលគេមិនបានដឹងច្បាស់ឡើយ។ លើសពីនេះ អាជ្ញាធរកម្ពុជាបានស្នើទៅកាន់សមភាគីចិនរបស់ខ្លួនឱ្យចេញទិដ្ឋា ការទេសចរណ៍ដល់ស្ត្រីកម្ពុជានៅលីវ ដរាបណាគេមានប្រាក់តំកល់ចំនួនមួយម៉ឺនដុល្លារសហរដ្ឋអាមេរិក($10,000) ក្នុងគណនីធនាគារចិន។[25]

នៅប្រទេសចិនឯណោះវិញ ការរៀបការរវាងជនបរទេសនិងជនជាតិចិនត្រូវកំណត់ដោយបញ្ញត្តិសម្រាប់ការចុះសំបុត្រអាពាហ៍ពិពាហ៍ ឆ្នាំ២០០៣។ បញ្ញត្តិនេះបញ្ជាក់ថាក្នុងករណីពលរដ្ឋចិនដីគោកណាម្នាក់មានបំណងរៀបការជាមួយជនបរទេស សម៉ីខ្លួនទាំងពីរនាក់ត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយអាជ្ញាធរមានសមត្ថកិច្ច។ ជនបរទេសនោះត្រូវបង្ហាញលិខិតឆ្លងដែនរបស់ខ្លួនដែលនៅមានសុពលភាព និងលិខិតបញ្ជាក់ភាពនៅលីវដើម្បីបញ្ជាក់ពីការអាចរៀបការបាន។

បញ្ញត្តិនេះក៏បញ្ជាក់ផងដែរថាអាជ្ញាធរមានសមត្ថកិច្ចផ្នែកអត្រានុកូលដ្ឋានអាចបដិសេធន៍ការដាក់ពាក្យស្នើសុំរៀបការ ប្រសិនបើភាគីណាមួយមិនទាន់មានអាយុគ្រប់ការ ឬភាគីណាមួយ ឬភាគីទាំងពីររៀបការម្តងរួចហើយ ហើយសំខាន់នោះ ប្រសិនបើការរៀបការធ្វើឡើងដោយមិនមានការស្ម័គ្រចិត្ត។ បញ្ញត្តិដដែលនោះក៏បានណែនាំថាប្រសិន បើការរៀបការនោះធ្វើឡើងក្រោមការគម្រាមកំហែង ភាគីដែលទទួលរងគ្រោះអាចប្តឹងទៅកាន់មន្ត្រីអត្រានុ កូលដ្ឋានឬប្តឹងទៅកាន់តុលាការដើម្បីធ្វើមោឃភាពនៃការរៀបការនោះបាន។

---

[24] Khan Sophirom, 'កម្ពុជាស្នើសុំទៅបណ្តាស្ថានទូត និងអគ្គកុងស៊ុលចិនដែលមានសវនដ្ឋាននៅបរទេសបញ្ឈប់ផ្តល់ទិដ្ឋាការដល់ស្ត្រីខ្មែរដែលនៅលីវ' *ទីភ្នាក់ងារសារព័ត៌មានកម្ពុជា* (ភ្នំពេញថ្ងៃទី2 ខែសីហាឆ្នាំ២០១៤) http://www.akp.gov.kh/?p=49305 accessed 4 October 2015.

[25] ចំនួននៃការចុះបញ្ជីរៀបការស្ត្រីកម្ពុជាបង្ហាញតាមខេត្តនានាក្នុងប្រទេសចិនធ្លាក់ចុះយ៉ាងខ្លាំងបន្ទាប់ពីគោលនោបាយបង្កការព្រួយបារម្ភខ្លាំងពាក់ព័ន្ធនឹងសិទ្ធិ ហើយស្ត្រីមួយចំនួនធ្វើដំណើរដោយលួចលាក់ទៅកាន់ប្រទេសចិនដើម្បី រៀបការ និងគោលបំណងផ្សេងទៀត អាចបង្កឱ្យមានការរំលោភបំពានច្រើនជាងមុន។Jina Moore (n 2)

លើសពីនេះទៀតទីភ្នាក់ងារដែលជាអន្តរការីក្នុងការរៀបការជាមួយជនបរទេសនោះ ត្រូវបានហាមឃាត់តាំងពីឆ្នាំ១៩៩៤មកម្លេះ។ សេចក្តីជូណដំណឹងពាក់ព័ន្ធនេះបានចែងផង ដែរថា "ទីភ្នាក់ងារក្នុងស្រុក និងស្ថាប័នដទៃទៀតដែលពាក់ព័ន្ធត្រូវបានហាមឃាត់មិនឱ្យប្រតិបត្តិរៀបចំចាត់ចែងការរៀបការជាមួយជនបរទេសឡើយ។ បុគ្គលគ្រប់រូបក៏ត្រូវគេហាមឃាត់ពីការផ្តល់សេវារៀបចំការរៀបការជាមួយជនបរទេស រាល់ទម្រង់នៃការក្លែងបន្លំ ឬក្នុងគោលបំណងទទួលបានប្រាក់ចំណេញ។"

## គោលបំណងនៃកិច្ចការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងបី៖

១. ដើម្បីវិភាគស្វែងយល់ពីទំនាក់ទំនងរវាងការជ្រើសរើស ការអូសទាញ[26] ការដឹកជញ្ជូន និងបែបផែននៃការកេងប្រវ័ញ្ច។

២. ស្វែងយល់ពីសេចក្តីត្រូវការសេវារបស់ស្ត្រីកម្ពុជាត្រូវគេជួញដូរទៅប្រទេសចិនដើម្បីរៀបការដោយបង្ខំ ពេលកំពុងស្នាក់នៅប្រទេសចិន ក្នុងដំណើរការនៃការធ្វើមាតុភូមនិវត្ត និងពេលគេត្រឡប់មកប្រទេសកម្ពុជាវិញ។

៣. ស្វែងយល់ពីឱកាសក្នុងការធ្វើអន្តរាគមន៍ដើម្បីបង្ការមិនឱ្យការរៀបការដោយបង្ខំ និងបង្កើនសេវាគាំពារទាំងនៅថ្នាក់គោលនយោបាយ និងថ្នាក់អនុវត្តកម្មវិធី

# វិធីសាស្ត្រ

## ទំហំសំណាក

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងផ្អែកលើសំណាកស្ត្រីកម្ពុជាចំនួន៨២នាក់ ដែលបានរៀបការនិងរស់ជាមួយប្តីរបស់ពួកគេនៅប្រទេសចិន ខ្លះបាននិងកំពុងស្នាក់នៅក្នុងប្រទេសចិន

[26]ក្នុងការស្រាវជ្រាវ មេខ្យល់ ឬគេហៅថាជាភ្នាក់ងារជាបុគ្គលធ្វើការងារតែម្នាក់ឯងឬជាក្រុម ដែលជួយសម្របសម្រួលការធ្វើចំណាកស្រុកដើម្បីរៀបការរវាងកម្ពុជា ចិន ហើយយកកម្រៃពីសេវានោះ។

និងខ្លះបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ សូមបញ្ជាក់ផងដែរថាក្នុងចំនួនសំណាកក្នុងការសិក្សាស្រាវជ្រាវនេះពុំមាននរណាម្នាក់មានអាយុក្រោម១៨ឆ្នាំទេ។

ការប្រមូលទិន្នន័យធ្វើឡើងរវាងខែកញ្ញា ឆ្នាំ២០១៤ ដល់ខែមីនា ឆ្នាំ២០១៥ នៅប្រទេសទាំងពីរ។ ក្នុងប្រទេសកម្ពុជា ក្រុមការងារបានជួបសម្ភាសក្នុងទីក្រុងភ្នំពេញ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកណ្តាល រីឯនៅប្រទេសចិនឯណោះវិញក្រុមការងារបានជួបសម្ភាសក្នុងទីក្រុងប៉េកាំង ខេត្តក្វាងចូវ ខេត្តហ្វូជៀន និងខេត្តជាងស៊ី។

ក្រុមការងារបានជួបសម្ភាសជាមួយស្ត្រីចំនួន៣៣នាក់ក្នុងប្រទេសកម្ពុជា។ ពួកគេបានរត់ចេញពីស្ថានភាពនៃជីវិតរងការរៀបការដោយបង្ខំក្នុងប្រទេសចិន[27] ហើយពួកគេទទួលបានជំនួយពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានដូចជា៖

- អង្គការចាប់ដៃ
- អង្គការជំនួយផ្នែកច្បាប់សម្រាប់កុមារនិងស្ត្រី (LSCW)
- អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)
- សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (LICHADHO)
- មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ (CWCC)
- អាហ្គាប៉េបេសកកម្មអន្តរជាតិ (AIM)
- មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហាគមន៍ (CLEC)

យើងក៏បានជួបសម្ភាសជាមួយមន្ត្រីសំខាន់ៗពីស្ថាប័ន៖

- មន្ត្រីនគរបាលនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបានជាតិ
- មន្ត្រីនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម
- មន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (MoFAIC)

---

[27] អ្នកឆ្លើយតបសំណួរមួយចំនួនមិនត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការថាជាជនរងគ្រោះដោយការរៀបការដោយបង្ខំដោយមន្ត្រីមានសមត្ថកិច្ចទេ។ ប៉ុន្តែពួកគេទទួលបានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល។

- មន្ត្រីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (NCCT)
- មន្ត្រីនគរបាលនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSVY)
- អង្គការក្រៅរដ្ឋាភិបាលមានដូចជា អង្គការ Chab Dai, LCSW និង Winrock International
- អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)

នៅប្រទេសចិនអ្នកសិក្សាស្រាវជ្រាវបានជួបសម្ភាសស្ត្រីកម្ពុជាចំនួនប្រាំបួននាក់ [28] នៅតាមកន្លែងដូចខាងក្រោម៖

- ១នាក់តាមរយៈនគរបាលមូលដ្ឋានក្នុងខេត្តហ្ស៊ូជៀន
- ១នាក់តាមរយៈពលរដ្ឋក្នុងខេត្តជាងស៊ី
- ១នាក់នៅខេត្តជាងស៊ី តាមរយៈទស្សនកិច្ចសនៅសហគមន៍ដោយក្រុមសិក្សាស្រាវជ្រាវ
- ២នាក់នៅក្រុងប៉េកាំងដែលជួយសង្គ្រោះដោយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ
- ១នាក់នៅខេត្តក្វាចូវដែលជួយសង្គ្រោះដោយពលរដ្ឋម្នាក់
- ២នាក់នៅទីក្រុងប៉េកាំងក្រុមការងារទៅជួបសម្ភាសតាមរយៈការណែនាំរបស់អ្នកផ្តល់សម្ភាសមុន
- ១នាក់បានមកកាន់ស្ថានទូតកម្ពុជានៅទីក្រុងប៉េកាំងដើម្បីស្វែងរកជំនួយ។ ក្នុងខណៈដែលរង់ចាំគេកំណត់អត្តសញ្ញាណ និងមាតុភូមិនិវត្តគាត់ត្រូវបានបញ្ជូនឱ្យទៅស្នាក់នៅមណ្ឌលសង្គ្រោះរបស់រដ្ឋាភិបាល។

នៅក្នុងចំណោមស្ត្រីខ្មែរចំនួន៩នាក់ត្រូវជួបសម្ភាសដោយស៊ីជម្រៅ ៤នាក់ត្រូវបានអាជ្ញាធរកំណត់ថាជាជនរងគ្រោះពីការរៀបការដោយបង្ខំ ហើយ៥នាក់ទៀតក៏មានសណ្ឋានដូចគ្នានឹងអ្នកខាងលើដែរ [29] ប៉ុន្តែពួកគេមិនទាន់បញ្ជូនទៅឱ្យទីភ្នាក់ងារអនុវត្តច្បាប់ ឬមិនទាន់ធ្វើការកំណត់អត្តសញ្ញាណនៅឡើយទេ។

---

[28] ស្ត្រីកម្ពុជានៅប្រទេសចិនចំនួន២៦នាក់ទៀតត្រូវអាជ្ញាធរស្រាវជ្រាវរកស្ទូចនាករស្តីពីការរៀបការដោយបង្ខំ។ ដោយរកមិនឃើញស្ថានភាពរងគ្រោះដោយអំពើជួញដូរមនុស្សទេ អ្នកស្រាវជ្រាវក៏មិនបានសម្ភាសពួកគេឱ្យបានស៊ីជម្រៅឡើយ។

[29] គឺថាធ្លាក់ចូលក្នុងការរៀបការដោយសារការបោកបញ្ឆោត និងបង្ខិតបង្ខំ។

គួរកត់សម្គាល់ថា អ្នកឆ្លើយតបសម្ភាសម្នាក់ដែលបានរៀបការដោយបង្ខំនៅប្រទេសចិន មានការភាពរីករាយនៅក្នុងចំណងអាពាហ៍ពិពាហ៍របស់ខ្លួន។ គាត់ត្រឡប់មកប្រទេសកម្ពុជាពីព្រោះគាត់ចង់ជួយស្ត្រីម្នាក់ទៀតឱ្យមកបានត្រឡប់មកផ្ទះវិញ ដោយសារស្ត្រីនោះមិនសប្បាយចិត្តនៅក្នុងចំណងអាពាហ៍ពិពាហ៍របស់គាត់នៅក្នុងប្រទេសចិន។[30]

ក្នុងប្រទេសចិនយើងក៏បានសម្ភាសជាមួយៈ

- មេខ្យល់នៅខេត្តជាងស៊ី
- មន្ត្រីទូតកម្ពុជាប្រចាំនៅប្រទេសចិន
- ពលរដ្ឋចិនដែលផ្តល់ជំនួយដល់ស្ត្រីកម្ពុជារត់គេចចេញពីជីវិតរៀបការដោយបង្ខំ
- បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជួយស្ត្រីកម្ពុជាដែលផ្តល់កិច្ចសម្ភាសន៍
- មន្ត្រីអគ្រានុកូលដ្ឋានខេត្ត
- នគរបាលព្រហ្មទណ្ឌមូលដ្ឋាន
- មន្ត្រីអន្តោប្រវេសន៍មូលដ្ឋាន

## ឧបករណ៍សម្រាប់ស្រាវជ្រាវ និងការប្រមូលទិន្នន័យ

គម្រោងសិក្សាស្រាវជ្រាវនេះដឹកនាំដោយទីប្រឹក្សាអន្តរជាតិដែលទទួលបានជំនួយបច្ចេកទេសពី UN-ACT។ ក្រៅពីនេះមានទីប្រឹក្សាជាតិម្នាក់នៅប្រទេសកម្ពុជា និងម្នាក់ទៀតនៅប្រទេសចិនសម្រាប់ការប្រមូលទិន្នន័យ។ ទីប្រឹក្សានាំមុខបានធ្វើដំណើរទៅកាន់ប្រទេសកម្ពុជាដើម្បីសម្ភាសន៍ក្រោមការជួយសម្របសម្រួលពីទីប្រឹក្សាជាតិ។ រីឯនៅប្រទេសចិនវិញទីប្រឹក្សាក្នុងប្រទេសនេះទទួលបានការជួយពីអ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិក្នុងការប្រមូលទិន្នន័យដោយមានការជួយពីសំណាក់អ្នកបកប្រែភាសាក្នុងករណីចាំបាច់។

[30] អង្គការមិនមែនរដ្ឋាភិបាលមួយក្នុងប្រទេសចិនដែលផ្តល់កិច្ចគាំពារដល់ស្ត្រីកម្ពុជាដែលគេបង្ខំឱ្យរៀបការ រាយការណ៍ថាអតិថិជនរបស់ខ្លួនបញ្ជាក់ថានាងត្រូវគេបង្ខំឱ្យរៀបការ នាងចង់រត់ត្រឡប់ទៅប្រទេសកម្ពុជាវិញ ប៉ុន្តែក្រោយមកប្រែសំដីវិញថាខ្លួងចង់ត្រឡប់ទៅស្រុកវិញដោយសារនឹកគ្រួសារ ហើយម្យ៉ាងទៀតនេះក៏ជារដូវបុណ្យផងដែរតែខ្លួនគ្មានប្រាក់គ្រប់គ្រាន់ដើម្បីធ្វើដំណើរទេ។

អ្នកប្រមូលទិន្នន័យជាស្ត្រីមានបទពិសោធន៍ក្នុងការសម្ភាសស៊ីជម្រៅលើករណីរសើបនានាដែលរួមមានការកេងប្រវ័ញ្ច និងការជួញដូរមនុស្ស។ តែទីប្រឹក្សាជាតិនៅប្រទេសកម្ពុជាជាមនុស្សប្រុស។ ទីប្រឹក្សាអន្តរជាតិនាំមុខមុនដំបូងបានបោះបង់ការងារចោលការងារ ហើយក្នុងការវិភាគទិន្នន័យជំនួសដោយទីប្រឹក្សាថ្មីម្នាក់ទៀត។

កម្រងសំណួរសម្រាប់សួរស្ត្រីខ្មែរដែររស់នៅប្រទេសចិន ឬត្រឡប់ទៅកាន់ប្រទេសកម្ពុជា មានដូចជាផ្នែកសេដ្ឋកិច្ចសង្គម សារតា (កម្រិតវប្បធម៌ និងការងារ) ព័ត៌មានអំពីគ្រួសារ ជាពិសេសអ្នកនៅក្នុងបន្ទុក កត្តាជម្រុញឱ្យគេសម្រេចចិត្តធ្វើចំណាកស្រុកទៅប្រទេសចិន (ព័ត៌មានពិស្តារអំពីមេខ្យល់ និងការបោកបញ្ឆោតនិងការបង្ខិតបង្ខំ) ការរៀបចំមុនចេញដំណើរ(ការរៀបចំលិខិតឆ្លងដែន ទិដ្ឋាការ និងសំបុត្រយន្តហោះ) ការធ្វើដំណើររហូតដល់គោលដៅនៅក្នុងប្រទេសចិន ដំណើរការនានារហូតដល់រៀបការ (ធាតុផ្សំនៃការបង្ខិតបង្ខំ) ជីវិតបន្ទាប់ពីរៀបការ និងការងារ ការសម្រេចចិត្ត និងការប៉ុនប៉ងរត់គេចពីផ្ទះខាងប្តី និងដំណើរការនៃការធ្វើមាតុភូមិនិវត្ត និងជីវិតក្រោយពេលត្រឡប់មកដល់កម្ពុជាវិញ។

គោលការណ៍ណែនាំបន្ថែមសម្រាប់សម្ភាសត្រូវបានតាក់តែងសម្រាប់សម្ភាសអ្នកធ្វើការងារពាក់ព័ន្ធនានាជាបុគ្គល ហើយជួនកាលធ្វើឡើងជាក្រុមពិភាក្សាផងដែរ។ ការពិភាក្សាផ្តោតលើបញ្ហាសំខាន់ៗទាក់ទងនឹងជំនាញ ដូចជាការងារចំណាកស្រុកដើម្បីរៀបការ ការជួញដូរមនុស្ស និងការរៀបការដោយបង្ខំ។

## ក្រមសីលធម៌ និងសុវត្ថិភាព

កិច្ចសិក្សាស្រាវជ្រាវអនុវត្តក្រោមការត្រួតពិនិត្យដោយ UN-ACT ពាក់ព័ន្ធនឹងក្រមសីលធម៌ ដោយផ្អែកលើបទដ្ឋាន និងគោលការណ៍អនុវត្តមានចែងក្នុងសៀវភៅមគ្គុទេសក៍ ដើម្បីទទួលបានក្រមសីលធម៌ និងសិទ្ធិមនុស្សក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស [31] ។ សៀវភៅនេះបោះពុម្ពផ្សាយដោយ UNIAP ដែលជាគម្រោងមួយមុន UN-ACT។ អ្នកពាក់ព័ន្ធជាមួយនឹងការប្រមូលទិន្នន័យក្នុងប្រទេសទាំងពីរ បានរួមគ្នាអភិវឌ្ឍវិធីសាស្ត្រដើម្បីទទួលបាន

---

[31] កម្មវិធីអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្ស [UNIAP], *សៀវភៅមគ្គុទេសក៍ ដើម្បីទទួលបានក្រមសីលធម៌ និងសិទ្ធិមនុស្សក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស* (UNIAP 2008).

ការគោរពបទដ្ឋានក្រមសីលធម៌ និងសន្តិសុខ មានដូចជាការស្នើសុំការអនុញ្ញាតសម្ភាសជាដើមបន្ទាប់មកបុគ្គលិក UN-ACT បានពិភាក្សា និងពិនិត្យសម្រេច។

ការស្នើសុំការអនុញ្ញាតសម្ភាសធ្វើឡើងជាពីរដំណាក់កាល។ ទីមួយមានការរៀបរាប់ពីគោលបំណងនៃកិច្ចសិក្សាស្រាវជ្រាវនេះនិងសំណួរដែលត្រូវសួរអ្នកតបសម្ភាស មុនពេលដាក់កាលបរិច្ឆេទទៅជួបសួរផ្ទាល់។ ជួនកាលការស្នើសុំនេះធ្វើឡើងដោយមានជួយជ្រោមជ្រែងពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល។ ទីពីរ មុនពេលសម្ភាស អ្នកប្រមូលទិន្នន័យរមែងរៀបរាប់ជាថ្មីម្តងទៀតនូវគោលបំណង រយៈពេលសួរ សំណួរ ការរក្សាការសំងាត់ និងសិទ្ធិរបស់អ្នកតបសំណួរក្នុងអំឡុងពេលសាកសួរនោះ។ ទាល់តែទទួលបានការយល់ព្រមផ្ទាល់មាត់ពីអ្នកតបសំណួរ ទើបអ្នកប្រមូលទិន្នន័យចាប់ផ្តើមសួរសំណួរ។ មានស្ត្រីពីររូបបានបដិសេធន៍មិនផ្តល់សម្ភាស។

កិច្ចសម្ភាសនៅប្រទេសកម្ពុជា ជាទូទៅធ្វើឡើងនៅការិយាល័យអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ជំនួយ ក្នុងបន្ទប់ឯកជនមួយដោយមិនអនុញ្ញាតឱ្យនរណាម្នាក់ក្រៅពីអ្នកធ្វើការលើគម្រោងសិក្សាស្រាវជ្រាវចូលឡើយ។ ប្រសិនបើពុំមានឯកជនភាពគ្រប់គ្រាន់ទេនោះក្រុមការងារនឹងប្រើប្រាស់បន្ទប់សណ្ឋាគារដែលនៅក្បែរនោះជំនួសវិញ។ នៅប្រទេសចិនវិញ ការសម្ភាសស្ត្រីខ្មែរភាគច្រើនធ្វើឡើងនៅផ្ទះខ្លួននៅ ឬនៅផ្ទះស្ត្រីខ្មែរណាមួយទៀតដែលអនុញ្ញាតឱ្យប្រើប្រាស់ដើម្បីសម្ភាសន៍បាន ហើយមួយចំនួនទៀតសម្ភាសនៅស្ថាប័នប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។ ការសម្ភាសជាទូទៅមានរយៈពេល៦០ ទៅ៩០នាទី។

កំណត់ហេតុត្រូវសរសេរជាភាសាអង់គ្លេសដែលអាចអាន និងយកទៅវិភាគបាន។ អត្តសញ្ញាណរបស់អ្នកផ្តល់សម្ភាសត្រូវលុបចេញពីទិន្នន័យក្នុងបំណងរក្សាការសំងាត់របស់បុគ្គលនោះ។

## ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យធ្វើឡើងជាពីរដំណាក់កាល ដោយអ្នកសិក្សាស្រាវជ្រាវចំនួនបីរូប។ ទិន្នន័យពីប្រទេសកម្ពុជា កិច្ចសម្ភាសន៍ធ្វើឡើងជាភាសាខ្មែរហើយត្រូវបកប្រែជាភាសាអង់គ្លេស ដើម្បីឱ្យទីប្រឹក្សាអន្តរជាតិអាចយល់បាន។ ព័ត៌មានដែលទទួលបានពីកិច្ចសម្ភាសន៍ពាក់

ព័ន្ធនឹងប្រធានបទសំខាន់ៗនឹងត្រូវប្រើប្រាស់សម្រាប់ក្នុងការវិភាគនិងសរសេររបាយការណ៍។ ទីប្រឹក្សានៅប្រទេសចិនបានប្រើប្រាស់វិធីប្រហាក់ប្រហែលគ្នាដែរ ហើយព្រាងរបាយការណ៍តាមការវិភាគ និងរកឃើញរបស់គាត់។

ខណៈដែលទីប្រឹក្សាអន្តរជាតិទីមួយបានបោះបង់ការងារពីគម្រោងនោះទៅ ទិន្នន័យ និងការវិភាគពីកម្ពុជា និងរបាយការណ៍នៃការរកឃើញរបស់ទីប្រឹក្សានៅប្រទេសចិនត្រូវប្រគល់ទៅទីប្រឹក្សាអន្តរជាតិថ្មីម្នាក់ទៀត ដែលជ្រើសរើសឱ្យមកជួយបញ្ចប់គម្រោងសិក្សាស្រាវជ្រាវនេះ។ ទិន្នន័យ និងរបាយការណ៍ពីប្រទេសកម្ពុជា និងចិនត្រូវ បានវិភាគរួមគ្នាដើម្បីរកភាពស្រដៀងគ្នានិងភាពខុសគ្នា។ ផ្អែកលើការវិភាគរួមនេះ ទីប្រឹក្សាធ្វើសេចក្តីព្រាងជារបាយការណ៍មួយដែលរួមបញ្ចូលនូវការរកឃើញទាំងអស់នៅក្នុងការសិក្សាស្រាវជ្រាវនេះ។

ការរកឃើញទាំងអស់ក្នុងការសិក្សាស្រាវជ្រាវត្រូវបានពិនិត្យផ្ទៀងផ្ទាត់ក្នុងដំណើរការអានពិនិត្យឡើងវិញ ដោយមានការចូលរួមពីសំណាក់មន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិ បាល ក្រុមអ្នកធ្វើការងារពាក់ព័ន្ធនៅប្រទេសទាំងពីរ។ ការពិនិត្យឡើងវិញនេះធ្វើឡើងអនុ លោមតាមបទដ្ឋានរបស់ UN-ACT ស្តីពីការចែករំលែកព័ត៌មាន និងបោះពុម្ពផ្សព្វផ្សាយ។ ការរកឃើញបឋមត្រូវយកទៅបង្ហាញដល់អ្នកពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា និងប្រទេសចិនដើម្បីឱ្យគេបញ្ជាក់ថាអ្វីដែលរកឃើញពិតជាត្រឹមត្រូវប្រាកដមែន។

## ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

វាជាការសិក្សាស្រាវជ្រាវស្វែងយល់បែបគុណភាព ដើម្បី ផ្តល់ការយល់ដឹងយ៉ាងជ្រាលជ្រៅទៅក្នុងបញ្ហារៀបការដោយបង្ខំ ដែលគ្មាននរណាម្នាក់ដឹងពីទំហំជាក់លាក់របស់វានៅឡើយ។ ការរកឃើញរបស់យើងទាមទារឱ្យធ្វើការប្រៀបធៀបជាមួយការសិក្សាបន្ថែមទៀត ដោយហេតុថា ដោយសារសំណាកនៅតិច មិនមានលក្ខណៈអាចទាយការសន្និដ្ឋានជាទូទៅបាន ហើយការសិក្សាស្រាវជ្រាវនេះគ្របដណ្តប់លើតំបន់មួយភាគតូចតែប៉ុណ្ណោះ នៅក្នុងប្រទេសទាំងពីរ។

ជាងនេះទៅទៀតការសិក្សាស្រាវជ្រាវនេះផ្តោតសំខាន់លើរឿងរ៉ាវរបស់ស្ត្រីខ្មែរដែលពីមុនធ្លាប់រៀបការ និងស្ត្រីខ្មែរដែលកំពុងរស់នៅជាមួយប្តីជនជាតិចិន តែមិនផ្តោតលើទស្សនៈរបស់ឪពុកម្តាយ ប្តី សាច់ថ្លៃ មេខ្យល់ និងអ្នកដទៃឡើយ។

ទោះបីមានការខិតខំអស់ពីសមត្ថភាពក្តី ក៏នៅមានការលំបាកក្នុងការរកអ្នកបកប្រែភាសាខ្មែរឱ្យបានគ្រប់គ្រាន់នៅក្នុងប្រទេសចិនដែរ។ ភាពស្រពេចស្រពិលក្នុងដំណើររឿងរបស់ស្ត្រីទាំងនោះមិនត្រូវបានយកមកប្រើប្រាស់ក្នុងការវិភាគឡើយ។ កិច្ចសម្ភាសន៍មួយចំនួនមិនបានផ្តល់ព័ត៌មានស៊ីជម្រៅគ្រប់គ្រាន់នៅឡើយ ហើយទិន្នន័យនៅ"ស្ងួចស្ងើង"និងមិនអាចយកមកធ្វើទឡ្ហីករណ៍ក្នុងការវិភាគលម្អិតបាន។ ដូចគ្នាផងដែរចំពោះទិន្នន័យទាំងឡាយបានមកពីអ្នកជំនាញក៏មិនសុទ្ធតែត្រូវយកទៅប្រើប្រាស់ទាំងអស់ទេ ល្គឹកណាមិនមានភាពច្បាស់លាស់គ្រប់គ្រាន់នោះ។

លើសពីនេះទៅទៀត ការបោះបង់ការងារភ្លាមៗរបស់ទីប្រឹក្សាអន្តរជាតិក្នុងការសិក្សាស្រាវជ្រាវ ហើយមិនបានផ្តល់ផ្នែកសំខាន់ៗនៃទិន្នន័យមកកាន់ក្រុមការងារវិញ ជាឧបសគ្គមួយយ៉ាងធំ ទាំងក្នុងការវិភាគ ក៏ដូចជាការអនុវត្តគម្រោងសិក្សាស្រាវជ្រាវឱ្យទាន់ពេលវេលាផងដែរ។

## របកគំហើញ៖ លក្ខណៈនៃសំណាក

អ្នកផ្ដល់សម្ភាសន៍មានអាយុរវាង១៨ដល់៣៧ឆ្នាំ [32] ពួកគេទាំងអស់គ្នាធ្លាប់បានរៀនសូត្រនៅសាលារៀនពី៣ដល់១០ឆ្នាំដែរ។ តែពួកគេមួយចំនួនមិនចេះអាននិងសរសេរទេ។ ពួកគេមានអ្នកនៅក្នុងបន្ទុកត្រូវចិញ្ចឹមមានដូចជាម្ដាយឪពុក និងកូនជាដើម។

ពួកគេរស់នៅក្នុងគ្រួសារក្រីក្រ។ អ្នកដែលរស់នៅជនបទជាទូទៅធ្វើការងារកសិកម្ម។ មួយចំនួនបានមករស់នៅទីក្រុងភ្នំពេញ ដោយធ្វើការងារដែលត្រូវការជំនាញទាប តាមបណ្ដារោងចក្រ ក្នុងសេវាកម្ម ឬលក់ដូរតាមផ្លូវជាដើម។ ពួកគេមួយចំនួនបាននិងកំពុងរកការងារធ្វើ។

ចំពោះពួកគេ ការធ្វើដំណើរទៅកាន់ប្រទេសចិនគឺជាដំណើរទៅចេញទៅក្រៅប្រទេសជាលើកដំបូង។

ខាងក្រោមនេះជារឿងរ៉ាវរបស់អ្នកឆ្លើយសំណួរ ដែលបង្ហាញពីអាយុ ស្ថានភាពគ្រួសារ និងចំនួនអ្នកនៅក្នុងបន្ទុក បទពិសោធន៍ការងារ និងប្រាក់ចំណូល៖[33]

- ✓ នាងជាស្ត្រីវ័យ២៣ឆ្នាំនៅលីវ រៀនបានត្រឹមថ្នាក់ទី៦។ នាងបានបោះបង់ការសិក្សាដើម្បីមកជួយរកស៊ីសងបំណុលដែលគ្រួសារនាងជំពាក់គេពីមុនមក។ មុនចាកចេញទៅប្រទេសចិនក្នុងបំណងទៅរកប្រាក់នោះ នាងធ្លាប់ធ្វើការងារនៅក្រុងភ្នំពេញដោយទទួលបានប្រាក់បៀវត្សចំនួន៦០$ ក្នុងមួយខែ។

---

[32] អាយុអប្បបរមារបស់ស្ត្រីដើម្បីរៀបការក្នុងប្រទេសចិនគឺអាយុ២០ឆ្នាំ។ ក្នុងអំឡុងសិក្សាស្រាវជ្រាវនោះយើងរកឃើញនិងសម្ភាសនារីវ័យក្មេងអាយុត្រឹមតែជាង១៨។ អ្នកផ្ដល់សេវាគាំពារក៏បានប្រាប់ដែរថាខ្លួនធ្លាប់បានជួយស្ត្រីខ្មែរមួយចំនួនក្រោម១៨ឆ្នាំដែលរត់ចេញពីស្ថានភាពរៀបការដោយបង្ខំនៅប្រទេសចិននោះដែរ។ ក៏មានព័ត៌មានផ្សេងទៀតលើកឡើងដែរថាមេខ្យល់ជារឿយៗប្រើប្រាស់សៀវភៅគ្រួសារ និងឯកសាររបស់អ្នកដទៃ ហើយប្រាប់ទៅក្មេងស្រីដែលមិនទាន់គ្រប់អាយុនោះឱ្យកុហាក់អាយុខ្លួននៅពេលធ្វើលិខិតឆ្លងដែន។

[33]គួរកត់សម្គាល់ផងដែរថាយើងបានសម្ភាសស្ត្រីខ្មែរមួយចំនួនបានមកប្រទេសចិនក្នុងគោលបំណងដើម្បីរៀបការ ហើយបានរួមរស់ជាមួយប្ដីចិនរបស់ខ្លួនដោយមិនមានបញ្ហាឡើយ។ ប៉ុន្តែការវិភាគក្នុងរបាយការណ៍នេះធ្វើឡើងចំពោះតែស្ត្រីខ្មែរណាដែលទទួលរងការបង្ខំឱ្យរៀបការតែប៉ុណ្ណោះ។ ដូច្នេះរាល់សញ្ញាណវិជ្ជមានទាំងឡាយណាមិនត្រូវរាប់បញ្ចូលក្នុងការសិក្សាស្រាវជ្រាវនេះឡើយ។

- ✓ នាងមានអាយុ៣២ឆ្នាំជាស្ត្រីមេម៉ាយមានកូន៣នាក់ និងក្មួយចំនួន២នាក់ទៀតនៅក្នុង បន្ទុក។ នាងធ្លាប់ទៅធ្វើការងារនៅប្រទេសថៃមួយរយៈដែរ ដោយទុកកូនឱ្យឪពុកម្តាយចាស់ជាអ្នកមើលថែរក្សា។ ការធ្វើការងារនៅរោងចក្រនាងទទួលបានប្រាក់ខែបន្តិចបន្តួច ហើយនាងក៏សម្រេចចិត្តទៅប្រទេសចិនដែលនាងគិតថាមានការងារដែលមានប្រាក់ខែខ្ពស់ជាង។
- ✓ នាងជាស្ត្រីមានវ័យ២៩ឆ្នាំមានកូនតូចពីរនាក់ និងម្តាយឪពុកនៅក្នុងបន្ទុក។ នាងមិនចេះអានឬសរសេរទេ ទោះបីជាបានរៀនចប់ថ្នាក់ទី២ហើយក្តី។ មុនពេលចេញទៅប្រទេសចិន នាងធ្វើការងារនៅតាមចំការដែលទទួលបានប្រាក់ប្រចាំថ្ងៃ។ មិត្តភក្តិរបស់នាងម្នាក់ដែលធ្វើការនៅប្រទេសចិនប្រាប់នាងថានាងអាចមករកប្តីល្អម្នាក់ ហើយរកការងារធ្វើដើម្បីជួយចិញ្ចឹមគ្រួសារ។
- ✓ នាងមានអាយុ១៩ឆ្នាំ រៀនបានថ្នាក់ទី៦។ នាងបោះបង់ការសិក្សាហើយទៅភ្នំពេញជាមួយបងស្រីនាងដើម្បីធ្វើការងារ។ កាលនោះនាងមានអាយុ១៧ឆ្នាំ ធ្វើការនៅរោងចក្រកាត់ដេរមួយ។ ប្រាក់ខែទាំងពីរនាក់បងប្អូនស្ទើតែមិនអាចដោះស្រាយជីវភាពរស់នៅរបស់គេទាំងពីរបានផង។ នាងក៏សម្រេចចិត្តទៅធ្វើការងាររោងចក្រកាត់ដេរមួយនៅប្រទេសចិនដែលនាងគិតថាទទួលបានប្រាក់ខែច្រើនជាង ប៉ុន្តែនាងត្រូវធ្លាក់ខ្លួនក្នុងការរៀបការដោយបង្ខិតបង្ខំទៅវិញ។
- ✓ នាងមានអាយុ៣៨ឆ្នាំមានប្តីមានកូនពីរនាក់ ធ្វើការនៅរោងចក្រកាត់ដេរ នៅក្នុងរាជធានីភ្នំពេញ។ នាងបានខ្ចីប្រាក់គេទៅព្យាបាលម្តាយនាង ហើយក៏សម្រេចចិត្តទៅប្រទេសចិនដែល គិតថានឹងមានឱកាសការងារប្រាក់ខែខ្ពស់ជាង។

# របកគំហើញ៖ ដំណាក់កាលនៃការជ្រើសរើស

## មេខ្យល់ទីមួយ

មេខ្យល់ទីមួយជាធម្មតាស្គាល់ស្ត្រីនោះ ឬក្រុមគ្រួសារនាង។ គេអាចជាអ្នកជិតខាងនឹងគ្នា អ្នកលក់គ្រឿងទេស ឬជាអ្នករស់នៅក្នុងភូមិជាមួយគ្នា។ អ្នកតបសម្ភាស និងក្រុមគ្រួសារជាច្រើន ជឿទុកចិត្តមេខ្យល់ដោយសារគេស្គាល់គ្នា ហើយមេខ្យល់នោះធ្លាប់មានបទពិសោធន៍បញ្ជូនស្ត្រីទៅកាន់ប្រទេសចិនដោយមិនមានបញ្ហាអ្វីឡើយ។ មេខ្យល់នោះក៏បានបញ្ជាក់ទៀតថាខ្លួនធ្លាប់ជួយគេ ឬខ្លួនមានប្អូនស្រីឬកូនស្រីទៅប្រទេសចិន ហើយតែងតែផ្ញើប្រាក់មកផ្ទះជាទៀងទាត់។ នៅទីក្រុងឯណោះមេខ្យល់ទីមួយនោះអាចអ្នកធ្វើការងារជាមួយគ្នា ឬអ្នកដែលគេធ្លាប់ជួបនៅកន្លែងការងារ។[34] មេខ្យល់តែងតែស្លៀកពាក់ "ស្អាតបាត" ឬជាអ្នកមានទ្រព្យធនដើម្បីធ្វើឱ្យជឿទុកចិត្តខ្លួន។

មានរឿងមួយគួរឱ្យចាប់អារម្មណ៍ផងដែរគឺអ្នកតបសំណួរបានឮ ឬដឹងថាមានស្ត្រីម្នាក់ត្រឡប់មកពីប្រទេសចិន បន្ទាប់ពីមានការលំបាករស់នៅជាមួយប្តី និងបញ្ហានៅកន្លែងការងារក្នុងប្រទេសចិន។ ម្នាក់ទៀតក៏បានបញ្ជាក់ថានាងបានមកប្រទេសចិន ទោះបីជានាងដឹងថាក្នុងភូមិនាងមានអ្នកត្រឡប់មកពីប្រទេសចិនវិញក្រោយពីគេបង្ខំឱ្យការជាមួយបុរសពិការទាំងរាងកាយ ឬសតិស្មារតីក៏ដោយ។ មានអ្នកដទៃទៀតដឹងថាមានករណីមួយចំនួនស្ត្រីខ្មែរបានរៀបការហើយរស់នៅក្នុងជីវភាពធូរធារ និងដោយក្តីរីករាយផង ដោយសារបទពិសោធន៍ទាំងវិជ្ជមាន និងអវិជ្ជមាននោះហើយ ទើបក្រុមគ្រួសារហាក់ដូចជាមិនសូវព្រួយបារម្ភពីរូបគេប៉ុន្មានឡើយ។

អ្នកតបសំណួរទាំងអស់មកពីគ្រួសារមានជីវភាពលំបាក ហើយជាអ្នកទទួលរ៉ាប់រ៉ងជីវភាពគ្រួសារផង។ មេខ្យល់តែងតែលើកឡើងថានាងអាចរកប្រាក់នៅប្រទេសចិនបានច្រើនជាងនៅប្រទេសកម្ពុជា ដោយទៅធ្វើការ ឬទៅរៀបការជាមួយប្តីចិនដែលជាអ្នកមានទ្រព្យធន

[34] ឧទាហរណ៍ កម្មកររោងចក្រកាត់ដេរម្នាក់ប្រាប់ថា មិត្តរួមការងាររបស់នាងសួថាតើនាងចង់ទៅធ្វើការនៅប្រទេសចិនទេ។ នារីម្នាក់ទៀតប្រាប់ថាមានស្ត្រីស្លៀកពាក់ស្អាតបាតក្នុងវ័យជាង៥០ឆ្នាំដែលជាម៉ូយប្រចាំកន្លែងអ៊ុតសក់ដែលនាងធ្វើការមករកទាក់ទងនាង។

ឬអាចទៅការជាមួយប្តីអ្នកមានហើយអាចធ្វើការងារបានទៀត។ មេខ្យល់ជូនកាលផ្តល់ឧទាហរណ៍ថាស្ត្រីមួយចំនួនទៅរៀបការនៅប្រទេសចិនពេលមកលេងស្រុកកំណើតម្តងៗពាក់មាសជ្រែកខ្លួន ឬភាពហឺហារដទៃទៀត។ ជួនកាលគេបង្ហាញវីដេអូរូបមនុស្សប្រុសមួយចំនួនដែលជាអ្នកកំពុងស្វែងរកប្រពន្ធ។ មុនពេលចាកចេញទៅប្រទេសចិនអ្នកតបសំណួរជាធម្មតាធ្វើការនៅរោងចក្រកាត់ដេរ ធ្វើការនៅភោជនីយដ្ឋាន ឬក៏លក់ដូរតាមផ្លូវ។ ពួកគេទទួលបានប្រាក់ខែត្រឹមតែ៦០$ ដល់៣០០$ តែប៉ុណ្ណោះ។ មេខ្យល់ប្រាប់ថាបើការងារបែបនោះនៅប្រទេសចិនគេអាចទទួលប្រាក់ខែពី៥០០$ ដល់ទៅ៨០០$ឯណោះ។[35]

ជួនកាល ការឱ្យប្រាក់មុនជាគឺជាការលើកទឹកចិត្តក្នុងគោលបំណងជ្រើសរើស។ អ្នកតបសំណួរបាននិយាយថាប្រាក់នេះជា "ប្រាក់បណ្ណាការ"[36] ប្រាក់សម្រាប់រៀបចំធ្វើដំណើរ ឬប្រាក់ខែបើកមុន មានចំនួនរវាងពី២០០$ ដល់១០០០$[37] ប៉ុន្តែមានលក្ខណ្ឌដូចឧទាហរណ៍ដូចខាងក្រោម៖

> "*បុរសនោះមិនតម្រូវឱ្យខ្ញុំចេញលុយធ្វើលិខិតឆ្លងដែន និងថ្លៃសំបុត្រយន្តហោះឡើយ ផ្ទុយទៅវិញគាត់ឱ្យខ្ញុំខ្ចី១០០០$ដើម្បីជួយគ្រួសារខ្ញុំទៀត។ ប៉ុន្តែខ្ញុំត្រូវសងគាត់វិញតាមរយៈការកាត់ប្រាក់ខែរបស់ខ្ញុំពេលធ្វើការងារនៅប្រទេសចិន។ ប្រសិនបើខ្ញុំប្តូរចិត្តមិនទៅវិញនោះខ្ញុំត្រូវបង់លុយសងគាត់វិញចំនួន២៥០០$។*"

មេខ្យល់មួយចំនួនបានឱ្យលុយដល់គ្រួសារស្ត្រីនោះ តែក្រោយមកវាក្លាយជាសម្ពាធឱ្យនាងយល់ព្រមរៀបការពេលទៅដល់ប្រទេសចិន។ យោងតាមអ្នកតបសំណួរម្នាក់ មេខ្យល់ប្រាប់ថានាងអាចទៅធ្វើការងារ ឬទៅយកប្តីនៅប្រទេសចិន ប៉ុន្តែពេលទៅដល់គោលដៅគេប្រាប់ថានាងថាត្រូវតែរៀបការជាមួយបុរសចិនម្នាក់។ បន្ទាប់មកនាងក៏ទូរស័ព្ទមកកាន់ម្តាយ

---

35 ជាធម្មតាមេខ្យល់ទីមួយជាអ្នកប្រាប់ដល់ស្ត្រីទាំងនោះថាកម្មកររោងចក្រកាត់ដេរនៅប្រទេសចិនគេអាចរកប្រាក់បានពី៥០០$ ដល់៦០០$ក្នុងមួយខែ។ នៅពេលនោះស្ត្រីទាំងនោះរកបានត្រឹមតែ៦៥$ក្នុងមួយខែតែប៉ុណ្ណោះនៅកម្ពុជា។

36 "dowry=បណ្ណាការ" ជាពាក្យដែលគេប្រើប្រាស់ក្នុងកិច្ចសម្ភាសន៍ ប៉ុន្តែតាមពិតទៅវាសំដៅទៅតម្លៃខ្លួនកូនក្រមុំដែលកូនកម្លោះជូនទៅខាងស្រី ក្នុងករណីនេះមេខ្យល់ជាអ្នកឱ្យទៅគ្រួសារខាងស្រីជំនួសខ្លួនតែប៉ុណ្ណោះ។

37 ករណីមួយស្ត្រីម្នាក់ធ្វើការនៅរោងចក្រកាត់ដេរនៅប្រទេសកម្ពុជា មេខ្យល់ប្រាប់ថានៅប្រទេសចិនអ្នកមានជំនាញកាត់ដេរដូចនាងអាចទទួលប្រាក់ខែបានដល់ទៅ១០០០$ឯណោះ។ នាងបដិសេធន៍ដោយប្រាប់ថាគ្មានប្រាប់សម្រាប់ធ្វើដំណើរឡើយ មេខ្យល់ប្រាប់ថាគេអាចបើកឱ្យ៥០០$មុនសម្រាប់ធ្វើដំណើរបាន។

នាងនៅស្រុកកំណើតដើម្បីសួរយោបល់ ប៉ុន្តែម្តាយប្រាប់នាងថាឱ្យព្រមរៀបការទៅ ព្រោះបានទទួលប្រាក់ពីគេរួចហើយ។

ការដាក់សម្ពាធលើគ្រួសារបែបនេះ ហើយជួនកាលការសម្រេចចិត្តជំនួសសម៉ីខ្លួនជាកត្តាជម្រុញឱ្យមានការធ្វើចំណាកស្រុកដើម្បីរៀបការទៀតផង។ ខាងក្រោមនោះជាឧទាហរណ៍ស្រាប់៖

> *"មេខ្យល់ម្នាក់ទៅលួងលោមម្តាយខ្ញុំនៅខេត្តកំពង់ចាមឱ្យជួយបញ្ចុះបញ្ចូលឱ្យខ្ញុំទៅរៀបការជាមួយបុរសចិន។ ម្តាយខ្ញុំប្រាប់ខ្ញុំថាអ្នកជិតខាងខ្ញុំបានទៅប្រទេសចិន ផ្ញើប្រាក់ជាច្រើនមកផ្ទះ ហើយគាត់ប្រាប់ទៀតថាធ្វើការងារនៅភ្នំពេញបានតែមួយខែ១០០$ប៉ុណ្ណោះ ជួយគ្រួសារមិនគ្រប់ទេ។ ខ្ញុំស្តាប់ម្តាយហើយក៏យល់ព្រមទៅរៀបការជាមួយបុរសជនជាតិចិន។"*

អ្នកឆ្លើយសំណួរដទៃទៀត ហាក់បីដូចជាបានរៀបចំខ្លួនជាស្រេចដើម្បីធ្វើដំណើរទៅប្រទេសចិន និងមានការគាំទ្រពីក្រុមគ្រួសាររបស់ពួកគេផង ប៉ុន្តែក៏មានសមាជិកគ្រួសារបានជំទាស់ដាច់ខាតក្នុងការធ្វើចំណាកស្រុកទៅប្រទេសចិន ទោះពីជាយ៉ាងណាក៏ដោយ ស្ត្រីមួយចំនួនមិនស្តាប់ទេហើយក៏អត្តនោម័តទៅដោយខ្លួនឯងតែម្តង។

ព័ត៌មានស្តីពីការរៀបការតែងតែធ្វើឡើងក្នុងរូបភាពបោកបញ្ឆោតថា ត្រូវតែរៀបការជាមុនសិន ទើបអាចមានការងារប្រាក់ខែខ្ពស់នៅប្រទេសចិន។ ក្រៅពីព័ត៌មានមិនត្រឹមត្រូវនេះ[38] អ្នកតបសម្ភាសជាធម្មតាគេប្រាប់ថាទៅប្រទេសចិនពួកគេអាចជ្រើសរើសប្តី ហើយមានសិទ្ធិបដិសេធន៍មិនរៀបការជាមួយបុរសណាម្នាក់បាន។ តែអ្វីដែលលើកឡើងនេះ វាមិនបានកើតឡើងទេ។ មានឧទាហរណ៍មួយចំនួន ដែលនឹងមានរៀបរាប់នៅពេលក្រោយ។ ខ្លះទៀតគេប្រាប់ថាពេលទៅដល់ប្រទេសចិនគេទុកពេលឱ្យមួយខែដើម្បីពិចារណារឿងយកប្តី តែក្នុងរយៈពេលនោះបើមិនចង់នៅប្រទេសចិនទេហើយចង់ត្រឡប់មកប្រទេសកម្ពុជាវិញនោះត្រូវបង់ប្រាក់សងថ្លៃមេខ្យល់ ចំណាយរត់ការទាំងអស់ខុសៗគ្នា ដោយមានចាប់ពី២០០០$ ដល់៨០០០$។

[38] ការចុះសំបុត្រអាពាហ៍ពិពាហ៍នៅប្រទេសចិនមិនបញ្ជាក់ពីសិទ្ធិរកការងារធ្វើបានឡើយ។ ការងារស្របច្បាប់សម្រាប់ជនបរទេសមិនពាក់ព័ន្ធនឹងស្ថានភាពអាពាហ៍ពិពាហ៍ទេ ម្យ៉ាងទៀតការងារក៏ពិបាករកជាពិសេសអ្នកដែលគ្មានជំនាញតែម្តង។

មេខ្យល់មួយចំនួនទៅជួប ឬទូរស័ព្ទទៅកាន់ស្ត្រី និងក្រុមគ្រួសាររបស់នាងម្តងហើយម្តងទៀត ទោះបីគេបដិសេធន៍ម្តងហើយម្តងទៀតក្តី។ ខាងក្រោមនេះជាឧទាហរណ៍មួយដែលបញ្ជាក់ពីមេខ្យល់ព្យាយាមបញ្ចុះបញ្ចូល ប៉ុន្តែចុងក្រោយស្ត្រីនោះសម្រេចចិត្តទៅប្រទេសចិនៈ

*"ក្នុងពេលដែលខ្ញុំកំពុងធ្វើការងារនៅក្រុងភ្នំពេញ មានស្ត្រីម្នាក់មកពីភូមិខ្ញុំទូរស័ព្ទមកខ្ញុំថាម្តាយរបស់ខ្ញុំពុំមានលុយកាក់សោះ ហើយខ្ញុំគួរតែជួយគាត់គ្រាន់តែទៅរៀបការជាមួយបុរសចិន។ គាត់បានឱ្យកូនស្រីគាត់ពីនាក់ការជាមួយប្តីចិន ហើយពួកគេបានផ្ញើលុយមកផ្ទះចំនួន៧០០$ ពេលទៅដល់ប្រទេសចិនភ្លាម ហើយមួយខែក្រោយមកនាងក៏ផ្ញើប្រាក់៥០០០$ថែមទៀត។ ទោះខ្ញុំបដិសេធន៍គាត់ហើយក្តី ក៏គាត់នៅតែទូរស័ព្ទមកខ្ញុំម្តងហើយម្តងទៀតពីរឬបីថ្ងៃម្តង ដើម្បីបញ្ចុះបញ្ចូលខ្ញុំ។ ក្រោយមក គាត់ទៅដល់ផ្ទះហើយល្បួងម្តាយខ្ញុំឱ្យជួយនិយាយខ្ញុំទៅរៀបការជាមួយប្តីចិន។"*

## មេខ្យល់ទីពីរ និងមេខ្យល់ទីបី

ពេលមានការព្រមព្រៀងគ្នាហើយ មេខ្យល់ទីមួយបានទាក់ទងស្ត្រីដែលគេល្បួងបាននោះឱ្យទាក់ទងគ្នាជាមួយមេខ្យល់ទីពីរ (ហើយជួនកាលមេខ្យល់ទីបី) ដើម្បីជួយរៀបចំឯកសារសម្រាប់ធ្វើដំណើររួមមានលិខិតឆ្លងដែន និងទិដ្ឋាការ។ ស្ត្រីនៅជនបទត្រូវមេខ្យល់នាំមកភ្នំពេញដើម្បីរៀបចំឯកសារ ហើយភ្នាក់ងាររបស់ពួកគេជាអ្នកចាត់ចែងតាមការិយាល័យ និងស្ថាប័ននានា។

ខាងក្រោមនេះជារឿងរ៉ាវរបស់ស្ត្រីម្នាក់ធ្វើការងារនៅទីក្រុងភ្នំពេញ ហើយអ្នកធ្វើការងារជាមួយនាងមករកនាង ព្យាយាមនិយាយពន្យល់នាងឱ្យទៅប្រទេសចិនៈ

*"ស្ត្រីម្នាក់បានណែនាំខ្ញុំទៅបុរសម្នាក់ គាត់ហ្នឹងជាអ្នករត់ការធ្វើលិខិតឆ្លងដែន និងឯកសារសម្រាប់ធ្វើដំណើរដទៃទៀត។ បុរសនោះទារពីខ្ញុំនូវឯកសារចម្លងអត្តសញ្ញាណប័ន សំបុត្រកំណើត និងសៀវភៅគ្រួសារ។ ខ្ញុំបានទៅជួបមនុស្សម្នាក់ទៀតនៅកន្លែងធ្វើលិខិតឆ្លងដែន ហើយគាត់ជួយនាំខ្ញុំទៅផ្តិតស្នាមក្រយៅដៃ និងថតរូប ពេលនោះខ្ញុំឃើញមានស្ត្រីបួននាក់ផ្សេងទៀតទៅធ្វើលិខិតឆ្លងដែនជាមួយមនុស្សម្នាក់ហ្នឹងដែរ។ ពីរសប្តាហ៍ក្រោយមកខ្ញុំក៏រៀបចំចេញដំណើរ។ ទាល់*

*តែទៅដល់អាកាសយានដ្ឋាន ទើបគេឱ្យឯកសារសម្រាប់ធ្វើដំណើរទាំងអស់មកខ្ញុំ ហើយគេប្រាប់ខ្ញុំឱ្យនិយាយថាទៅប្រទេសចិនទៅលេងបងប្អូន។"*

ជាទូទៅលិខិតឆ្លងដែនត្រូវការពេលពីពីរបីថ្ងៃរហូតដល់ពីរខែឯណោះទើបរួច តែតាមការសម្ភាស អ្នកតបសំណួរទាំងអស់គ្នាប្រាប់ថាលិខិតឆ្លងដែនធ្វើរួចក្នុងអំឡុងពេលពីពីរទៅបួនសប្តាហ៍។ មេខ្យល់ប្រមូលលិខិតឆ្លងដែនទុកទាំងអស់។ ពេលឯកសារផ្សេងទៀតរួចរាល់ហើយ មេខ្យល់ក៏ទិញសំបុត្រយន្តហោះឱ្យស្ត្រីទាំងនោះធ្វើដំណើរទៅប្រទេសចិន។

## របកគំហើញ៖ ដំណាក់កាលចំណាកស្រុក

នៅពេលដែលឯកសារទាំងឡាយរៀបចំរួចរាល់ហើយនោះ មេខ្យល់នាំស្ត្រីទាំងនោះទៅអាកាសយានដ្ឋានភ្នំពេញ ហើយជួយបំពេញបែបបទសម្រាប់ចាកចេញជាដើម។ អ្នកតបសំណួរតែងតែធ្វើដំណើរជាក្រុមពីបីទៅប្រាំមួយនាក់ មានករណីតិចតួចបំផុតដែលស្ត្រីទាំងនោះមានមេខ្យល់ជូនទៅតាមយន្តហោះ។ គេទទួលលិខិតឆ្លងដែន និងសំបុត្រយន្តហោះនៅឯអាកាសយានដ្ឋាន ហើយប្រសិនបើមាននរណាសួរ មេខ្យល់បង្គាប់ពួកគេឱ្យនិយាយថាទៅស្រុកចិនដើម្បីទៅលេងបងប្អូន ឬទៅដើរលេង។ អ្នកតបសំណួរហោះហើរតាមជើងយន្តហោះផ្ទាល់ពីភ្នំពេញទៅសៀងហៃ ឬពីភ្នំពេញទៅក្វាងចូវ។

មានករណីតិចតួចប៉ុណ្ណោះដែលធ្វើដំណើរតាមផ្លូវគោកតាមប្រទេសវៀតណាមទៅកាន់ប្រទេសចិន។[39] អ្នកតបសំណួរម្នាក់ត្រូវមេខ្យល់នាំពីកម្ពុជាទៅក្រុងហូជីមិញ។ នាងត្រូវរង់ចាំទទួលទិដ្ឋាការទៅប្រទេសចិនរយៈពេលជាច្រើនថ្ងៃ។ មេខ្យល់ក៏នាំនាងទៅក្រុងប៉េកាំង ហើយប្រគល់ឱ្យទៅភ្នាក់ងារនៅក្នុងស្រុកនោះដែលនាំនាងទៅឱ្យភ្នាក់ងារម្នាក់ទៀតហើយនាងពុំដែលស្គាល់ឈ្មោះពួកគេឡើយ។ អ្នកតបសំណួរមួយចំនួនពុំបានដឹងពីច្រកដែលខ្លួនចូលទៅ ឬគោលដៅនៅក្នុងប្រទេសចិនទេ។

ពេលមកដល់អាកាសយានដ្ឋាននៅប្រទេសចិន មានមេខ្យល់មកទទួលនៅច្រកចេញដោយមានសរសេរឈ្មោះពួកគេលើផ្ទាំងក្រដាសមួយ។ គេក៏ត្រូវយកទៅជនបទតាមរថយន្តរថយន្តក្រុង ឬរថភ្លើងហើយឱ្យនៅសម្រាកនៅផ្ទះមេខ្យល់ ឬកន្លែងក្បែរៗនោះដើម្បីណែនាំទៅកាន់បុរសដែលកំពុងរកប្រពន្ធ។ ក្នុងករណីខ្លះភ្នាក់ងារនៅប្រទេសចិនបានរៀបការជាមួយនារីខ្មែរ។ ខណៈពេលរង់ចាំនោះអ្នកតបសំណួរត្រូវគេប្រាប់ថាត្រូវតែរៀបការបើមិនដូច្នោះទេ ត្រូវសងលុយរាល់ការចំណាយឱ្យដល់គេវិញ។

[39] នេះប្រហែលជាស្របពេលដែលមានការលំបាកក្នុងការស្នើរសុំទិដ្ឋាការទេសចរណ៍ដល់ស្ត្រីខ្មែរនៅលីវទៅចិន។ អាជ្ញាធរកម្ពុជាបានស្នើរសុំទៅស្ថានទូតចិនឱ្យមានការរឹតបន្តឹងក្នុងការផ្តល់ទិដ្ឋាការដល់ស្ត្រីខ្មែរនៅតាមបណ្តាប្រទេសនានា រួមមានប្រទេសឡាវ ថៃ និងវៀតណាម (អានKhan Sophirom (n 23))។វាល្អដែរក្នុងការតាមដានរាល់របៀបធ្វើដំណើរទៅកាន់ប្រទេសចិនរបស់ស្ត្រីខ្មែរក្រោយពីមានការដាក់ចេញគោលនយោបាយបែបនោះ។

ខាងក្រោមនេះជារឿងរ៉ាវរបស់ស្ត្រីម្នាក់ដែលពណ៌នាពីដំណើររបស់នាងរហូតដល់គោលដៅនៅប្រទេសចិន៖

*"នៅឯអាកាសយានដ្ឋានកម្ពុជា ខ្ញុំបានជួបនារីក្មេងៗចំនួនបួននាក់ផ្សេងទៀតដែលត្រូវធ្វើដំណើរជាមួយខ្ញុំដែរ។ យើងទទួលបានលិខិតឆ្លងដែន និងសំបុត្រយន្តហោះគ្រប់ៗគ្នា។ បន្ទាប់ពីចុះឈ្មោះចូលរួចហើយ យើងដើរតាមបុរសម្នាក់ដែលខ្ញុំមិនស្គាល់ទៅកន្លែងពិនិត្យលិខិតឆ្លងដែន និងនាំឡើងជិះយន្តហោះ។ យន្តហោះចុះនៅទីក្រុងប៉េកាំង ហើយមានបុរសម្នាក់ទៀតមកនាំពួកយើងទៅកាន់ក្រុងមួយ។ គេឱ្យយើងសម្រាកពីរបីយប់នៅផ្ទះសំណាក់មួយ ហើយក្រោយមកគេក៏បំបែកពួកយើងទៅតាមទិសដៅផ្សេងៗគ្នា។ ប៉ុន្មានម៉ោងក្រោយមកឡានក៏ឈប់មានមនុស្សបីនាក់រង់ចាំនៅចិញ្ចើមថ្នល់។ គេឱ្យខ្ញុំចុះពីឡាននេះ ហើយឱ្យឡើងឡានមួយទៀត។ ខ្ញុំសួរគេជាភាសាខ្មែរថានាំខ្ញុំទៅណា? ឱ្យខ្ញុំធ្វើអ្វី? ប៉ុន្តែគ្មាននរណាម្នាក់ឆ្លើយតបខ្ញុំឡើយព្រោះអ្នកបើកបរជាជនជាតិចិន។"*

# របកគំហើញ៖ ដំណើរការនៃការរៀបអាពាហ៍ពិពាហ៍

## ការផ្សំផ្គុំគូស្វាមីភរិយា

ពេលមកដល់ផ្ទះមេខ្យល់ភ្លាម មានបុរសចិននៅតំបន់នោះមកមើល។ មានស្ត្រីខ្លះគេឱ្យសម្រាកពីរឬបីថ្ងៃសិន មានខ្លះទៀតផ្សំផ្គុំត្រូវរៀបចំភ្លាមៗតែម្តង។ ខាងក្រោមគឺជា ការរៀបរាប់របស់របស់ស្ត្រី៖

*"ពេលមកដល់ហើយកំពុងដើរចូលទៅផ្ទះមេខ្យល់មានគ្រួសារមួយបញ្ឈប់ពួកយើង ហើយសួររកកូនក្រមុំ។ គេឱ្យមេខ្យល់នាំស្ត្រីទាំងនោះទៅកាន់ភោជនីយដ្ឋានមួយដើម្បីឱ្យគេជ្រើសរើសម្នាក់យកធ្វើជាប្រពន្ធ។"*

*"មកដល់បានមួយថ្ងៃ មេខ្យល់ឱ្យយើងស្លៀកពាក់ និងផាត់មុខឱ្យបានស្អាតៗ ហើយអង្គុយជាជួរនៅក្នុងបន្ទប់មួយ។ មានបុរសចិនជាច្រើននាក់មកមើលពួកយើង។ នរណាពេញចិត្តគេក៏យកទៅរៀបការទៅ។"*

*"គេឱ្យយើងនៅផ្ទះមួយ។ ពីរថ្ងៃក្រោយមក មានបុរសៗមកមើលយើង ហើយយកស្ត្រីពីរឬបីនាក់ចេញទៅ។ ខ្ញុំសួរស្ត្រីដែលនៅក្បែរខ្ញុំថាហេតុអ្វីបានជាមាន*

*ប្រុសៗមកមើលយើងអញ្ចឹង។ នាងក៏ប្រាប់ខ្ញុំថាប្រុសៗនោះគេមករកប្រពន្ធ។ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង ព្រោះថាខ្ញុំមកនេះមករកការងារធ្វើទេ។ នាងក៏ប្រាប់ខ្ញុំថា ប្រសិនបើមិនរៀបការជាមួយប្តីចិនទេគឺរកការងារមិនបានឡើយ។*

*"គេឱ្យពួកយើងនៅផ្ទះមួយប្រហែលមួយសប្តាហ៍។ ខ្ញុំសួរគេម្តងហើយម្តងទៀតអំពីការងារដែលខ្ញុំត្រូវធ្វើ ប៉ុន្តែប្រពន្ធមេខ្យល់ប្រាប់ថា ប្តីរបស់នាង (ដែលជាមេខ្យល់) កំពុងស្វែងរកការងារឱ្យ។ ក្រោយមកនាងនោះក៏មកប្រាប់ខ្ញុំវិញថាបើមានប្តីចិននោះនឹងងាយស្រួលក្នុងការរកការងារធ្វើណាស់។ ខ្ញុំអស់សង្ឃឹមជាខ្លាំង ប៉ុន្តែក៏គ្មានជម្រើសអ្វីផ្សេងទេ។"*

*"អ្នកតបសំណួរត្រូវបានគេចាក់សោរឱ្យនៅក្នុងបន្ទប់មួយអស់រយៈពេលពីរឬបីថ្ងៃ ហើយគេប្រាប់នាងថាត្រូវតែការប្តីចិន បើមិនដូច្នោះទេត្រូវសងលុយដែលគេខំរៀបចំឱ្យមកដល់ប្រទេសចិននេះ។"*

ជាធម្មតាមេខ្យល់តែងតែប្រាប់បុរសចិនដែលស្វែងរកប្រពន្ធនោះពីការមកដល់របស់ស្ត្រីខ្មែរជាមុន តាមរយៈការផ្សព្វផ្សាយតាមអ៊ិនធឺណិត ឬតាមពាក្យសម្តីពីម្នាក់ទៅម្នាក់ទៀត។ ក្នុងរយៈពេលមួយខែដែលទិដ្ឋាការទេសចរណ៍នៅមានសុពលភាពនៅឡើយ មេខ្យល់ខិតខំស្វែងរកប្តីឱ្យទៅស្ត្រីដែលគេនាំមកដល់ប្រទេសចិននោះ ឱ្យបានរៀបការ បានចុះសំបុត្រអាពាហ៍ពិពាហ៍ និងបន្តទិដ្ឋាការឱ្យបានរស់នៅរយៈពេលវែង[40]។ ពេលវេលាខ្លីនៃសុពលភាពទិដ្ឋាការទេសចរណ៍ជាកត្តាមួយរួមចំណែកដល់ការដាក់សម្ពាធរបស់មេខ្យល់លើស្ត្រីឱ្យយល់ព្រមរៀបការ។

តម្លៃកូនក្រមុំខ្មែរត្រូវគេតថ្លៃគ្នាផ្អែកលើកត្តាចំនួនដូចជា រូបសម្ផស្ស និងថ្លៃរៀបចំធ្វើដំណើរ។ មានតម្លៃពី១០០០០$ ទៅដល់២០០០០$។[41] ភ្នាក់ងារនៅទីនោះជាអ្នកទទួលផលប្រយោជន៍ច្រើនជាងគេពីកម្រៃដែលខ្លួននាំនារីម្នាក់ឱ្យទៅរៀបការ។ ប្រាក់នៅសល់ត្រូវបង់ឱ្យភ្លាមបន្ទាប់ពីបានសំបុត្រអាពាហ៍ពិពាហ៍ និងបានទិដ្ឋាការស្នាក់នៅបន្ត។

---

[40]ជាទូទៅទិដ្ឋាការប្តីប្រពន្ធត្រូវគេចេញឱ្យមានរយៈពេលបីខែ អាចបន្តបានពីប្រាំមួយខែ ទៅមួយឆ្នាំ។

[41] មន្ត្រីជាច្រើននាក់បានលើកឡើងថាប្តីចិនទាំងនោះមានពេលមួយការប្រពន្ធគេឱ្យអ្នកដទៃបន្តឱ្យនរណាម្នាក់ទៀតបន្ទាប់ពីគេបានកូនពីនាងហើយ។ ដូច្នេះគេអាចរួចថ្លៃដែលគេបង់ឱ្យមេខ្យល់ពីពេលមុននោះ។ ការរៀបចំការបន្តទៀតនោះអាចគេធ្វើឡើងដោយខ្លួនឯងផ្ទាល់ ឬក៏តាមរយៈមេខ្យល់ចាត់ចែងឱ្យ។

មេខ្យល់ស្ទើរតែទាំងអស់យកលិខិតឆ្លងដែនរបស់ស្ត្រីទាំងនោះ និងប្រាក់កក់ទុកទាំងអស់ក្នុងអំឡុងពេលផ្លូវផ្គងនោះ។ ក្នុងអំឡុងពេលនោះ គេមិនឱ្យនាងដើរហើរដោយសេរីទេ មានស្ត្រីខ្លះត្រូវគេឱ្យទៅធ្វើការងារនៅចំការដំណាំ ឬមានគេដើរតាមពេលទៅផ្សារ ឬទៅផ្ទះគ្រួសារចិនដែលរកកូនក្រមុំសម្រាប់រៀបការ។ គេពុំមានលទ្ធភាពទូរស័ព្ទមកផ្ទះនៅកម្ពុជាទេ។ មេខ្យល់តែងតែប្រាប់ថាទូរស័ព្ទមកស្រុកខ្មែរអស់លុយច្រើនណាស់។ ក្នុងករណីដែលក្រុមគ្រួសារទូរស័ព្ទចូលមកមេខ្យល់ដើម្បីជួបកូនស្រីវិញនោះ មេខ្យល់តែងតែមិនចង់ឱ្យប្រាស្រ័យទាក់ទងគ្នាទេ បន្ទាប់ពីបាននិយាយជាមួយស្ត្រីពីរឬបីដងរួចហើយ។

ក្នុងករណីដែលនារីណាម្នាក់ប្រកែកមិនរៀបការទេនោះ មេខ្យល់តែងតែប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីបង្ខំឱ្យនាងយល់ព្រម។ ឧទាហរណ៍គេដកហូតលិខិតឆ្លងដែន គម្រាមប្តឹងឱ្យនគរបាលចិនចាប់ព្រោះនៅហួសកំណត់ទិដ្ឋាការ ឬបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញបាន ប៉ុន្តែត្រូវបង់ប្រាក់ចំណាយដែលគេនាំមកប្រទេសចិនឱ្យគេវិញ។ ប្រាក់នោះគេទារចាប់ពី ២០០០$ ដល់៨០០០$ ចំពោះការវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ ស្ត្រីទាំងអស់នោះមិនមានលទ្ធភាពរកប្រាក់មកសងគេវិញឡើយ ហើយក៏មិនហ៊ានប្រាប់ពីបញ្ហានេះដល់ក្រុមគ្រួសារឡើយ។ ដូច្នេះគេត្រូវបង្ខំចិត្តយល់ព្រមរៀបការ។

ស្ត្រីមួយចំនួនត្រូវមេខ្យល់ចាប់រំលោភ ឬគម្រាមចាប់រំលោភ ក្នុងបំណងបង្ខំឱ្យនាងយល់ព្រមរៀបការ។ ខាងក្រោមនេះជាឧទាហរណ៍មួយដកស្រង់ចេញពីចម្លើយផ្តល់ដោយអ្នកតបសំណួរម្នាក់៖

> *"មានយប់មួយនោះមេខ្យល់យកនារីម្នាក់ចេញទៅបាត់ទៅ។ ស្អែកឡើងនាងត្រឡប់មកវិញហើយក៏ប្រាប់នារីដទៃទៀតថានាងត្រូវគេប៉ងរំលោភ។ នារីពីរនាក់ក្រោយពីព្រឹត្តិការណ៍នោះក៏យល់ព្រមរៀបការជាមួយបុរសចិនក្នុងស្រុកនោះទៅ។ ស្ត្រីនេះនៅបានរហូតដល់ដប់ថ្ងៃ។ មានប្រុសៗមកមើលនាង មានអ្នកខ្លះពិការ នាងប្រកែករហូត។ ថ្ងៃមួយមេខ្យល់នោះក៏និយាយថាគេមិនសប្បាយចិត្តក្នុងការដែលនាងធ្វើបែបនោះឡើយ។ នាងបិទទ្វារមិនឱ្យមេខ្យល់នោះចូលបន្ទប់នាងទេ។ មេខ្យល់នោះក៏នាំនាងយកទៅប្រគល់ឱ្យមេខ្យល់ក្នុងស្រុកម្នាក*

*ទៀត។ នាងស្នាក់នៅផ្ទះមេខ្យល់នេះបានរយៈពេលប្រាំយប់ ក្រោយមកគេក៏យកនាងទៅផ្ទះសំណាក់តូចហើយថោកជាងមុន គេមិនឱ្យចំណីអាហារនាងបរិភោគគ្រប់គ្រាន់ឡើយ។ អាកាសធាតុត្រជាក់ខ្លាំងណាស់ហើយនាងគ្មានសម្លៀកបំពាក់គ្រប់គ្រាន់សម្រាប់ទប់ទល់នឹងភាពត្រជាក់នេះទេ រីឯមេខ្យល់ក៏មិនខ្វល់ខ្វាយពីនាងដែរ។ បុរសៗបន្តមកមើលនាងដដែល។ មានបុរសម្នាក់ដែលមើលទៅសមរម្យហើយគេប្រាប់នាងថាគេធ្វើការងារបានប្រាក់ខែប្រហែល ១៥០០$ តែនាងនៅតែមិនព្រម។ នាងបារម្ភខ្លាចមេខ្យល់មកចាប់រំលោភនាង ដូច្នេះនាងមិនបើកទ្វារឱ្យមេខ្យល់នោះចូលឡើយទោះបីគេយកម្ហូបអាហារឱ្យនាងក្តី។ មានយប់មួយមេខ្យល់ព្យាយាមចាប់ឱបនាងតែនាងស្រែកហើយគេក៏ថយចេញបាត់ទៅ។ នាងភ័យខ្លាចជាខ្លាំង។ មេខ្យល់ចេះតែបន្តនាំប្រុសៗមកមើលនាងមានអ្នកខ្លះ "មិនគ្រប់ទឹក" ក៏មានដែរ។ នាងក៏សម្រេចចិត្តថានឹងយល់ព្រមរៀបការជាមួយបុរសម្នាក់ដែលមានសភាពធម្មតា។ ភ្នាក់ងារនោះធុញទ្រាន់ជាមួយនាងជាខ្លាំងក៏ទាក់ទងមកមេខ្យល់នៅឯភ្នំពេញតាមទូរស័ព្ទ។ នាងប្រាប់ទៅកាន់មេខ្យល់នៅភ្នំពេញថានាងយល់ព្រមសងប្រាក់២០០០$ដែលគេចំណាយឱ្យនាងមកទីនេះតាមរយៈម្តាយនាងនៅឯស្រុកកំណើត ហើយនាងមិននៅប្រទេសចិនទេ។ ខណៈដែលនាងកំពុងនិយាយទូរស័ព្ទក៏ដាច់មិនអាចទាក់ទងគ្នាបានទៀតឡើយ។ នាងក្រោយមកក៏សម្រេចចិត្តយល់ព្រមរៀបការជាមួយបុរសម្នាក់ដែលអះអាងថាខ្លួនមានការងារធ្វើបានប្រាក់ខែ១៥០០$នោះទៅ។"*

បុរសៗដែលស្វែងរកប្រពន្ធនោះមានអាយុរវាងពី២០ឆ្នាំ ទៅដល់៣០ឆ្នាំ ជួនកាលជាបុរសពោះម៉ាយមានកូនក្នុងបន្ទុកស្រាប់។ គេធ្វើស្រែចំការ ឬធ្វើការងារក្នុងកន្លែងតូចតាចដូចជាជាងភ្លើង ជាងជួសជុលទូរទស្សន៍ ឬកម្មករសំណង់ជាដើម។ គេមិនមានការងារពេញម៉ោងធ្វើឡើយ។ ដូចគ្នានឹងករណីខាងលើនេះមានស្ត្រីមួយចំនួនបានប្រាប់ថាមេខ្យល់បានណែនាំពួកគេឱ្យរៀបការជាមួយបុរសដែលមិនមានកាយសម្បទា ឬសតិគ្រប់គ្រាន់ផងដែរ។

## ការចុះសំបុត្រអាពាហ៍ពិពាហ៍

បញ្ញត្តិស្តីពីការចុះសំបុត្រអាពាហ៍ពិពាហ៍របស់ចិនទាមទារឱ្យសម៉ីខ្លួនទាំងពីរយល់ព្រមក្នុងការរៀបការនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីជាជនបរទេសត្រូវធ្វើនៅ

មជ្ឈមណ្ឌលស៊ុំកូនបរទេស និងចុះបញ្ជីអាពាហ៍ពិពាហ៍ខេត្ត ចំណុះឱ្យមន្ទីរកិច្ចការស៊ីវិល។ មន្ត្រីសួរទៅកាន់ភាគីទាំងពីរដើម្បីបញ្ជាក់ពីការស្នើសុំសំបុត្រអាពាហ៍ពិពាហ៍ដោយឆន្ទៈ និងគ្មានការបង្ខិតបង្ខំ។ ប៉ុន្តែមជ្ឈមណ្ឌលស៊ុំកូនបរទេស និងចុះបញ្ជីអាពាហ៍ពិពាហ៍ខេត្តជាច្រើនពុំមានមន្ត្រីចេះនិយាយភាសាខ្មែរទេ។ តែទោះបីជាមានអ្នកចេះនិយាយភាសាខ្មែរក៏ដោយក៏មានកត្តាមួយចំនួនរារាំងមិនឱ្យស្ត្រីខ្មែរបង្ហាញពីឆន្ទៈពិតរបស់ខ្លួនដែរ។ ឧទាហរណ៍មន្ត្រីម្នាក់នៅមជ្ឈមណ្ឌលស៊ុំកូនបរទេស និងចុះបញ្ជីអាពាហ៍ពិពាហ៍ខេត្ត ខេត្តជាំងស៊ីបានប្រាប់អ្នកសិក្សាស្រាវជ្រាវថា៖ *"អណត្តិរបស់មជ្ឈមណ្ឌលគឺគ្រាន់តែសម្រាប់ដោះស្រាយការចេញសំបុត្រអាពាហ៍ពិពាហ៍ឱ្យសម៉ីខ្លួនទាំងពីរនាក់កាលណាគេមានឯកសារគ្រប់គ្រាន់ហើយ។ គេមិនអាចសួរពីព័ត៌មានផ្ទាល់ខ្លួនដូចជាថាតើអ្នកទាំងពីរជួបគ្នាយ៉ាងដូចម្ដេចឡើយ។"*[42]

ដោយសារចំនួនស្ត្រីខ្មែរកើនឡើងក្នុងខេត្តនេះ មជ្ឈមណ្ឌលស៊ុំកូនបរទេស និងចុះបញ្ជីអាពាហ៍ពិពាហ៍ខេត្តជាំងស៊ីមានអ្នកបកប្រែភាសាខ្មែរ។ មួយផ្នែកវាជាការខិតខំបង្ការការរៀបការដោយបង្ខំមិនឱ្យកើតមានឡើង។ យោងតាមមន្ត្រីមជ្ឈមណ្ឌលស៊ុំកូនបរទេស និងចុះបញ្ជីអាពាហ៍ពិពាហ៍ខេត្តជាំងស៊ីថា *"មានវិធានការថ្មីៗមួយចំនួនត្រូវគេយកមកប្រើប្រាស់ក្នុងឆ្នាំនេះដើម្បីបង្ការការរៀបការដោយបង្ខំ និងកូនក្រមុំបោកប្រាស់។ វិធានការមួយក្នុងចំណោមនោះគឺការពិនិត្យលើឆន្ទៈនៃការរៀបការរបស់បុគ្គលទាំងពីរនាក់តាមរយៈអ្នកបកប្រែភាសានៅឯការិយាល័យចុះសំបុត្រអាពាហ៍ពិពាហ៍។"*

ទោះបីជាមានអ្នកបកប្រែភាសាខ្មែរក៏ដោយ អ្នកតបសំណួរក្នុងការសិក្សាស្រាវជ្រាវនេះបញ្ជាក់ថាវត្តមានរបស់អ្នកបកប្រែភាសាខ្មែរមិនបានបញ្ជាក់ពីឆន្ទៈពិតប្រាកដនៃការរៀបការរបស់ពួកគេឡើយ៖

> *"អ្នកបកប្រែភាសាជាស្ត្រីខ្មែរម្នាក់ដែលបានរៀបការជាមួយប្ដីចិន ប្រាប់ខ្ញុំថាការប្ដីចិននៅស្រុកនេះមិនល្អទេ។ គាត់ដឹងថាខ្ញុំត្រូវគេបង្ខំឱ្យរៀបការហើយ។ មុនពេលទៅការិយាល័យអគ្រានុកូលដ្ឋាននោះមេខ្យល់គម្រាមខ្ញុំថាបើថា "មិនយល់ព្រម"*

---

[42] យោងតាមមន្ត្រីមជ្ឈមណ្ឌលស៊ុំកូនបរទេស និងចុះបញ្ជីអាពាហ៍ពិពាហ៍បង្ហាញថាជូនកាលពួកគេសួរសំណួរថាតើភាគីទាំងពីរស្គាល់គ្នាដោយរបៀបណា ប៉ុន្តែចម្លើយចំពោះសំណួរបែបនេះជាទូទៅគឺគេឆ្លើយថា បងប្អូនសាច់ញាតិជាអ្នកណែនាំ។ គួរកត់សំគាល់ផងដែរថា រយៈពេលពីរបីឆ្នាំកន្លងទៅ ស្ត្រីកម្ពុជាពីរនាក់និយាយថាពួកគេត្រូវស្ថិតនៅក្រោមការគម្រាមកំហែងនៅពេលនាំទៅមជ្ឈមណ្ឌល។ ជាការឆ្លើយតបនឹងស្ថានការណ៍នេះគឺពួកគេទទួលបានការការពារនិងការគាំទ្រ។

*នោះគេឱ្យខ្ញុំសងលុយដែលគេនាំមក និងស្នាក់នៅប្រទេសចិនវិញទាំងអស់។ មានមនុស្សប្រហែល១៥នាក់នៅការិយាល័យអត្រានុកូលដ្ឋាននាថ្ងៃនោះ។ អ្នកបកប្រែភាសានោះចេះនិយាយភាសាខ្មែរ ភាសាចិន និងភាសាវៀតណាម។ គាត់មិនបានរាយការណ៍ពីករណីខ្ញុំទៅកាន់មន្ត្រីនោះទេ គាត់ធ្វើតែតាមនិតិវិធីធម្មតាដោយបោះត្រា និងចុះហត្ថលេខាលើសំបុត្រនោះតែប៉ុណ្ណោះ។"*

ក្នុងករណីខ្លះទៀតភ្នាក់ងារជ្រើសរើសគូស្រករជាអ្នកជួលអ្នកបកប្រែភាសា ឧទាហរណ៍៖

*"ការិយាល័យអត្រានុកូលដ្ឋាននោះមានមនុស្សច្រើនណាស់។ មានអ្នកបកប្រែម្នាក់នៅទីនោះ គេសួរខ្ញុំថាតើខ្ញុំរៀបការនេះដោយឆន្ទៈរបស់ខ្ញុំទេ។ ប៉ុន្តែមេខ្យល់ជាអ្នកជួលគេឱ្យទៅបកប្រែភាសា។ មេខ្យល់ព្យាយាមគម្រាមខ្ញុំឱ្យសងលុយគេវិញប្រសិនបើខ្ញុំបដិសេធន៍មិនផ្តិតមេដៃលើឯកសារទេនោះ។"*

ករណីមួយចំនួនទៀតអ្នកបកប្រែជាប់សាច់ញាតិជាមួយភ្នាក់ងាររៀបអាពាហ៍ពិពាហ៍៖

*"គេនាំខ្ញុំទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅកន្លែងឆ្ងាយណាស់។ មន្ត្រីអត្រានុកូលដ្ឋានសួរខ្ញុំថាតើខ្ញុំចង់រៀបការជាមួយបុរសនោះដែរឬទេ។ មុនដំបូងខ្ញុំថាគេបង្ខំខ្ញុំទេ។ អ្នកបកប្រែភាសានោះប្រាប់ខ្ញុំវិញថាបើសិនខ្ញុំថាមិនព្រមទេនោះខ្ញុំមិនអាចវិលត្រឡប់មកស្រុកកំណើតវិញឡើយ [ស្ត្រីនោះក៏ 'យល់ព្រម'រៀបការ]។"*

តាមច្បាប់ចិនចែងថាដើម្បីចុះអាពាហ៍ពិពាហ៍រវាងជនជាតិចិនជាមួយជនបរទេសបានដរាបណាជនបរទេសនោះមានលិខិតបញ្ជាក់ភាពនៅលីវ វិញ្ញាបនបត្រពិនិត្យសុខភាព និងលិខិតឆ្លងដែនមានទិដ្ឋាការនៅមានសុពលភាព។ ប៉ុន្តែក្នុងពេលថ្មីៗនេះមានការបារម្ភពីភាពស្របច្បាប់នៅឯកសារទាំងនោះ។ តាមការលើកឡើងរបស់មន្ត្រីមជ្ឈមណ្ឌលស្នុំកូនបរទេស និងចុះបញ្ជីអាពាហ៍ពិពាហ៍ខេត្តជាំងស៊ីថា៖

*"ចាប់តាំងពីត្រីមាសទីបីក្នុងឆ្នាំ២០១៥មក មានការសង្ស័យលើឯកសារពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ហើយយើងក៏ស៊ើបអង្កេតលើឯកសារទាំងនោះ។ លិខិតបញ្ជាក់ពីភាពនៅលីវរបស់កូនក្រមុំបរទេសក៏ត្រូវផ្ញើឱ្យ*

*ស្ថានកុងស៊ុល ឬស្ថានទូតរបស់ខ្លួនបញ្ជាក់ពីភាពស្របច្បាប់ក្នុងគោលបំណងចាត់វិធានការបំបាត់ការធ្វើឯកសារក្លែងក្លាយ។*[43]

តាមសេចក្តីរាយការណ៍ លិខិតបញ្ជាក់ភាពនៅលីវចេញដោយស្ថានកុងស៊ុល ឬស្ថានឯកអគ្គរាជទូតកម្ពុជានៅក្នុងប្រទេសចិនមានតម្លៃខ្ពស់ណាស់ ដោយពុំត្រូវការការពិនិត្យបញ្ជាក់ផ្ទៀងផ្ទាត់ឡើយ។[44] ដោយសារការធ្វើឯកសារមានតម្លៃខ្ពស់ គួបផ្សំជាមួយនឹងរាល់ការចំណាយនានាផងនោះ វាក៏ក្លាយជាបំណុលដ៏ធ្ងន់ធ្ងរដល់ស្ត្រីខ្មែរដែលត្រូវសងគេវិញ ប្រសិនបើនាងបដិសេធន៍ការរៀបការ ដូច្នេះ នាងត្រូវទទួលយល់ព្រមរៀបការនោះទាំងបង្ខំ។ ការចេញលិខិតបញ្ជាក់ភាពនៅលីវនេះដោយពុំបានពិនិត្យឱ្យបានល្អិតល្អន់ វាបង្កជាបញ្ហាចំពោះស្ត្រីដែលរៀបការរួចហើយ រៀបការបានម្តងទៀតនៅប្រទេសចិន។ ប្រសិនបើមានមានការរកឃើញបញ្ហានេះថាអាចជា សូចនាករ (សញ្ញា) នៃការរៀបការដោយបង្ខំជា នោះប្រហែលមានការស៊ើបអង្កេត ។

[43] ការត្រួតពិនិត្យឯកសារត្រូវបានចាប់ផ្តើម ដោយសារតែមានការពិគ្រោះយោបល់រវាងមន្ត្រីចិននិងមន្ត្រីការទូតកម្ពុជា ដើម្បីឆ្លើយតបនឹងការក្លែងបន្លំឯកសារនិងការរៀបការដោយបង្ខំ ។

[44] ករណីមួយចំនួនអាចប្រើប្រាស់ជាភស្តុតាងបានថា លិខិតបញ្ជាក់ភាពនៅលីវ ត្រូវកុងស៊ុល និងស្ថានទូតកម្ពុជាចេញឱ្យដោយពុំចាំបាច់មានវត្តមានស្ត្រីដែលជាសម៉ីខ្លួនផ្ទាល់ឡើយ។ លើសពីនេះទៀតឯកសារនេះមិនបានបញ្ជាក់ថាការចេញលិខិតនេះទៅប្រើប្រាស់ក្នុងគោលបំណងអ្វីនោះទេ។ ខុសប្លែកពីប្រទេសដទៃទៀត ឧ. ប្រទេសវៀតណាមជាដើម។

# របកគំហើញ៖ ការរត់គេចខ្លួន និងការវិលត្រឡប់មកវិញ

## ការរៀបចំផែនការរត់គេច និងការត្រឡប់មកវិញ

នៅពេលរៀបចំផែនការរត់គេច អ្នកតបសំណួរគិតពីកត្តាមួយចំនួនរួមមាន ឯកសារកំណត់អត្តសញ្ញាណ ប្រាក់ និងពេលវេលា។ ជាធម្មតាប្ដីចិនជាអ្នករក្សាទុកលិខិតឆ្លងដែនក្រោយពេលរៀបការរួច។ ធ្វើបែបនេះគេអាចគ្រប់គ្រងរាល់ការធ្វើដំណើរជិតឆ្ងាយរបស់ប្រពន្ធគេបាន។ ស្ត្រីមួយចំនួនមានច្បាប់ចម្លងលិខិតឆ្លងដែនរក្សាទុក។ ដរាបណាមានឯកសារស្រេបច្បាប់ទាំងនោះទើបគេលក់សំបុត្ររថភ្លើង និងអនុញ្ញាតឱ្យចូលស្នាក់នៅសណ្ឋាគារបាន។ អ្នកតបសំណួរខ្លះមានជនជាតិចិនស្ម័គ្រចិត្តប្រើអត្តសញ្ញាណប័ណ្ណរបស់គេជួយជួលបន្ទប់សណ្ឋាគារ ឬជួយទិញសំបុត្ររថភ្លើងឱ្យ។ នៅពេលដែលមកដល់កុងស៊ុល ឬស្ថានទូតកម្ពុជាគេឆែករកមើលសាវតាហើយគេនឹងចេញឯកសារថ្មីមួយឱ្យ សម្រាប់ធ្វើដំណើរ។

អ្នកតបសំណួរចាំបាច់ត្រូវតែមានទិដ្ឋាការដែលមានសុពលភាពក្នុងការចេញពីប្រទេសចិន។ អនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងការចេញចូល អ្នកដែលស្នាក់នៅលើសកំណត់ត្រូវឃុំខ្លួន ឬទទួលផាកការពិន័យ។ ស្ត្រីម្នាក់ដែលស្នាក់នៅលើសកំណត់ពេលនៃទិដ្ឋាការបានរៀបរាប់ថា នាងត្រូវគេពិន័យជាប្រាក់៥០០០យ៉ាន់ ឬប្រហែល៧៨០$ដើម្បីទទួលបានលិខិតបើកផ្លូវ។ នៅពេលដែលស្នាក់នៅកុងស៊ុលកម្ពុជាក្នុងខេត្តក្វាងចូវ ម្ដាយឪពុកនាងលក់អស់គោក្របីដើម្បីប្រមូលប្រាក់ឱ្យនាង។ សម្រាប់អ្នកដែលជាជនរងគ្រោះដោយសារការរៀបការដោយបង្ខំ មានទិដ្ឋាការនៅសុពលភាពប៉ុន្តែត្រូវប្ដីយកលិខិតឆ្លងដែនទុក ស្ថានទូតកម្ពុជានឹងសម្របសម្រួលជាមួយក្រសួងសន្តិសុខសាធារណៈរបស់ចិនដើម្បីកំណត់ថានៈរបស់នាង និងជួយធ្វើមាតុភូមិនិវត្តមកកាន់មាតុប្រទេសវិញ។ អ្នកតបសំណួរមួយចំនួនបានប្រាប់ថាអង្គការអន្តរជាតិជាអ្នកចេញថ្លៃស្នាក់នៅ និងថ្លៃសំបុត្រយន្តហោះដើម្បីឱ្យវិលត្រឡប់មកស្រុកកំណើតវិញ។ ជម្រកសុវត្ថិភាពរដ្ឋាភិបាលក្នុងក្រុងប៉េកាំងចាប់ផ្ដើមផ្ដល់កន្លែងស្នាក់នៅបណ្ដោះអាសន្នដល់ស្ត្រីខ្មែរក្នុងពេលរង់ចាំមាតុភូមិនិវត្តវិញ តាំងពីខែមីនា ឆ្នាំ២០១៥ម្លេះ។

លើសពីនេះទៀត ធនធានថវិកាជាតម្រូវការចាំបាច់មួយសម្រាប់ចំណាយលើការធ្វើដំណើរ ការហូបចុក និងការស្នាក់នៅ។ អ្នកតបសំណួរខ្លះបាននិយាយថាគេសន្សំលុយពីប្ដី

ឱ្យចាយ និងសាច់ថ្លៃឱ្យទៅផ្សារបានខ្លះ។ ស្ត្រីម្នាក់ប្រាប់ថានាងយកលុយពីផ្ទះប្តីនាងបាន ៨០០០យ៉ាន់ ប្រហែល១២៥០$ នៅពេលនាងរត់ចេញ។[45] អ្នកតបសម្ភាសដែលជួយដោយ កុងស៊ុល ឬស្ថានទូតកម្ពុជា ឬអង្គការមិនមែនរដ្ឋាភិបាល បានប្រាប់ថា នាងត្រូវគេផ្តល់ម្ហូប អាហារ និងកន្លែងស្នាក់នៅ។ អ្នកតបសំណួរដែលត្រូវការប្រាក់សម្រាប់ទិញសំបុត្រយន្តហោះ មកផ្ទះវិញ តែងតែទូរស័ព្ទមកគ្រួសារ ហើយរង់ចាំរហូតដល់បានលុយផ្ញើទៅមន្ត្រីកុងស៊ុលកម្ពុ ជានៅឯប្រទេសចិន។[46]

ពេលវេលាក៏ជាកត្តាសំខាន់មួយដើម្បីឱ្យការរត់គេចបានសម្រេច។ ពីរឬបីខែដំបូងជា ដំណាក់កាលមិនទាន់មានស្ថេរភាពសម្រាប់ប្តីប្រពន្ធនោះដោយសារមូលហេតុមួយចំនួនដូច ជារបៀបរបបរស់នៅខុសគ្នា ឬភាសាដើម្បីប្រាស្រ័យទាក់ទងគ្នា និងការជ្រើសរើសគូដោយ មិនត្រូវតាមការរំពឹងទុក និងជីវិតរស់នៅក្នុងប្រទេសចិន។ ប្តីចិនតែងតែព្រួយបារម្ភថាប្រពន្ធ ដែលខ្លួនរៀបការមកអាចលែងលះ ឬរត់ចោលពួកគេ។ ប្រពន្ធរត់ចោលគឺជាការបាត់បង់យ៉ាង ធ្ងន់ធ្ងររបស់បុរសនោះ ព្រោះថាគេបានចំណាយប្រាក់ជាច្រើនខណៈដែលខ្លួនមានជីវភាព លំបាកនៅជនបទផងនោះ។[47] ដោយសារហេតុនេះហើយ បានជាប្តីចិនតែងតែឃ្លាំមើលនិង តាមដានប្រពន្ធជានិច្ច ដកហូតយកលិខិតឆ្លងដែនទុក និងមិនឱ្យទុកលុយ ។ ក្រោយពីរៀបការ បានប្រាំមួយឬប្រាំពីរខែមក ឬក៏ពេលប្រពន្ធមានផ្ទៃពោះហើយការឃ្លាំមើល និងការតាមដាន ហាក់ដូចជាមិនសូវតឹងតែងដូចពេលមុនឡើយ។ ដូច្នេះវាជាឱកាសឱ្យនាងរកផ្លូវរត់ចេញបាន។

ខាងក្រោមនេះជាការរៀបរាប់របស់អ្នកតបសំណួរ៖

*"ស្ថានភាពកាន់តែអាក្រក់ទៅៗ ខ្ញុំពិបាកណាស់ ហើយខ្ញុំគិតថារត់។ ខ្ញុំបាន ទាក់ទងទៅកាន់មន្ត្រីកុងស៊ុលដើម្បីឱ្យជួយ។ គាត់ប្រាប់ថាគាត់មិនអាចជួយពី ចម្ងាយបានទេ ទាល់តែខ្ញុំមកបង្ហាញខ្លួននៅការិយាល័យគាត់ទើបអាចរកវិធីជួយ*

---

[45] គួរកត់សម្គាល់ផងដែរថានគរបាលមិនបានចាត់វិធានការចំពោះស្ត្រីណាម្នាក់នៅពេលដែលប្តីចិនបានរាយការណ៍ថានាង ជាសហម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យ។

[46] អ្នកតបសំណួរមួយចំនួនត្រូវអង្គការសង្គមស៊ីវិល ឬអង្គការអន្តរជាតិចេញថ្លៃសំបុត្រឱ្យ។

[47] មានភស្តុតាងបញ្ជាក់ថាប្រពន្ធខ្មែរដែលព្យាយាមលែងលះនោះត្រូវប្តីចិន ឬភ្នាក់ងាររៀបអាពាហ៍ពិពាហ៍គម្រាមឱ្យសងលុយ គេវិញ។ ភ្នាក់ងារតែងចូលជួយដោះស្រាយប្រសិនបើប្តីប្រពន្ធមានការឈ្លោះទាស់ទែងគ្នា។ សូមបញ្ជាក់ផងដែរថាក្នុងការ ផ្សព្វផ្សាយឃោសនាតាមអ៊ិនធឺណិតសេវារៀបអាពាហ៍ពិពាហ៍មានធានាថាយកប្រពន្ធថ្មីមកជំនួសវិញដោយមិនគិតថ្លៃពេល ណាប្រពន្ធម្នាក់រត់ចោលក្នុងអំឡុងពេលជាក់លាក់ណាមួយបន្ទាប់ពីការរៀបការ។

*បាន។ ខ្ញុំក៏រៀបចំផែនការរត់។ ខ្ញុំព្យាយាមធ្វើល្អដាក់គ្រួសារ ហើយធ្វើឱ្យគេជឿទុកចិត្តជាថ្មីម្តងទៀត [នាងធ្លាប់រត់ម្តងកាលពីមុន]។ នៅពេលគេមិនសូវប្រយ័ត្ន ខ្ញុំក៏លួចចេញតាមក្រោយផ្ទះ រត់រកផ្លូវសំដៅទៅចំណតរថយន្តក្រុងហើយធ្វើដំណើរទៅកុងស៊ុលតែម្តង។"*

ស្ត្រីម្នាក់ទៀតបានប្រាប់ថានាងត្រូវទ្រាំនៅអស់ពេល៨ខែទើបនាងអាចរត់រួច ព្រោះថាដំបូងមានការលំបាកក្នុងការនិយាយភាសា។ នាងទទួលបានព័ត៌មានអំពីស្ថានកុងស៊ុលនៅខេត្តក្វាងចូវ នាងក៏បានទូរស័ព្ទសុំយោបល់ពីមន្ត្រីនៅទីនោះពីការចង់ចាកចេញរបស់នាង។ គេថាគេមិនអាចជួយនាងបានទេ តែនាងអាចទៅឱ្យស្ថានទូតនៅប៉េកាំងជួយបាន។ នៅថ្ងៃចូលឆ្នាំថ្មីប្រពៃណីចិនបងប្អូនខាងប្តីបានឱ្យលុយនាង។ នាងសន្សំបាន១០០០យ៉ាន់ ប្រហែល ១៥៦$ ហើយលាក់លុយនោះ។ ពេលនាងរត់ នាងធ្វើដំណើរយ៉ាងវែងឆ្ងាយតែម្នាក់ឯងអស់ រយៈពេលពីរយប់ទើបបានដល់ស្ថានទូត។

ស្ត្រីមួយចំនួនប្រាប់ថាគេព្យាយាមរត់គេចជាច្រើនលើកមកហើយទំរាំរត់រួច។ អ្នកភូមិក្នុងសហគមន៍របស់ខ្លួនមិនសូវបានជួយជាជុំកំភួនទេ ដោយសារពួកគេជាសាច់ញាតិរបស់គ្រួសារប្តី។ ពេលដែលអ្នកភូមិសង្ស័យថាមានស្ត្រីលួចរត់ គេអាចទៅប្រាប់ប្តីឬឱ្យក្រុមគ្រួសារទៅចាំចាប់យកមកវិញនៅតាមចំណតរថយន្តក្រុង ឬស្ថានីយរថភ្លើង។

ដូចដែលលើកឡើងខាងលើ ការទៅដល់កុងស៊ុល ឬ ស្ថានទូតតែងតែជាការងារលំបាកបំផុត។ អ្នកតបសំណួរថាគេតែងតែដើរទៅទីប្រជុំជនតូចក្បែរភូមិដែលគេរស់នៅដើម្បីឡើងជិះរថយន្តក្រុងទៅកាន់ទីប្រជុំជនធំមួយទៀត ហើយបន្តដំណើរទៅកាន់ទីរួមខេត្តដើម្បីជិះរថភ្លើង ឬ រថយន្តក្រុងទៅ កុងស៊ុលនៅទីក្រុងសៀងហៃ ឬក្វាងចូវ ឬទៅស្ថានទូតនៅទីក្រុងប៉េកាំង។

## បណ្តាញសង្គម និងទូរស័ព្ទចល័ត

នៅជនបទប្រទេសចិនមានការលក់ដូរ ការតាំងពិព័រណ៍រៀងរាល់សប្តាហ៍។ នេះជាឱកាសល្អសម្រាប់ស្ត្រីខ្មែរទៅជួបគ្នា ជួយរំលែកទុក្ខគ្នា ចែករំលែកព័ត៌មានគ្នា និងស្វែងរក ជំនួយ។ ភស្តុតាងជាក់ស្តែងបានបញ្ជាក់ថាបណ្តាញក្រៅប្រព័ន្ធបែបនេះតែងតែមាននៅក្នុងសហគមន៍ដែលមានស្ត្រីខ្មែររស់នៅ។ លើសពីនេះទៀតមានស្ត្រីខ្លះរស់នៅភូមិ ឬខេត្តដទៃក្តីតែងតែ

ទូរស័ព្ទរកគ្នាជានិច្ច នេះជាមធ្យោបាយចាំបាច់មួយដើម្បីឱ្យពួកគេរៀបចំរត់គេចបាន។ កិច្ចសម្ភាសន៍ខាងក្រោមនេះបង្ហាញជាឧទាហរណ៍ស្រាប់។

*"ក.ល ជាស្ត្រីខ្មែរម្នាក់មានបំណងចង់រត់ចេញពីជីវិតរៀបការដោយបង្ខំជាមួយបុរសចិនម្នាក់។ មិត្តភក្តិរបស់នាងម្នាក់ឈ្មោះ វ.ល ក៏មានប្តីចិន គាំទ្រឱ្យ ក.ល រត់ បានណែនាំ ក.លឱ្យទៅស្គាល់ស្ត្រីខ្មែរមានប្តីចិនម្នាក់ទៀតមានផ្ទៃពោះប្រាំមួយខែ ឈ្មោះ ស.រ ដែលមានបំណងរត់គេចដែរ។ បន្ទាប់ពី វ.ល ណែនាំអ្នកទាំងពីរឱ្យទាក់ទងគ្នាហើយ ក.ល និង ស.រ ក៏រៀបចំគម្រោងការរត់ជាមួយគ្នា។ ក.ល ស្គាល់លេខទូរស័ព្ទនារីខ្មែរម្នាក់ទៀតឈ្មោះ ស.ហ តាមរយៈបណ្តាញស្ត្រីខ្មែររស់នៅទីនោះ។ ពេល ក.ល ទូរស័ព្ទមក ស.ហ កំពុងស្ថិតនៅស្ថានកុងស៊ុលសម្ភាសជាមួយអ្នកសិក្សាស្រាវជ្រាវនេះ។ ស.ហ ឱ្យលេខទំនាក់ទំនងរបស់អ្នកស្រាវជ្រាវទៅ ក.ល ហើយនាងក៏ទាក់ទងមកដើម្បីឱ្យជួយនាងផង។ អ្នកសិក្សាស្រាវជ្រាវក៏បានឱ្យនាងទាក់ទងទៅកាន់អង្គការសង្គមស៊ីវិលដើម្បីជួយផ្តល់កន្លែងស្នាក់នៅ ការធ្វើដំណើរ និងជំនួយផ្នែកច្បាប់នានា។ ក្រោយមកពួកគេក៏អាចរត់គេច ហើយវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ។"*

មានអ្នកតបសំណួរផ្សេងទៀតក៏បានលើកឡើងពីសារៈសំខាន់របស់ទូរស័ព្ទដៃធ្វើឱ្យពួកគេរត់រួចផងដែរ។ ឧទាហរណ៍ ស្ត្រីម្នាក់ទាក់ទងមកគ្រួសារនៅប្រទេសកម្ពុជាដោយទូរស័ព្ទដៃរបស់ខ្លួន ហើយសមាជិកគ្រួសារទៅទាក់ទងអង្គការមិនមែនរដ្ឋាភិបាលឱ្យជួយបន្តទៀត។ អង្គការមិនមែនរដ្ឋាភិបាលនោះក៏បានទាក់ទងជាមួយក្រុមអ្នកស្ម័គ្រចិត្តចិន។ បន្ទាប់មកក្រុមអ្នកស្ម័គ្រចិត្តទាក់ទងស្ត្រីនោះតាមរយៈទូរស័ព្ទដៃហើយជួយឱ្យនាងរត់បានសម្រេច។ អ្នកតបសំណួរនៅប្រទេសចិនម្នាក់ទៀតត្រូវជួយសង្គ្រោះដោយអង្គការសង្គមស៊ីវិលចិន បន្ទាប់ពីគេស្គាល់កន្លែងនាងរស់នៅតាមរយៈសារដែលនាងផ្ញើចេញពីទូរស័ព្ទនាង។ មានស្ត្រីម្នាក់ទៀតទទួលបានការជួយសង្គ្រោះ ក្រោយពីអ្នកស្ម័គ្រចិត្តចិនទទួលដំណឹងតាមរយៈប្រព័ន្ធទូស័ព្ទបន្ទាន់នៅកម្ពុជា។ អ្នកតបសម្ភាសម្នាក់ទាក់ទងទៅបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ជារឿយៗតាមរយៈទូរស័ព្ទដៃ ខណៈពេលដែលនាងធ្វើដំណើរទៅទីក្រុងប៉េកាំងដើម្បីរត់គេច។

## នគរបាល

មានអ្នកតបសំណួរមួយចំនួនប៉ុណ្ណោះដែលចូលខ្លួនទៅកន្លែងនគរបាលក្នុងមូលដ្ឋាននោះដើម្បីស្វែងរកជំនួយ។ ក្នុងករណីដែលមានអ្នកមករកនគរបាលឱ្យជួយនោះ នគរបាលតែងតែគិតថាវាជាវិវាទក្នុងគ្រួសារហើយការរៀបការសោតទៀតក៏ស្របច្បាប់ ។ ជួនកាលនគរបាល ក៏ស្គាល់ក្រុមគ្រួសាររបស់ប្តីនាង ដូច្នេះពួកគេក៏មិនធ្វើអន្តរាគមន៍ទេ។ ការលំបាកមួយទៀតរបស់ស្ត្រីក្នុងការស្វែងរកជំនួយនោះគឺភាសា។ នគរបាលមូលដ្ឋានតែងតែប្រាប់ប្តីឱ្យដឹង ហើយឱ្យប្រពន្ធត្រឡប់ទៅផ្ទះវិញតែប៉ុណ្ណោះ។

មានស្ត្រីមួយចំនួនជួបនគរបាលដោយចៃដន្យ ហើយត្រូវបានបានឃាត់នៅចំណតរថយន្តក្រុង ឬស្ថានីយរថភ្លើង។ បន្ទាប់ពីឃាត់ខ្លួន គេក៏នាំនាងទៅកាន់ប៉ុស្តិ៍នគរបាលដើម្បីសាកសួរ ហើយគេបន្តនីតិវិធីរបស់គេតាមយុត្តាធិការតទៅទៀត។ ប្រសិនបើស្ត្រីនោះត្រូវគេឃុំខ្លួននៅជិតផ្ទះរបស់ប្តី នាងត្រូវគេបញ្ជូនឱ្យទៅផ្ទះនោះវិញ។[48]

ប្រសិនបើនគរបាលឃាត់ខ្លួននៅឆ្ងាយពីកន្លែងស្នាក់នៅនោះគេនឹងឃុំទុកហើយទូរស័ព្ទទៅសួរប្តីដើម្បីបញ្ជាក់ថាគេពិតជាប្តីប្រពន្ធនឹងគ្នា ហើយទាមទារឱ្យយកលិខិតឆ្លងដែននិងឯកសារពាក់ព័ន្ធមកបង្ហាញ។ ក្នុងពេលនោះអ្នកតបសំណួរស្នាក់នៅប៉ុស្តិ៍ ឬមណ្ឌលណាមួយ តាមនីតិវិធីនេះគេអាចកំណត់អត្តសញ្ញាណថាជាជនរងគ្រោះពីការរៀបការដោយបង្ខំជាមួយស្ថានកុងស៊ុល ឬស្ថានទូតកម្ពុជាដែលនៅជិតបំផុត។ ខាងក្រោមនេះជាឧទាហរណ៍បញ្ជាក់៖

> *"ខ្ញុំត្រូវនគរបាលចាប់ដាក់ប៉ុស្តិ៍ក្រោយពីខ្ញុំរត់គេចចេញពីប្តី។ ខ្ញុំបង្ហាញលិខិត ឆ្លងដែនដែលបានថតចម្លងទុក ឱ្យទៅមន្ត្រីនៅទីនោះ។ ដោយសារពេលនោះយប់*

[48] អាជ្ញាធរចិននិយាយថា មន្ត្រីជួរមុខរបស់ខ្លួនមានការលំបាកក្នុងការបែងចែកភាពខុសគ្នារវាងការរៀបការដោយបង្ខំនិងការរៀបការដែលបោកបញ្ឆោតយកលុយពីបុរសចិន ដែលក្នុងករណីបោកបញ្ឆោតគឺស្ត្រីមករៀបការជាមួយនឹងបុរសចិនតាមរយៈមេខ្យល់រួចគេខ្លួនបាត់ គឺបន្ទាប់ពីទទួលបានថ្លៃបណ្ណាការរួច ហើយមន្ត្រីទាំងនេះការលំបាកផងដែរអំពីភាពខុសគ្នារវាងការរៀបការដោយបង្ខំនិងការឈ្លោះប្រកែកគ្នាប្តីប្រពន្ធនិងក្រុមគ្រួសារដោយសារតែបញ្ហាភាសា។

*ផងមន្ត្រីនោះក៏ឱ្យខ្ញុំសម្រាកនៅក្នុងបន្ទប់មួយ។ លុះដល់ស្អែកឡើងគាត់បានបញ្ជូនខ្ញុំទៅកាន់កន្លែងមួយដែលមាននគរបាលធ្វើការច្រើននៅទីនោះ។ ប្រហែលជិតដល់ពេលថ្ងៃត្រង់មន្ត្រីកុងស៊ុលកម្ពុជាបានមកជួបខ្ញុំហើយនិយាយគ្នាអំពីស្ថានភាពរបស់ខ្ញុំ។ ដោយសារខ្ញុំមានលិខិតឆ្លងដែនថតចម្លងនោះ ករណីរបស់ខ្ញុំពុំសូវពិបាកដោះស្រាយឡើយ។ គាត់ក៏បានបញ្ជូនខ្ញុំទៅកាន់មណ្ឌលស្នាក់នៅបណ្ដោះអាសន្នខណៈដែលមន្ត្រីកុងស៊ុលកំពុងចាត់ការរឿងរបស់ខ្ញុំជាមួយនគរបាល។ មួយថ្ងៃក្រោយមក មន្ត្រីកុងស៊ុល និងនគរបាលហៅប្ដីខ្ញុំឱ្យយកមកជាមួយនូវលិខិតឆ្លងដែនរបស់ខ្ញុំមកជួបគ្នាដើម្បីដោះស្រាយ។ នគរបាលសួរខ្ញុំថាតើខ្ញុំមានបំណងវិលត្រឡប់ទៅផ្ទះជាមួយប្ដីវិញដែរឬទេ។ ខ្ញុំឆ្លើយថាអត់ទេ។ គាត់ក៏យកខ្ញុំទៅមណ្ឌលវិញ ហើយមន្ត្រីកុងស៊ុលប្រាប់ឱ្យខ្ញុំស្នាក់នៅទីនោះរង់ចាំគេធ្វើឯកសារដែលចាំបាច់សម្រាប់ធ្វើដំណើររួចរាល់សិន។ ខ្ញុំនៅក្នុងមណ្ឌលប្រហែលពីរសប្ដាហ៍ទើបមន្ត្រីកុងស៊ុលប្រាប់ខ្ញុំថាឯកសាររបស់ខ្ញុំរួចរាល់ ហើយខ្ញុំត្រូវទិញសំបុត្រយន្តហោះដោយខ្លួនឯង។ ខ្ញុំប្រាប់គាត់វិញថាខ្ញុំគ្មានលុយទិញទេ។ គាត់ក៏ឱ្យយោបល់ថាទាក់ទងទៅម្ដាយឪពុកខ្ញុំឱ្យផ្ញើមក។ ម្ដាយខ្ញុំរកបាន ៣០០$ ហើយផ្ញើមកខ្ញុំតាមរយៈបងប្អូនរបស់មន្ត្រីកុងស៊ុលនៅទីក្រុងភ្នំពេញ។ ទីបំផុតខ្ញុំក៏បាន មកប្រទេសកម្ពុជាវិញ។"*

អ្នកតបសំណួរម្នាក់ទៀតរាយការណ៍ថាខ្លួនបានរត់គេចទៅខេត្តក្វាងចូវ ហើយបានសុំឱ្យតាក់ស៊ីដឹកនាងទៅស្ថានអគ្គកុងស៊ុលកម្ពុជានៅទៅនោះ។ ប៉ុន្តែតាក់ស៊ីនាំនាងយកទៅអាកាសយានដ្ឋានទៅវិញ។ នៅទីនោះនាងរត់រកនគរបាល៖

*"ខ្ញុំឃើញនគរបាល រួចខ្ញុំចូលខ្លួនឱ្យគាត់ចាប់។ គាត់នាំខ្ញុំទៅការិយាល័យរបស់គាត់ក្នុងអាកាសយានដ្ឋាននោះដើម្បីសាកសួរ។ ដោយសារភាសានិយាយស្ដាប់គ្នាមិនបាន ខ្ញុំព្យាយាមនិយាយដដែលៗថា 'កម្ពុជា'ៗ។"*

នគរបាលក៏បានទាក់ទងមកកុងស៊ុលកម្ពុជានៅខេត្តក្វាងចូវ ហើយក្រោយមកនាងក៏ត្រូវគេបញ្ជូនមកកម្ពុជាវិញ។

អ្នកតបសំណួរម្នាក់ដែលបានរត់ពីភូមិរបស់នាងនៅទៅកុងស៊ុលក្រុងសៀងហៃ ប៉ុន្តែមន្ត្រីនៅទីនោះប្រាប់នាងឱ្យទៅស្ថានទូតនៅប៉េកាំង។ ដូច្នេះនាងក៏ឡើងរថយន្តក្រុងទៅកាន់ប៉េកាំងតែម្ដង។

*"វាយប់ហើយ ខ្ញុំរកស្ថានទូតមិនឃើញ ខ្ញុំក៏សួរអ្នកនៅក្បែរនោះរកប៉ុស្ដិ៍នគរបាល ហើយក៏ចូលទៅប៉ុស្ដិ៍។ នគរបាលសួរខ្ញុំព្យាយាមនិយាយភាសាចិនដែលខ្ញុំចេះជាមួយគាត់។ គាត់ក៏អនុញ្ញាតឱ្យខ្ញុំស្នាក់នៅក្នុងប៉ុស្ដិ៍នៅយប់នោះ។ ស្អែកឡើងប្រហែលម៉ោង៩ព្រឹកមន្ត្រីមកពីស្ថានទូតមកជួបខ្ញុំ។"*

## ស្ថានកុងស៊ុល និងស្ថានឯកអគ្គរាជទូតកម្ពុជា

អ្នកតបសំណួរបានរៀបរាប់ពីបទពិសោធន៍នានាដែលគេជួបប្រទះនៅឯស្ថានកុងស៊ុល និងស្ថានឯកអគ្គរាជទូតកម្ពុជានៅក្នុងប្រទេសចិន។ ខ្លះសម្ដែងការពេញចិត្តចំពោះកិច្ចខិតខំយកចិត្តទុដាក់រកកន្លែងឱ្យស្នាក់នៅ ម្ហូបអាហារនៅក្នុងប្រទេសចិនរហូតដល់ពេលបានត្រឡប់មកមាតុប្រទេសវិញ។ មួយចំនួនទៀតលើកឡើងជាយោបល់ថា វត្តមានរបស់មន្ត្រីកុងស៊ុលនៅការិយាល័យនគរបាលចំពោះមុខប្ដី នៅពេលដែលស្ត្រីសុំលែងលះប្ដីនិងឱ្យបញ្ជូនត្រឡប់ទៅផ្ទះវិញ ។ គ្រប់ៗគ្នាពេញចិត្តចំពោះការអនុញ្ញាតឱ្យប្រើប្រាស់ទូរស័ព្ទមកក្រុមគ្រួសារនៅប្រទេសកម្ពុជា។ លើសពីនេះទៀត មន្ត្រីកុងស៊ុលជារឿយៗជូនស្ត្រីខ្មែរទាំងនោះមកដល់អាកាសយានដ្ឋាន និងរហូតដល់ពួកគេចាកចេញពីប្រទេសនោះដោយសុវត្ថិភាព។ ខាងក្រោមនេះជាការរ៉ាយរ៉ាប់របស់អ្នកតបសម្ភាសន៍ស្ដីពីកិច្ចគាំពារដែលបានទទួលខណៈស្នាក់នៅស្ថានកុងស៊ុលៈ

*"ខ្ញុំបានលេខទូរស័ព្ទទាក់ទងជាមួយមន្ត្រីកុងស៊ុលពីស្ត្រីម្នាក់ទៀតដែលរស់នៅក្នុងតំបន់ជាមួយខ្ញុំដែរ។ ខ្ញុំរៀបចំផែនការរត់គេចជាលើកទីពីរ។ ខ្ញុំក៏ទូរស័ព្ទទៅមន្ត្រីកុងស៊ុលដើម្បីសុំយោបល់គាត់។ ពេលរត់លើកនេះខ្ញុំជិៈតាក់ស៊ីទៅចំណតរថយន្តក្រុងនៅទីប្រជុំជនមួយឆ្ងាយពីផ្ទះ ហើយខ្ញុំឱ្យលុយអ្នកបើកតាក់ស៊ីជួយទិញសំបុត្ររថយន្តក្រុងឱ្យខ្ញុំ។ ទីបំផុតខ្ញុំមកដល់ស្ថានកុងស៊ុលក្នុងក្រុងសៀងហៃ ហើយមន្ត្រីនៅទីនោះជួបសម្ភាសខ្ញុំ។ មន្ត្រីនៅទីនោះអនុញ្ញាតឱ្យខ្ញុំស្នាក់នៅទីនោះមួយយប់។ គាត់ក៏ទូរស័ព្ទហៅប្ដីខ្ញុំមកហើយឱ្យយកលិខិតឆ្លងដែនខ្ញុំមកជាមួយផង។ ក្នុងបន្ទប់នោះមានមន្ត្រីកុងស៊ុល នគរបាល ប្ដីខ្ញុំ និងខ្ញុំ។ គាត់សួរអំពីបំណងរបស់ខ្ញុំ។ ខ្ញុំប្រាប់គាត់ថាខ្ញុំមានបំណងលែងលះហើយវិលត្រឡប់ទៅស្រុកកំណើតវិញ។ ពេលថ្ងៃគេឱ្យខ្ញុំរង់ចាំនៅខាងក្រៅស្ថានកុងស៊ុល ហើយយប់ឡើងគេអនុញ្ញាតឱ្យខ្ញុំចូលសម្រាកនៅក្នុងការិយាល័យកុងស៊ុលបាន។ ខ្ញុំរង់ចាំរបៀបនេះរហូតដល់ដប់ថ្ងៃ។*

*មន្ត្រីកុងស៊ុលសួរខ្ញុំថាតើខ្ញុំអាចទិញសំបុត្រយន្តហោះទៅវិញបានទេ។ គាត់ប្រាប់ថាសំបុត្រយន្តហោះថ្លៃ២៣៥០យ៉ាន់ ខ្ញុំក៏ឱ្យសាច់ប្រាក់សុទ្ធទៅគាត់តែម្តង។ នៅពេលអ្វីៗរៀបចំរួចរាល់សម្រាប់ខ្ញុំចាកចេញ ពួកគាត់បានជូនដំណឹងដល់រូបខ្ញុំ ឱ្យត្រៀមចេញដំណើរ។ មានស្ត្រីប្អូននាក់រួមទាំងខ្ញុំផងវិលត្រឡប់មកមាតុភូមិវិញ។ នគរបាលម្នាក់ និងមន្ត្រីកុងស៊ុលម្នាក់ជូនពួកយើងមកអាកាសយានដ្ឋានរហូតដល់យើងចូលយន្តហោះ។"*

ទោះជាយ៉ាងនោះក្តី យើងក៏ឃើញមានការព្រួយបារម្ភពីការប្រតិបត្តិរបស់មន្ត្រីកុងស៊ុល និងស្ថានទូត។ អ្នកតបសំណួរខ្លះបានមកតាំងពីខេត្តជាងស៊ីរហូតដល់ស្ថានកុងស៊ុលក្រុងសៀងហៃ ប៉ុន្តែមន្ត្រីទីនោះប្រាប់ពួកគាត់ថាឱ្យទៅរកស្ថានទូតនៅក្រុងប៉េកាំងដើម្បីជួយព្រោះថាខេត្តជាំងស៊ីមិនមែនស្ថិតនៅក្រោមយុត្តាធិការរបស់កុងស៊ុលសៀងហៃទេ។ រឿងនេះកើតឡើងដូចគ្នាដែរចំពោះអ្នកដែលស្វែងរកជំនួយនៅស្ថានកុងស៊ុលខេត្តក្វាងចូវ។ ការបញ្ជូនទៅក្រុងប៉េកាំង អ្នកស្វែងរកជំនួយត្រូវធ្វើដំណើរប្រហែលពី១២០០គីឡូម៉ែត្រ ទៅ២១០០គីឡូម៉ែតទៀតឯណោះ ដោយគួបផ្សំជាមួយការចំណាយប្រាក់បន្ថែមសម្រាប់ធ្វើដំណើរ និងភាពងាយរងគ្រោះថ្នាក់ក៏កើនឡើងចំពោះការរត់គេចរបស់ខ្លួន។ អ្នកតបសំណួរមិនដែលដឹងពីវិសាលភាពនៃយុត្តាធិការនេះទេ ដូច្នេះអ្នកតបសម្ភាសចាត់ទុកអាជ្ញាធរកម្ពុជាថាមិនបានជួយពួកគេទេ។ ស្ត្រីភាគច្រើនយល់ឃើញថាមន្ត្រីទាំងនោះដឹងថាពួកគេមិនសប្បាយចិត្តនឹងជីវិតអាពាហ៍ពិពាហ៍របស់គេទេ ហើយក៏ព្យាយាម ចាកចេញពីស្ថានភាពនោះដែរ ប៉ុន្តែមន្ត្រីទាំងនោះមិនបានគិតគូរពីឋានៈជាអ្នករងគ្រោះដោយសារការរៀបការដោយបង្ខំ ឬរកវិធីដើម្បីជួយពួកគេឡើយ។[49]

អ្នកតបសំណួរដែលកំពុងរង់ចាំការត្រឡប់មកមាតុប្រទេសវិញបញ្ជាក់ថាតម្លៃសំបុត្រយន្តហោះត្រឡប់មកវិញដែលមន្ត្រីកុងស៊ុលទារនោះខ្ពស់ជាងតម្លៃពិតប្រាកដឆ្ងាយណាស់។ ឧទាហរណ៍ ស្ត្រីម្នាក់បង្ហើបឱ្យដឹងថាមន្ត្រីកុងស៊ុលប្រាប់នាងឱ្យម្តាយនាងផ្ញើប្រាក់ចំនួន៧០០$

[49] តាំងពីដើមឆ្នាំ២០១៥មក ស្ថានទូតកម្ពុជាក្នុងទីក្រុងប៉េកាំងបានណែនាំឱ្យមានការប្រើប្រាស់ទម្រង់ស្តង់ដាមួយបង្កើតឡើងនិងឧបត្ថម្ភដោយIOM ដើម្បីពិនិត្យថាតើស្ត្រីដែលមកស្វែងរកជំនួយនោះជាជនរងគ្រោះដោយអំពើជួញដូរមនុស្សដែរឬទេ។

សម្រាប់ទិញសំបុត្រយន្តហោះត្រឡប់ទៅវិញ។[50] គ្រួសាររបស់នាងទៅរកអង្គការមិនមែនរដ្ឋាភិបាលឱ្យជួយនាំនាងត្រឡប់មកវិញ។ ពេលដែលដឹងថាមានអង្គការចូលរួមជួយគាត់ក៏បញ្ចុះតម្លៃមកនៅត្រឹមតែ៥០០$។

ការរៀបរាប់ផ្សេងទៀតរបស់ជនរងគ្រោះគួរឱ្យព្រួយបារម្ភជាខ្លាំង ដូចជាការប្រមាថ និងការបំពារបំពាន។

## ក្រុមអ្នកស្ម័គ្រចិត្ត និងអង្គការនានា

បុគ្គល និងអង្គការនានាជួយអ្នកតបសម្ភាសឱ្យរួចខ្លួនចេញពីស្ថានភាពជីវិតរៀបការដោយបង្ខំ។ ក្រុមអ្នកស្ម័គ្រចិត្តចិនក្នុងក្រុងតូចៗនៅខេត្តជាំងស៊ីក៏ដូចជាក្រុងធំៗដូចជាក្វាងចូវ សៀងហៃ និងប៉េកាំងជាកន្លែងដែលមានស្ថានកុងស៊ុល និងស្ថានទូតកម្ពុជាតាំងនៅ តែងតែបានផ្តល់ជំនួយក្នុងដំណាក់កាលណាមួយជានិច្ច។ ភាគច្រើនបានជួយស្ត្រីដែលរង់ចាំការធ្វើមាតុភូមិនិវត្តនៅក្រុងធំៗដើម្បី ឱ្យទទួលបានឯកសារសម្រាប់ធ្វើដំណើរឬ រៀបចំនិងបង់ថ្លៃធ្វើដំណើរត្រឡប់មកកម្ពុជាវិញ។ ការជួយនោះជួនកាលរាប់បញ្ចូលទាំងម្ហូបអាហារ ការពិនិត្យសុខភាពដល់ស្ត្រីមានផ្ទៃពោះ ការផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទំនាក់ទំនងផ្សេងៗទៀត។ ខាងក្រោមនេះជាកំណត់ត្រាពីកិច្ចសម្ភាសបង្ហាញពីការជួយរបស់អ្នកស្ម័គ្រចិត្តទាំងនោះ៖

> *"មានស្ត្រីពីរនាក់បានរត់ចេញពីផ្ទះប្តីនាងនៅ លីពីង ហើយចូលទៅប៉ុស្តិ៍នគរបាលក្រុងណានឆាង ខេត្តជាំងស៊ី ដើម្បីឱ្យជួយ។ ពួកនាងត្រូវរង់ចាំរយៈពេលមួយថ្ងៃដើម្បីឱ្យនគរបាលណានឆាង និងលីពីងស៊ើបអង្កេតករណីនោះ។ អ្នកសិក្សាស្រាវជ្រាវបានជួយសម្របសម្រួលទាក់ទងទៅកាន់អ្នកស្ម័គ្រចិត្តពីរនាក់ហើយពួកគេទិញអាហារថ្ងៃត្រង់ សម្លៀកបំពាក់ និងស្បែកជើង ហើយបានរកបន្ទប់សណ្ឋាគារឱ្យនារីទាំងពីរនាក់នោះស្នាក់នៅផងដែរ។ ពួកគេក៏ស្នាក់នៅក្នុងបន្ទប់ជាមួយស្ត្រីខ្មែរទាំងពីរនាក់នោះដែលក្នុងគោលបំណងការពារសុវត្ថិភាពក្នុងករណីដែលប្តីរបស់ពួកគេមកតាមរក។ ដោយសារនារីទាំងពីរនាក់នោះបានចុះសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍រួចហើយ នគរបាលឃើញថានាងបានរៀបការដោយស្របច្បាប់*

---

[50] មន្ត្រីបច្ចេកទេសម្នាក់បានបញ្ជាក់ថាជនរងគ្រោះដោយអំពើជួញដូរមនុស្សមួយចំនួនបានបង់ប្រាក់រវាង១៨០០$ ដល់២០០០$ ឱ្យទៅមន្ត្រីកុងស៊ុលកម្ពុជាក្នុងប្រទេសចិនជាថ្នូរក្នុងការធ្វើមាតុភូមិនិវត្តខ្លួនមកវិញដោយធានាថាមិនបញ្ជូនទៅឱ្យអាជ្ញាធរចិន ឬជាប់គុកទេ។

*និងមិនពាក់ព័ន្ធនឹងការជួញដូរមនុស្សទេ ដូច្នេះនគរបាលមិនបានផ្តល់ជំនួយអ្វីដល់អ្នកទាំងពីឡើយ។ ដោយមានការភ័យខ្លាចថាប្តីពួកគេអាចមកយកពួកគេត្រឡប់ទៅវិញនោះ អ្នកស្ម័គ្រចិត្តពីខេត្តជាំងស៊ីបានជួយជូនដំណើរនាងទាំងពីរនាក់ទៅរហូតដល់ស្ថានទូតកម្ពុជានៅទីក្រុងប៉េកាំងដើម្បីរកជំនួយបន្តទៀត។ ដោយហេតុថាពួកនាងមិនមានឯកសារសម្គាល់ខ្លួន គេមិនអាចជិះរថភ្លើងបានឡើយ ដូច្នេះទាំងរូបពួកនាង និងអ្នកស្ម័គ្រចិត្តត្រូវជិះរថយន្តក្រុងដែលចំណាយពេលរហូតដល់៣០ម៉ោងឯណោះទើបដល់ក្រុងប៉េកាំង។ ពេលមកដល់ក្រុងប៉េកាំង ក្រុមអ្នកស្ម័គ្រចិត្តទីក្រុងនេះបានទាក់ទងការិយាល័យ UN-ACTប្រចាំប្រទេសចិន និងការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃក្រសួងសន្តិសុខសធារណៈដើម្បីកំណត់ថាតើពួកគេទាំងពីរនាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬយ៉ាងណា។ អ្នកស្ម័គ្រចិត្តបានជួយពួកគេដែលម្នាក់មានផ្ទៃពោះផងនោះឱ្យទទួលបានការថែទាំសុខភាព រៀបចំចុះហត្ថលេខាលើកំណត់ហេតុ និងស្នើសុំលិខិតឆ្លងដែនថ្មី។ ក្រោយពីស្ត្រីទាំងពីរត្រូវអាជ្ញាធរកំណត់ជាផ្លូវការថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សហើយ គេក៏ទទួលបានលិខិតឆ្លងដែន ហើយអ្នកស្ម័គ្រចិត្តបានជួយទិញសំបុត្រយន្តហោះនិងជូនអ្នកទាំងពីរមកដល់អាកាសយានដ្ឋានប៉េកាំងទៀតផង។”*

# របកគំហើញ៖ ស្ថានភាពក្រោយការវិលត្រឡប់មកប្រទេសកម្ពុជាវិញ

## ការត្រឡប់មកដល់ប្រទេសកម្ពុជាវិញ

ជាធម្មតាឪពុកម្តាយស្ត្រីទាំងនោះទៅទទួលនៅឯអាកាសយានដ្ឋាន ជួនកាលមានតំណាងអង្គការអន្តរជាតិទៅជាមួយផង។ ស្ត្រីដែលវិលត្រឡប់មកវិញត្រូវនគរបាលអន្តោប្រវេសន៍សាកសួរពីមេខ្យល់ដែលពាក់ព័ន្ធនឹងការធ្វើដំណើរទៅកាន់ប្រទេសចិន។ ក្នុងករណីខ្លះ ស្ត្រីទាំងនោះត្រូវបានអនុញ្ញាតក៏ឱ្យត្រឡប់ទៅផ្ទះតែម្តង ក្រោយពីការសម្ភាសលើកដំបូង។ ក្នុងករណីខ្លះទៀត ពួកគេត្រូវនាំទៅអគ្គស្នងការនគរបាលជាតិដើម្បីសាកសួរបន្ថែមទៀត។ ជួនកាល មន្ត្រីនគរបាលអន្តោប្រវេសន៍ជួយជូនពួកគេទាំងម្តាយឪពុកដែលមកទទួល ទៅកាន់ការិយាល័យអង្គការសង្គមស៊ីវិល ឬអង្គការអន្តរជាតិទៀតផង។ មានស្ត្រីម្នាក់ត្រឡប់មកវិញ

តាមអាកាសយានដ្ឋានអន្តរជាតិសៀមរាប[51] រៀបរាប់ថាពេលនាងមកដល់នគរបាលនៅទីនោះគម្រាមចាប់ដាក់គុកថែមទៀត។

អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិផ្តល់នូវជំនួយឧបត្ថម្ភនានាដល់អ្នកតបសំណួរមានតាំងពីម្ហូបអាហារ សម្ភារៈអនាម័យ និងការស្នាក់សំចតនៅភ្នំពេញរយៈពេលពីរឬបីថ្ងៃ និងសោហ៊ុយធ្វើដំណើរត្រឡប់ទៅផ្ទះវិញជាដើម។ មានស្ត្រីមួយចំនួនប្រាប់ថា អង្គការសង្គមស៊ីវិលផ្តល់កន្លែងស្នាក់នៅនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ មួយចំនួនទៀតបានទទួលជំនួយជាសាច់ប្រាក់ចាប់ពី៣០០$ ដល់៥០០$ដើម្បីសមាហរណកម្ម ឬសម្រាប់ចេញថ្លៃជួលផ្ទះ។ អង្គការនីមួយៗមានរបៀបជួយផ្សេងៗគ្នារៀងៗខ្លួន។

## ស្ថានភាពរបស់អ្នកតបសម្ភាសបន្ទាប់ពីការវិលត្រឡប់វិញរយៈពេលពីរឬបីខែដំបូង

មានអ្នកតបសំណួរមួយចំនួនបញ្ជាក់ថាពួកគេជាប់បំណុលដោយសារខ្ចីលុយគេដើម្បីធ្វើដំណើរត្រឡប់មកពីប្រទេសចិនវិញ។ ស្ត្រីម្នាក់ប្រាប់ថាគ្រួសាររបស់នាងជំពាក់ប្រាក់អ្នកចងការប្រាក់ក្នុងភូមិចំនួន១០០០$ដោយបញ្ចាំប្លង់ផ្ទះ។ នាងត្រូវបង់សងគេក្នុងមួយខែ៧០$ជាប្រចាំ។ នាងធ្វើការប៉ាន់ស្មានថាការបង់សងគេនោះនឹងមានរយៈពេលពីរឆ្នាំទើបរួចទាំងការទាំងដើម។ អ្នកតបសំណួរម្នាក់ទៀតដែលបានត្រឡប់មកផ្ទះវិញទាំងមានផ្ទៃពោះផងនោះឱ្យដឹងដែរថា នាងជំពាក់ប្រាក់គេដោយសារម្តាយនាងខ្ចីប្រាក់គេដើម្បីចាត់ចែងសំបុត្រយន្តហោះឱ្យនាងត្រឡប់មកផ្ទះវិញ ហើយនាងខ្លួនឯងផ្ទាល់ក៏បានខ្ចីលុយពីស្ត្រីម្នាក់ដែលបានត្រឡប់មកជាមួយគ្នានោះតាំងពីនៅប្រទេសចិនម្លេះ។ មានអ្នកដទៃទៀតក៏បានប្រាប់ថាខ្លួនបានខ្ចីប្រាក់ពីសាច់ញាតិដើម្បីបង់ថ្លៃត្រឡប់មកពីប្រទេសចិន។

អ្នកតបសម្ភាសក្នុងការសិក្សាស្រាវជ្រាវនេះភាគច្រើន សុទ្ធតែមានការងារធ្វើនិងមានប្រាក់ខែទាំងអស់គ្នា ចាប់តាំងពីវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ មានស្ត្រីខ្លះធ្វើការងារនៅរោងចក្រកាត់ដេរ ខ្លះទៀតធ្វើការក្រៅម៉ោងគួបផ្សំជាមួយការងារកសិកម្មផង។ នារីម្នាក់បាន

[51] មានស្ត្រីមួយចំនួនចាកចេញ ឬចូលប្រទេសកម្ពុជាតាមអាកាសយានដ្ឋានអន្តរជាតិសៀមរាបព្រោះថាមិនមានជើងយន្តហោះនៅមានកំណត់នៅឡើយតាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

ប្រាប់ថា ពេលត្រឡប់មកវិញនាងក៏ចូលធ្វើការងាររោងចក្រភ្លាមៗដែរ ប៉ុន្តែម្តាយនាងក៏ធ្លាក់ខ្លួនឈឺ នាងក៏បោះបង់ការងារចោលហើយត្រឡប់មកស្រុកកំណើតហើយធ្វើជាអ្នកបម្រើការងារតាមផ្ទះ។ នាងលើកឡើងផងដែរថា ការងារដែលនាងធ្វើការងារតាមផ្ទះដប់ពីរម៉ោងក្នុងមួយថ្ងៃ ប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍ដោយទទួលបានប្រាក់ខែចំនួន១៥០$។ ស្ត្រីពីរនាក់ផ្សេងទៀតធ្វើការងារនៅហាងសំអាង ដោយស្ត្រីម្នាក់បានទទួលប្រាក់កម្ចីពីអង្គការសង្គមស៊ីវិលបើកហាងដោយខ្លួនឯង។ ស្ត្រីពីរនាក់ទៀតធ្វើការនៅផ្នែកសេវាកម្មម្ហូបអាហារទទួលបានប្រាក់១១០$ក្នុងមួយខែ បន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាលពីអង្គការមិនមែនរដ្ឋាភិបាលមក។

អ្នកតបសំណួរខ្លះមិនទទួលយកឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈទេ។ ឧទាហរណ៍ ស្ត្រីម្នាក់និយាយថាគាត់គ្មានពេលដើម្បីរៀនវិជ្ជាជីវៈឡើយ ព្រោះថាគាត់ត្រូវការរកប្រាក់ជាបន្ទាន់។ ម្នាក់ទៀតប្រាប់ថានាងគ្មានប្រាក់ដើម្បីធ្វើសោហ៊ុយធ្វើដំណើរមករៀនវិជ្ជាជីវៈទេ។

## វិធានការប្រឆាំងនឹងមេខ្យល់

អ្នកតបសំណួរភាគច្រើនមិនប្តឹងមេខ្យល់ទេដោយមូលហេតុមួយចំនួន។ ដោយសារគេមិនចង់ឡើងតុលាការ និងពាក់ព័ន្ធនឹងនីតិវិធីច្បាប់ ដោយលើកហេតុផលថាវាចំណាយពេលយូរ។ ខ្លះទៀតមិនចង់រំលឹកពីការឈឺចាប់ដែលខ្លួនមាននៅក្នុងប្រទេសចិនឡើយ។ ហើយមួយចំនួនទៀតបារម្ភពីការខាតបង់ពេលវេលាធ្វើការងារ និងមុខរបររបស់ខ្លួន។

ខាងក្រោមនេះជារឿងរ៉ាវរបស់ស្ត្រីម្នាក់បានដាក់ពាក្យប្តឹងមេខ្យល់កាលពីនាងនៅប្រទេសចិននៅឡើយ ឥឡូវនេះនាងមិនមានបំណងបន្តប្តឹងទៀតឡើយ បន្ទាប់ពីនាងបានមកដល់ប្រទេសកម្ពុជាវិញ។

> *"ខ្ញុំមិនចង់ប្តឹងមេខ្យល់ទេ។ ខ្ញុំចង់បញ្ចប់សំណុំរឿងរបស់ខ្ញុំដោយសារខ្ញុំបានមកដល់ផ្ទះវិញហើយ។ ខ្ញុំមិនចង់ជាប់ពាក់ព័ន្ធនឹងបញ្ហាច្បាប់ ឬចំណាយប្រាក់ក្នុងការធ្វើដំណើរចុះឡើងៗមកភ្នំពេញជួបនគរបាល និងតុលាការទេ។ ម្យ៉ាងទៀតខ្ញុំក៏មិនចង់មានឈ្មោះផ្សព្វផ្សាយនៅលើទំព័រសារព័ត៌មានដែរ។"*

អ្នកតបសំណួរម្នាក់ទៀតមិនចង់ប្តឹងមេខ្យល់ព្រោះថាពួកគេរស់នៅភូមិជាមួយគ្នា ហើយគ្រួសារនាងខ្លាចគេតាមសងសឹក។

ដោយឡែកមានអ្នកតបសំណួរពីរឬបីនាក់តែប៉ុណ្ណោះបានប្តឹងមេខ្យល់។ ស្ត្រីម្នាក់និយាយថាបន្ទាប់ពីនាងរត់គេចពីប្តីក្នុងប្រទេសចិនមក ឪពុកម្តាយនាងបានទូរស័ព្ទទៅកាន់ភ្នាក់ងារនៅប្រទេសកម្ពុជា ប៉ុន្តែគេឆ្លើយថាគេមិនទទួលខុសត្រូវនូវអ្វីដែលកើតមានឡើងនៅប្រទេសចិនឡើយ។ ពេលឪពុកម្តាយនាងគម្រាមប្តឹង គេថាគេឱ្យប្រាក់៥០០$ដើម្បីបញ្ចប់រឿង តែគ្រួសារនាងមិនព្រមទេ។ ផ្ទុយទៅវិញគ្រួសារនាងបានប្តឹងនគរបាលប៉ុស្ត៍ ប៉ុន្តែមេខ្យល់នោះបានរត់គេចខ្លួនបាត់ទៅហើយ។ ស្ត្រីម្នាក់ទៀតបន្តប្តឹងមេខ្យល់ដោយទទួលបានការគាំទ្រពីអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា៖

> *"ខ្ញុំសម្រេចដាក់ពាក្យប្តឹងសំអាងលើហេតុផលពីរយ៉ាង ទីមួយដើម្បីទទួលបានសំណងខូចខាតដែលបង្កឡើងដោយការបោកបញ្ឆោតនោះ និងទីពីរ ខ្ញុំចង់ឱ្យមេខ្យល់នោះជាប់គុក ដូច្នេះនឹងមិនមានស្ត្រីណាម្នាក់ទៀតធ្លាក់ចូលក្នុងការបង្ខំឱ្យរៀបការដូចដែលខ្ញុំឆ្លងកាត់រួចហើយ។"*

## ស្លាកស្នាមជិតជាប់អ្នកវិលត្រឡប់ពីប្រទេសចិនវិញ

ស្ត្រីមួយចំនួនមានការភ័យខ្លាច ឬមានស្លាកស្នាមបទពិសោធន៍ពាក់ព័ន្ធនឹងការវិលត្រឡប់មកពីប្រទេសចិនវិញ។ ឧទាហរណ៍ អ្នកតបសំណួរម្នាក់ប្រាប់ថា ពេលអង្គការមិនមែនរដ្ឋាភិបាលសួរថាតើនាងចង់ទៅលេងគ្រួសារនៅស្រុកកំណើតទេ នាងបានប្រកែកមិនទៅព្រោះនាងបានសម្រេចចិត្តចេញទៅប្រទេសចិនដោយខ្លួនឯង ហើយនាងគិតថាក្រុមគ្រួសារនាងនឹងមិនពេញចិត្តនាងឡើយ។ ស្ត្រីម្នាក់ទៀតប្រាប់ថា នាងមិនទៅស្រុកកំណើតវិញទេព្រោះថានាងមានផ្ទៃពោះពេលមកពីប្រទេសចិន នាងបារម្ភថាអ្នកភូមិនឹងមើលងាយមើលថោកនាង។ ក្នុងករណីផ្សេងមួយទៀត ក្រុមអ្នកសិក្សាស្រាវជ្រាវបានជួបឪពុកនារីម្នាក់ដែលវិលត្រឡប់ពីប្រទេសចិន ពួកគាត់និយាយដដែលៗថាកូនស្រីខ្លួនអស់ព្រហ្មចារីយ៍ ហើយនាងនឹងគ្មានឱកាសរៀបការឡើយ។ ក្នុងករណីគួរឱ្យសោកសៅដោយឡែកមួយទៀត អង្គការសង្គមស៊ីវិលបានប្រាប់ថា មានស្ត្រីម្នាក់ត្រូវគ្រួសារកាត់កាលចោលបន្ទាប់ត្រឡប់មកពីប្រទេសចិនវិញ។ នាងមានបំណងធ្វើអត្តឃាតនៅក្នុងការិយាល័យរបស់ពួកគេ។

# សន្និដ្ឋាន

ការរៀបការដោយបង្ខំជាផ្នែកមួយនៃការធ្វើចំណាកស្រុកដើម្បីរៀបអាពាហ៍ពិពាហ៍ ដែលមិនទាន់មានការសិក្សាស្រាវជ្រាវស៊ីជម្រៅនៅឡើយ ហើយទំនាក់ទំនងរវាងការរៀបការរបៀបនេះនិងការជួញដូរមនុស្ស នៅតែជាប្រធានបទនៃការពិភាក្សានៅឡើយ។ ការសិក្សាស្រាវជ្រាវនេះព្យាយាមយល់ពីការរៀបការមួយដែលកើតឡើងពីការបោកបញ្ឆោត[52] ឬការបង្ខិតបង្ខំដែលជាធាតុផ្សំមួយក្នុងការជួញដូរមនុស្ស ដោយមិនគិតតើមានឬគ្មាន ភស្តុតាងនៃការកេងប្រវ័ញ្ចផ្លូវភេទ ឬការកេងប្រវ័ញ្ចកម្លាំងពលកម្មនោះទេ ពីព្រោះការរៀបការដោយបង្ខំស្មើនឹងករណីកេងប្រវញ្ច។ ទោះបីជាមានទស្សនៈខុសគ្នាក៏ដោយ ការយល់ឃើញអំពីការរៀបការដោយបង្ខំបែបនេះ ស្របនឹងច្បាប់អន្តរជាតិ[53]និងការអនុវត្តក្នុងប្រទេសកម្ពុជា-ចិន ជាកន្លែងដែលការសិក្សាស្រាវជ្រាវនេះប្រព្រឹត្តិទៅ។

ខុសពីទម្រង់នានានៃការជួញដូរមនុស្ស ដែលការសិក្សាបានផ្តោតការយកចិត្តទុកដាក់លើលក្ខណៈបែបផែន និងទំហំនៃការកេងប្រវ័ញ្ច ចំពោះការរៀបការដោយបង្ខំវិញ មធ្យោបាយដែលធ្វើឱ្យមានការរៀបការនិងមធ្យោបាយនៃការរក្សាចំណងអាពាហ៍ពិពាហ៍ ជាចំណុចគន្លឹះ។ សំខាន់បំផុតគឺមេខ្យល់ជ្រើសរើសតាមរយៈការបោកបញ្ឆោត ឬក៏ការបង្ខិតបង្ខំ ចំណែកឯប្តី ហើយជួនកាលក្រុមគ្រួសារ មានការបង្ខិតបង្ខំដើម្បីរក្សាចំណងអាពាហ៍ពិពាហ៍ ដែលផ្ទុយពីឆន្ទៈរបស់ស្ត្រី។ ការសិក្សានេះក៏បានរកឃើញ តួអង្គ និងកត្តាសំខាន់ៗមួយចំនួនដែលជះឥទ្ធិពលលើការធ្វើចំណាកស្រុកពីកម្ពុជាដើម្បីទៅរៀបការនៅឯប្រទេសចិន។

ឱកាសការងារមានកំណត់ រួមផ្សំនឹងបញ្ហាសេដ្ឋកិច្ចផងនោះបណ្តាលឱ្យគ្រួសារមួយចំនួនជាពិសេសស្ត្រីត្រូវសម្រេចចិត្តធ្វើចំណាកស្រុកដើម្បីស្វែងរកឱកាសដើម្បីជួយគ្រួសារ។ មានភស្តុតាងមួយបង្ហាញយ៉ាងច្បាស់ថាស្ត្រីដែលធ្វើចំណាកស្រុកទៅប្រទេសចិនមានគោលបំណងតែមួយគឺរកលុយផ្ញើមកផ្ទះ ខណៈគ្រួសារកំពុងតែត្រូវការ។ គ្មាននរណាម្នាក់ដឹងពីចំនួនជាក់លាក់នៃស្ត្រីបានធ្វើចំណាកស្រុកទៅរៀបការនៅប្រទេសចិននៅឡើយក៏ ប៉ុន្តែវាពិតជាមានចំនួនមួយច្រើន។

---

[52] ក្នុងការសិក្សាស្រាវជ្រាវនេះ ជាធម្មតាការជ្រើសរើសដោយបោកបញ្ឆោតកើតមាននៅក្នុងប្រទេសកម្ពុជា ហើយការគម្រាមកំហែងបង្ខិតបង្ខំកើតមានឡើងនៅក្នុងប្រទេសចិនដើម្បីឱ្យស្ត្រីខ្មែរទាំងនោះយល់ព្រមរៀបការដោយផ្ទុយពីឆន្ទៈរបស់ខ្លួន។

[53] សូមអានសេចក្តីផ្តើមស្តីពីកិច្ចពិភាក្សាលើទស្សនៈនេះ។

បើតាមការប៉ាន់ប្រមាណ មានបុរសចិនដល់អាយុរៀបការពី៣០ ទៅ៤០លាននាក់លើសចំនួនស្ត្រីចិន ក្នុងឆ្នាំ២០២០។ តួលេខនេះវាមានគម្លាតដាច់ឆ្ងាយរវាងចំនួនបុរសនិងចំនួនស្ត្រីដែលមានវ័យរៀបការ។ ដូច្នេះតម្រូវការស្ត្រីដើម្បីមកការជាប្រពន្ធដល់បុរសទាំងនោះក៏មានចំនួនច្រើនណាស់ដែរ។ អ្នកនៅទីក្រុងមានចំណេះដឹងខ្ពស់ និងមានមុខរបរច្បាស់លាស់នោះមិនមានការលំបាកក្នុងការស្វែងរកភរិយាទេ ផ្ទុយទៅវិញបុរសនៅជនបទទើបមានការពិបាករកប្រពន្ធ ព្រោះថាតម្លៃដើម្បីស្វែងរកប្រពន្ធកាន់តែកើនឡើងជាលំដាប់។ គេតែងតែពឹងពាក់មេខ្យល់ឱ្យនាំស្ត្រីពីប្រទេសក្រៅនៅក្នុងតម្លៃមួយដែលខ្លួនមានលទ្ធភាពទទួលយកបាន។

ក្នុងបរិយាកាសនេះ គួបផ្សំជាមួយកត្តាអូសទាញ និងកត្តារុញច្រានមួយចំនួនទៀតទើបបណ្ដាលឱ្យមានការធ្វើចំណាកស្រុកមិនស្របច្បាប់ពីប្រទេសកម្ពុជាដើម្បីមករៀបការនៅប្រទេសចិនកើតមានឡើង។ ប្រទេសទាំងពីរបានហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសតាមរយៈសេវាកម្មទីភ្នាក់ងារជ្រើសរើសគូស្រករ។ ហើយការធ្វើចំណាកស្រុកក្នុងគោលបំណងរៀបការដែលរៀបចំដោយភាគីទីបីក៏ត្រូវគេហាមឃាត់ផងដែរ។ ប៉ុន្តែកាលណាមកដល់ប្រទេសចិនហើយជនបរទេស និងជនជាតិចិននោះអាចទៅចុះសំបុត្រអាពាហ៍ពិពាហ៍បាន។ លើសពីនេះទៀតអាជ្ញាធរកម្ពុជាបានចាត់វិធានកាត់បន្ថយឱកាសសម្រាប់ស្ត្រីកម្ពុជាធ្វើដំណើរទៅប្រទេសចិន ទោះជាក្នុងរូបភាពទេសចរណ៍ក៏ដោយ ព្រោះមានការព្រួយបារម្ភពីការបង្ខំឱ្យរៀបការកើតមានឡើងដល់ពលរដ្ឋខ្លួន។

ទោះវិធានការនេះហាក់បីដូចជាមានឥទ្ធិពលធ្វើឱ្យចំនួនស្ត្រីគេនាំទៅរៀបការនៅប្រទេសចិនមានការថយចុះក្ដី ក៏គេមានការព្រួយបារម្ភពីការរើសអើងយេនឌ័រក្នុងសេរីភាពក្នុងការដើរហើរផងដែរ។ លើសពីនេះទៅទៀត គោលនយោបាយទាំងនេះអាចកាន់តែជម្រុញឱ្យស្ត្រីងាយធ្លាក់ចូលក្នុងភាពងាយរងគ្រោះក្នុងការបង្ខិតបង្ខំឱ្យរៀបការតាមរយៈសេវាដែលមិនមានតម្លាភាព និងគ្មានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ។ ភស្តុតាងខ្លះបង្ហាញថាស្ត្រីខ្មែរមួយចំនួនដែលរស់នៅក្នុងជីវិតរៀបការដោយបង្ខំនៅប្រទេសចិននោះមានការពេញចិត្តចំពោះស្ថានភាពជីវិតរបស់គេ[54]។ ប៉ុន្តែការសិក្សាស្រាវជ្រាវនេះបង្ហាញពីចំណុចអវិជ្ជមាននៃការរៀប

[54] គួរកត់សម្គាល់ថាការសិក្សាស្រាវជ្រាវនេះក៏បានសម្ភាសជាមួយស្ត្រីដែលទទួលបានភាពរីករាយក្នុងជីវិតរៀបការជាមួយបុរសចិនផងដែរ ប៉ុន្តែយើងមិនបានយកមកវិភាគក្នុងបរិបទរៀបការដោយបង្ខិតបង្ខំឡើយ។

ការតាមរយៈភាពមិនស្របច្បាប់។

មេខ្យល់មួយចំនួននៅក្នុងប្រទេសទាំងពីរជាប់ទាក់ទិននឹងការរៀបចំឱ្យគេធ្វើចំណាកស្រុកទៅរៀបការនៅប្រទេសចិន។ មេខ្យល់ទីមួយតែងតែស្គាល់គ្នាជាមួយក្រុមគ្រួសារ ឬស្ត្រីដែលមានបំណងធ្វើចំណាកស្រុក ព្រោះពួកគេរស់នៅក្នុងភូមិជាមួយគ្នា ឬធ្វើការងារនៅកន្លែងតែមួយ។ មេខ្យល់ទាក់ទាញការចាប់អារម្មណ៍ដោយរៀបរាប់អំពីករណីឱកាសរកប្រាក់នៅប្រទេសចិន តាមការរៀបការជាមួយបុរសចិនមានទ្រព្យសម្បត្តិ ឬក៏ការងារនៅប្រទេសចិនទទួលបានប្រាក់ខែខ្ពស់ជាងនៅប្រទេសកម្ពុជាជាដើម។ ខ្លះទៀតបានឱ្យប្រាក់មុន ដើម្បីឱ្យកាន់តែជឿទុកចិត្ត។ ជួនកាល ការរៀបអាពាហ៍ពិពាហ៍ត្រូវបានពិពណ៌នាថាជាការចាំចាប់មួយដើម្បីរកបានការងារធ្វើ និងសិទ្ធិស្នាក់នៅក្នុងប្រទេសចិនរយៈពេលយូរ។

តាមរយៈការលើកឡើងរបស់អ្នកតបសំណួរបង្ហាញយ៉ាងច្បាស់ថា នោះគ្រាន់តែជាការបោកបញ្ឆោតតែប៉ុណ្ណោះ។ ស្ត្រីខ្មែរជាអ្នកតបសម្ភាសក្នុងការសិក្សាស្រាវជ្រាវនេះមិនដែលមានគេណែនាំឱ្យជួបប្តីជាអ្នកមានទ្រព្យសម្បត្តិទេ ហើយក៏គ្មានលទ្ធភាពរកការងារល្អ ឬធ្វើការងារណាក្រៅពីការងារដែលគ្រួសារខាងប្តីឱ្យធ្វើបានដែរ។ ឱកាសការងារសម្រាប់ជនបរទេសក្នុងប្រទេសចិនមានការត្រួតពិនិត្យយ៉ាងម៉ឹងម៉ាត់ ប្រសិនបើមាន គឺមានតែក្នុងកាលៈទេសៈជាក់លាក់ណាមួយតែប៉ុណ្ណោះ។ ការរៀបការជាមួយជនជាតិហើយស្នាក់នៅក្នុងប្រទេសចិនមិនមានន័យថាទទួលបានអាទិភាពក្នុងការរកបានការងារធ្វើឡើយ គឺត្រូវរង់ចាំយ៉ាងហោចណាស់ក៏ប្រាំឆ្នាំដែរ ទើបមានសិទ្ធិស្របច្បាប់ក្នុងការរកការងារធ្វើ។

នៅពេលដែលព្រមព្រៀងគ្នាហើយ ជួនកាលដោយមានការលើកទឹកចិត្តពីសំណាក់សមាជិកគ្រួសារផងនោះ ភ្នាក់ងារនៅទីក្រុងរៀបចំឯកសារចាំបាច់មួយចំនួនមានដូចជាលិខិតឆ្លងដែន ទិដ្ឋាការ និងសំបុត្រយន្តហោះ។ ស្ត្រីមានបំណងធ្វើចំណាកស្រុកនោះនឹងទទួលបានឯកសារសម្រាប់ធ្វើដំណើរនៅឯអាកាសយានដ្ឋាន ហើយរមែងធ្វើដំណើរជាក្រុមតូចៗមានគ្នាពីបី ទៅប្រាំមួយនាក់ ដោយមិនមានអ្នកជូនទៅឡើយ។ គោលដៅរបស់គេមានដូចជាសៀងហៃ ឬក្វាងចូវ គឺអាស្រ័យការរៀបចំរបស់ភ្នាក់ងារក្នុងស្រុកទៅតាមក្រុងតូចៗ ឬភូមិដែលនៅឆ្ងាយៗពីអាកាសយានដ្ឋាន។

ពេលទៅដល់គោលដៅ ស្ត្រីទាំងនោះត្រូវគេឱ្យស្នាក់នៅផ្ទះរបស់មេខ្យល់ ឬផ្ទះសំណាក់ក្បែរផ្ទះមេខ្យល់ពីរឬបីសប្តាហ៍ទំរាំមានបុរសចិនមកមើល។ នៅពេលនេះហើយស្ត្រីទាំងនោះទើបដឹងថាខ្លួនចាញ់បោកគេ។ ជាទូទៅភ្នាក់ងារទាំងនោះដកហូតយកលិខិតឆ្លងដែនទុក ហើយឱកាសក្នុងការដើរហើរ ឬឱកាសក្នុងការប្រាស្រ័យទាក់ទងមកគ្រួសារនៅស្រុកកំណើតវិញនោះក៏ត្រូវគេហាមឃាត់ដែរ។

ទិដ្ឋាការក៏ជាលេសមួយដែលគេប្រើប្រាស់ដើម្បីគម្រាមស្ត្រីទាំងនោះឱ្យយល់ព្រមរៀបការ។ ដោយសារស្ត្រីទាំងនោះចូលប្រទេសចិនតាមរយៈទិដ្ឋាការទេសចរណ៍ដែលមានសុពលភាពត្រឹមតែរយៈពេល៣០ថ្ងៃ ស្ត្រីមួយចំនួនតូចដែលដឹងថាការស្នាក់នៅរបស់នាងជិតផុតកំណត់ហើយនោះ ត្រូវមេខ្យល់ប្រាប់ថាការរៀបការគឺជាជម្រើសតែមួយគត់ដើម្បីឱ្យពួកគេមានសិទ្ធិរស់នៅរយៈពេលយូរ និងជៀសសផុតពីការចាប់និរទេសចេញពីប្រទេសចិនវិញ។ លើសពីនេះទៀត មេខ្យល់ប្រើប្រាស់មធ្យោបាយផ្សេងៗ មានទាំងការបំពានផ្លូវភេទ ការ គម្រាមកំហែងឱ្យសងប្រាក់ដែលចំណាយលើការធ្វើដំណើរមកវិញ បង្អត់អាហារជាដើម ដើម្បីបង្ខំស្ត្រីទាំងនោះឱ្យយល់ព្រមរៀបការ។

ក្រោយពីទទួលបានការៈយល់ព្រម៉ពីស្ត្រី មេខ្យល់នាំនាងទៅចុះសំបុត្រអាពាហ៍ពិពាហ៍ និងបន្តទិដ្ឋាការឱ្យនាងនៅជាបន្តទៀត។ សេវារបស់គេគឺចប់ត្រឹមហ្នឹងហើយ។ ការចុះសំបុត្រអាពាហ៍ពិពាហ៍ទាមទារឱ្យសម៉ីខ្លួនទាំងពីរមានវត្តមាន បង្ហាញការយល់ព្រមចំពោះមុខអាជ្ញាធរ។ ពេលនេះហើយជាឱកាសមួយឱ្យស្ត្រីខ្មែរស្វែងរកជំនួយពីអាជ្ញាធរមានសមត្ថកិច្ចនោះ។ ប៉ុន្តែមានការិយាល័យចុះសំបុត្រអាពាហ៍ពិពាហ៍មួយចំនួនតូចតែប៉ុណ្ណោះមានអ្នកបកប្រែភាសាខ្មែរ។ ក្នុងករណីមានអ្នកបកប្រែក៏អ្នកទាំងនោះតែងតែជាមនុស្សទទួលប្រាក់ពីមេខ្យល់។ ទិដ្ឋភាពបែបនេះបានគម្រាមកំហែងដល់តម្លាភាពក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍នោះរួចស្រេចទៅហើយ។

បុរសចិនទាំងនោះចំណាយប្រាក់ជាច្រើនដល់សេវារបស់មេខ្យល់មានចាប់ពី១០០០០$ ដល់២០០០០$។ ដូច្នេះគេបារម្ភពីការបាត់បង់ប្រពន្ធណាស់។ ក្នុងរយៈពេលពីរឬបីខែដំបូងបន្ទាប់ពីពេលរៀបការរួច ប្តី ឬក្រុមគ្រួសារខាងប្តីតែងតែតាមឃ្លាំមើលប្រពន្ធគ្រប់ជំហាន។ គេដកហូតយកលិខិតឆ្លងដែនទុក គេតាមដានរាល់សកម្មភាព និងឱ្យប្រាក់ចាយតែបន្តិចបន្តួចតែ

ប៉ុណ្ណោះ។ សកម្មភាពទាំងនោះនឹងធូរស្រាលវិញនៅពេលណានារីជាប្រពន្ធនោះរស់នៅកាន់តែយូរនិង/ឬមានផ្ទៃពោះ។ ទោះបីជាយ៉ាងណាក្តីក៏នាងមិនអាចទៅធ្វើអ្វីក្រៅពីការងារផ្ទះសម្បែង ឬក៏គេត្រឹមតែឱ្យជួយធ្វើការក្នុងអាជីវកម្មរបស់គ្រួសារប្តីតែប៉ុណ្ណោះ។ គ្មាននរណាម្នាក់បានផ្ញើប្រាក់មកស្រុកកំណើតដើម្បីជួយក្រុមគ្រួសារនៅក្នុងបន្ទុកឡើយ។

ស្ត្រីមួយចំនួនព្យាយាមរត់គេចជាច្រើនលើកច្រើនសារ។ មជ្ឈដ្ឋានអំណោយផលសម្រាប់រៀបចំផែនការរត់គេចនោះគឺបណ្តាញស្ត្រីខ្មែរឯទៀតនៅក្នុងប្រទេសចិន ដូចជាការជួបជុំគ្នានៅទីផ្សារនាចុងសប្តាហ៍ ឬតាមរយៈទូរស័ព្ទដៃ។ ទូរស័ព្ទចល័តដើរតួយ៉ាងសំខាន់នៅក្នុងការជួយឱ្យស្ត្រីរត់គេចបានជោគជ័យ រួមទាំង អនុញ្ញាតឱ្យគេអាចទាក់ទងទៅកាន់គ្រួសារនៅស្រុកកំណើត ឬប្រាប់ពីទីកន្លែងដែលខ្លួនកំពុងស្ថិតនៅជាដើម។ លិខិតឆ្លងដែន និងប្រាក់ជាវត្ថុសំខាន់បំផុតដើម្បីជួយឱ្យគេរត់រួច។ គេអាចប្រើប្រាស់វាដើម្បីទិញសំបុត្ររថភ្លើង ចូលស្នាក់នៅសណ្ឋាគារក្នុងការធ្វើដំណើរដ៏វែងឆ្ងាយរបស់ខ្លួនទៅកាន់ស្ថានកុងស៊ុល ឬស្ថានទូត។

អ្នកនៅក្នុងសហគមន៍មិនសូវជួយជាជុំកំភួនទេដោយមូលហេតុថាគេអាចមានទំនាក់ទំនងជាមួយក្រុមគ្រួសារប្តី។ ផ្ទុយទៅវិញពួកគេតែងតែប្រាប់ប្តីពីសកម្មភាពសង្ស័យមួយចំនួនទាក់ទងនឹងការរត់គេចណាមួយដែលអាចកើតមានឡើង។ ទោះបីជាដូច្នោះក្តីក៏ស្ត្រីខ្មែរមួយចំនួនទទួលបានការជួយប្រកបដោយភាពកក់ក្តៅពីបុគ្គលមួយចំនួន និងក្រុមអ្នកស្ម័គ្រចិត្តក្នុងប្រទេសចិននៅគ្រប់ដំណាក់កាលនៃការរត់គេច ជាពិសេសនៅខណៈពេលដែលរង់ចាំធ្វើមាតុភូមិនិវត្តមកកាន់មាតុប្រទេសវិញ។ ជំនួយរបស់គេមានដូចជាការផ្តល់ម្ហូបអាហារ ទីកន្លែងសម្រាប់ស្នាក់នៅ ក៏ដូចជាការផ្តល់សេវាសុខភាព ការផ្តល់ប្រឹក្សា និងការផ្តល់ជំនួយផ្នែកច្បាប់ក្នុងករណីដែលត្រូវការ។

បទពិសោធន៍ជាមួយនគរបាលមានភាពខុសៗគ្នាអាស្រ័យថាតើការជួបនគរបាលនោះស្ថិតនៅកន្លែងណា។ អ្នកតបសំណួរមួយចំនួនតូច សម្រេចចិត្តដើរចូលទៅកាន់មន្ត្រីអនុវត្តច្បាប់ តែមួយចំនួនទៀតជួបនគរបាលដោយចៃដន្យនៅឯចំណតរថយន្តក្រុង និងស្ថានីយ៍រថភ្លើង។ ក្នុងករណីជួបនៅសហគមន៍ដែលខ្លួនរស់នៅ នគរបាលតែងតែចាត់ទុករឿងរបស់គេជាបញ្ហាក្នុងគ្រួសារហើយគេបញ្ជូននារីនោះត្រឡប់ទៅផ្ទះរបស់ប្តីវិញ។ ប៉ុន្តែបើនាងជួបនគរបាលនៅទីកន្លែងឆ្ងាយ ដូចជានៅខេត្តមួយផ្សេងទៀត ឬនៅទីក្រុងធំណាមួយនគរបាលដោះស្រាយ

រឿងរបស់នាងដោយមានមន្ត្រីកុងស៊ុល ឬមន្ត្រីទូតចូលរួមផងដែរ ហើយជាពេលដែលនាងអាចទទួលបានជំនួយ។

បទពិសោធន៍ជាមួយមន្ត្រីកុងស៊ុល និងមន្ត្រីទូត មានល្អមានអាក្រក់។ មានមួយចំនួនពេញចិត្តចំពោះសេវាដែលបានផ្តល់ឱ្យ ឧទាហរណ៍ទីកន្លែងសម្រាប់ស្នាក់នៅ ម្ហូបអាហារ ឱកាសទូរស័ព្ទទាក់ទងមកគ្រួសារនៅស្រុកកំណើត និងការជួយរៀបចំឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ រួមមានការចេញលិខិតឆ្លងដែនជាថ្មីម្តងទៀត លិខិតបើកផ្លូវ និងឯកសារចាំបាច់មួយចំនួនទៀត។ ផ្ទុយទៅវិញស្ត្រីមួយចំនួនទទួលបានបទពិសោធន៍ផ្សេងទៅវិញដូចជាការយឺតយ៉ាវ និងការិយាធិប្បតេយ្យហួសហេតុ។ អ្នកតបសំណួរខ្លះត្រូវគេបញ្ជូនបន្តពីកន្លែងមួយទៅកន្លែងមួយទៀតរវាងស្ថានកុងស៊ុល និងស្ថានទូត ដោយមូលហេតុស្ថិតនៅក្រៅយុត្តាធិការរបស់ខ្លួន ដោយបានធ្វើឱ្យរយៈពេលនៃការធ្វើដំណើរកាន់តែយូរ ចាយប្រាក់កាន់តែច្រើន និងហានិភ័យកាន់តែខ្ពស់។ ស្ត្រីមួយចំនួនតូចបានរៀបរាប់អំពីការប្រមាថនិងការបំពារបំពានដែលបានកើតឡើង។

អ្នកតបសំណួរទទួលបានជំនួយផ្សេងៗគ្នាតាមរយៈទីភ្នាក់ងាររដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិក្នុងពេលវិលត្រឡប់មកដល់កម្ពុជាវិញទាំងរយៈពេលខ្លី (កន្លែងសម្រាប់ស្នាក់នៅ សោហ៊ុយសម្រាប់ធ្វើដំណើរ និងប្រាក់កាស) និងទាំងរយៈពេលវែង (ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការជួយស្វែងរកការងារឱ្យធ្វើ)។ មានកត្តាមួយចំនួនបានធ្វើឱ្យសមាហរណកម្មរបស់ពួកគេមិនទទួលបានជោគជ័យទាំងស្រុងទេ។ កត្តាទាំងនោះ ជួនកាល រួមមានការជាប់បំណុលគេសម្រាប់យកមកឱ្យថ្លៃសំបុត្រយន្តហោះពេលត្រឡប់មកពីប្រទេសចិន បន្ទុកចំណាយសម្រាប់គ្រួសារគឺនៅពេលដែលស្ត្រីមានផ្ទៃពោះមកពីប្រទេសចិនសម្រាលកូន ក៏ដូចជាការបាក់បែកគ្រួសារ និងស្លាកស្នាមមិនល្អដែលបណ្តាលមកពីបទពិសោធន៍ ពេល ស្នាក់នៅបរទេស។

អ្នកតបសំណួរមួយចំនួនតូចបានដាក់ពាក្យប្តឹងមេខ្យល់ក្នុងប្រទេសកម្ពុជា។ មួយចំនួនទៀតមិនបានដាក់ពាក្យប្តឹងទេ ដោយសារខ្លាចមានការសងសឹកពីសំណាក់មេខ្យល់ព្រោះថាមេ

ខ្យល់នោះក៏រស់នៅក្នុងភូមិនោះដែរ។ អ្នកខ្លះទៀតចង់បំភ្លេចចោលដោយមិនមានបំណងគាស់កកាយដំបៅចាស់នោះឱ្យរើឡើងវិញឡើយនៅក្នុងនីតិវិធីតុលាការ។

ដោយផ្អែកលើការវិភាគ និងការរកឃើញ ជាបន្តទៅនេះជាអនុសាសន៍ សម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្តកម្មវិធីសម្រាប់ធ្វើការពិចារណាផ្តោតសំខាន់លើការបង្ការ ការកំណត់អត្តសញ្ញាណ និងកិច្ចគាំពារបឋម ដោយរាប់បញ្ចូលទាំងការធ្វើមាតុភូមិនិវត្តន៍ផង ។[55]

## សម្រាប់ប្រទេសទាំងពីរដោយរួមបញ្ចូលទាំងកិច្ចសហប្រតិបត្តិការទ្វេភាគី៖

- **សម្រួលការធ្វើចំណាកស្រុកដើម្បីរៀបអាពាហ៍ពិពាហ៍រវាងកម្ពុជា-ចិនឱ្យស្របច្បាប់ និងមានការពិនិត្យតាមដានដោយបង្កើតឱ្យមានបទដ្ឋាន និងការអនុវត្តច្បាស់លាស់។**

កត្តាអូសទាញ និងរុញច្រានជាពិសេសវិសមភាពភេទក្នុងប្រទេសចិននឹងជម្រុញឱ្យមានការនាំស្ត្រីខ្មែរទៅរៀបការនៅប្រទេសចិនបន្តទៀតនាពេលអនាគត។ ភស្តុតាងបានបញ្ជាក់ថាស្ត្រីខ្មែរដែលបានរៀបការជាមួយបុរសចិនរស់នៅប្រកបដោយក្តីសុខសាន្តក្នុងជីវិតគ្រួសារគេ។ ប៉ុន្តែ របាយការណ៍នេះ ផ្តោតភាគច្រើនលើចំណុចអវិជ្ជនៃស្ត្រីដែលគេនាំទៅរៀបការនៅប្រទេសចិនតាមរយៈទីភ្នាក់ងារទុច្ចរិត មិនស្របច្បាប់ មិនមានតម្លាភាព និងគ្មានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវនោះផងដែរ។ គោលនយោបាយថ្មីៗចុងក្រោយនៅក្នុងប្រទេសកម្ពុជាដែលតម្រូវឱ្យមានការកក់ប្រាក់ជាច្រើនចំពោះស្ត្រីទៅទេសចរណ៍នៅប្រទេសចិនម្នាក់ឯង និងហាមឃាត់មិនឱ្យចេញលិខិតបញ្ជាក់ភាពនៅលីវអាចជួយបន្តិចបន្តួចតែប៉ុណ្ណោះក្នុងការបង្ការបាតុភាពដែលបង្កឡើងដោយការរៀបការដោយបង្ខំ ហើយទង្វើនេះអាចមានការរើសអើងចំពោះយេនឌ័រ។ ផ្ទុយទៅវិញប្រទេសទាំងពីរគួរតែបង្កើតឱកាសធ្វើចំណាកស្រុកដើម្បីរៀបអាពាហ៍ពិពាហ៍ឱ្យស្របច្បាប់ ដោយយកគំរូបទពិសោធន៍ល្អៗពីកន្លែងដទៃទៀ

- **ធានាថាមន្ត្រីជួរមុខរបស់ចិន និងមន្ត្រីកម្ពុជានៅក្នុងប្រទេសចិនទទួលបានការយល់ដឹង**

---

55 ការវិភាគពិស្តារមួយស្តីពីតម្រូវកាក្នុងការធ្វើសមាហរណកម្មក្នុងប្រទេសកម្ពុជាអាចរកបាននូវអត្ថបទបោះពុម្ពស្រាវជ្រាវដោយRebecca Surtees, *បន្ទាប់ពីការជួញដូរ៖ បទពិសោធន៍ និងឧបសគ្គក្នុងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងមហាអនុតំបន់មេគង្គ* (UNIAP/Nexus Institute 2013).

គ្រប់គ្រាន់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ ក៏ដូចជាការចេះប្រើប្រាស់ឧបករណ៍សម្រាប់កំណត់អត្តសញ្ញាណ និងឆ្លើយតបស្ថានភាពទាំងនោះ។

ដោយបែបផែនជាក់លាក់នៃការរៀបការដោយបង្ខំក្នុងប្រទេសចិនចេះតែកើនឡើងពាក់ព័ន្ធនឹងការនាំយកស្ត្រីបរទេសទៅរៀបការ មន្ត្រីជួរមុខ និងបេសកកម្មការទូតពាក់ព័ន្ធចាំបាច់ត្រូវយល់ដឹងអំពីបាតុភូត និងមានឧបករណ៍សម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ។ ការសិក្សាស្រាវជ្រាវនេះបង្ហាញថាមន្ត្រីនគរបាល ជាពិសេសនៅថ្នាក់មូលដ្ឋានពុំទាន់យល់ដឹងក្នុងការអនុវត្តការងារនេះឱ្យបានប្រសើរទេ។ ការយល់ច្រលំមួយទាក់ទងនឹងលិខិតបញ្ជាក់អា ពាហ៍ពិពាហ៍ ដែលក្នុងនោះមន្ត្រីអនុវត្តច្បាប់តែងតែច្រាលចោលករណីរបស់ស្ត្រី ដោយសំអាងលើឯកសារចុះបញ្ជីអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយមិនបានពិចារណាអំពីភាពអាចជាជនរងគ្រោះនៃការជួញដូរមនុស្ស។ មន្ត្រីស្ថានកុងស៊ុល និងមន្ត្រីស្ថានទូតកម្ពុជាជួនកាលរកមិនឃើញសូចនាករអំពីការរៀបការដោយបង្ខំ ហើយជាលទ្ធផលគាត់មិនបានជួយស្ត្រីខ្មែរដែលកំពុងត្រូវការជំនួយឡើយ។ ការស្វែងរក និងកំណត់ស្ថាប័នសម្រាប់បណ្ដុះបណ្ដាល និងអភិវឌ្ឍន៍ឧបករណ៍ដើម្បីកំណត់អត្តសញ្ញាណគួរត្រូវតែធ្វើដើម្បីជម្នះឱ្យបាននូវរាល់ចំណុចខ្វះខាត ដែលកើតមាននាពេលកន្លងមក។ ប្រទេសទាំងពីរគួរតែបង្កើតវិធីសាស្ត្ររួមក្នុងការកំណត់អត្តសញ្ញាណជនងរគ្រោះ ឬទទួលស្គាល់លទ្ធផលទៅវិញទៅមក ដោយអនុញ្ញាតឱ្យមាននីតិវិធីក្នុងការធ្វើមាតុភូមិនិវត្ត និងមានការថែទាំបណ្ដោះអាសន្នសមរម្យ ចាប់ផ្ដើមបានឆាប់រហ័ស។

- **បន្ថែមសេវាដោយមិនមានការបង់ប្រាក់ រាប់បញ្ចូលទាំងការធ្វើដំណើរ និងការស្នាក់នៅឱ្យដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។**

បំណុលដែលកើតឡើងក្នុងអំឡុងពេលនៅប្រទេសចិន និងការត្រឡប់ទៅមាតុប្រទេសវិញធ្វើឱ្យប៉ះពាល់ដល់ជោគជ័យនៃការធ្វើសមាហរណកម្ម និងរឹតតែបង្កើនឱ្យមានភាពងាយរងគ្រោះដោយការជួញដូរសារជាថ្មីថែមទៀតផង។ សេវាឧបត្ថម្ភគាំទ្រគួរតែផ្ដល់ដោយឥតគិតថ្លៃដល់ជនរងគ្រោះដោយការរៀបការដោយបង្ខំ និងជនរងគ្រោះរាល់ទម្រង់ នៃការកេងប្រវ័ញ្ចដោយទទួលស្គាល់ការឈឺចាប់របស់គេ និងទទួលស្គាល់សិទ្ធិជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ទោះបីនេះជាទំនួលខុសត្រូវដំបូងរបស់រដ្ឋពាក់ព័ន្ធក៏ដោយ មានថវិកានិងសេវាផ្សេ

ងៗដែលអង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិមានសម្រាប់ជួយជនរងគ្រោះ។ កិច្ចសម្រប សម្រួល កិច្ចសហប្រតិបត្តិការ និងការបញ្ជូនប្រកបដោយប្រសិទ្ធភាពជាគន្លឹះនៅក្នុងបរិបទ នេះ។

## សម្រាប់អ្នកធ្វើការងារពាក់ព័ន្ធនៅប្រទេសកម្ពុជា៖

- **បញ្ជ្រាបសារខាងក្រោមនេះក្នុងការធ្វើអន្តាគមន៍ក្នុងការផ្លាស់ប្តូរឥរិយាបទដល់ស្ត្រីខ្មែរ ដែលមានបំណងធ្វើចំណាកស្រុកទៅរៀបការនៅប្រទេសចិន។**

ក. បុរសចិនដែលឱ្យមេខ្យល់រកប្រពន្ធពីប្រទេសកម្ពុជាមិនមែនជាអ្នកមាន ហើយរស់ នៅទីក្រុងទេ ដូច្នេះក្តីសង្ឃឹមថាបានប្រាក់ផ្ញើមកគ្រួសារនៅស្រុកកំណើតហាក់បីដូច ជាមានតិចតួចណាស់។

ខ.ការរៀបការជាមួយជនជាតិចិនមិនមែនជាឱកាសសម្រាប់ទទួលបានការងារធ្វើឡើយ ប្រសិនបើមិនបានរស់នៅស្របច្បាប់យ៉ាងហោចណាស់៥ ឆ្នាំនោះទេ។ ចំណែកការ រៀបការជាមួយចិនជាមធ្យោបាយទទួលបានការងារស្របច្បាប់ជាព័ត៌មានមិនពិត។

គ. ស្ត្រីខ្មែរដែលធ្វើចំណាកស្រុកទៅកាន់ប្រទេសចិនតាមរយៈទិដ្ឋាការទេសចរណ៍មាន សុពលភាពត្រឹមតែ៣០ថ្ងៃតែប៉ុណ្ណោះ។ ឱកាសពន្យារពេលស្នាក់នៅបន្តមាន លក្ខណៈចង្អៀត ហើយមានតម្លៃខ្ពស់។ ការស្នាក់នៅហួសសុពលភាពនៃទិដ្ឋាការ ប្រឈមនឹងការចាប់និរទេសចេញពីប្រទេសចិន។

ឃ.សេវាធ្វើចំណាកស្រុកក្នុងគោលបំណងរៀបការមិនមែនធ្វើឡើងដោយឥតគិតថ្លៃទេ ក្នុងករណីស្ត្រីណាម្នាក់បដិសេធន៍មិនរៀបការពេលដែលមកដល់ប្រទេសចិននោះ គេឱ្យសងប្រាក់ចំណាយ និងប្រាក់ដែលគេបើកឱ្យមុនវិញទាំងអស់។

ង. លិខិតឆ្លងដែនជាឯកសារសំខាន់សម្រាប់ធ្វើដំណើរ និងស្នាក់នៅ ដូច្នេះអ្នកធ្វើចំ ណាកស្រុកទាំងអស់គ្នាគួរតែរក្សាលិខិតឆ្លងដែន ច្បាប់ចម្លង ឬរូបថតនៃលិខិតឆ្លងដែន នោះគ្រប់ពេលវេលាដោយខ្លួនឯង និងត្រូវចងចាំលេខលិខិតឆ្លងដែននោះផងដែរ។

ច. ក្នុងករណីធ្វើដំណើរ ឬស្នាក់នៅដោយមិនមានលិខិតឆ្លងដែនជាការចាំបាច់ ចូរសុំពលរដ្ឋចិន ឬក្រុមអ្នកស្ម័គ្រចិត្តឱ្យជួយទិញសំបុត្ររថភ្លើង ឬជួលបន្ទប់ឱ្យស្នាក់នៅ។

ឆ. បណ្តាញស្ត្រីខ្មែរក្នុងប្រទេសចិនអាចជួយបានក្នុងករណីចាំបាច់។ បណ្តាញនេះមាននៅកន្លែងដែលស្ត្រីខ្មែររស់នៅច្រើន ក្រៅពីនេះក៏អាចទាក់ទងគ្នាតាមរយៈទូរស័ព្ទ និងអ៊ិនធឺណិតផងដែរ។

ជ. ស្ត្រីអាចរកជំនួយបាននៅទីភ្នាក់ងារដទៃទៀតក្នុងប្រទេសចិន ដូចជាក្រុមអ្នកស្ម័គ្រចិត្ត និងអង្គការសង្គមស៊ីវិល ក៏ដូចជាស្ថានកុងស៊ុល និងស្ថានទូតកម្ពុជា។

ឈ. ពេលព្យាយាមរត់ពីជីវិតរៀបការដោយបង្ខំនោះ ស្ត្រីគួរគប្បីស្វែងរកជំនួយពីនគរបាលខេត្ត ឬក្រុងផ្សេង ប្រសើរជាងរកនគរបាលក្នុងមូលដ្ឋានដែលខ្លួនរស់នៅឱ្យជួយ។

- **ការចូលរួមពីសំណាក់ក្រុមគ្រួសារ និងសហគមន៍ក្នុងប្រទេសកម្ពុជា ទើបធ្វើឱ្យការបង្ការទប់ស្កាត់ និងការធ្វើសមាហរណកម្មមានប្រសិទ្ធភាព។**

ការសិក្សាស្រាវជ្រាវនេះបង្ហាញថាគ្រួសារ និងសហគមន៍ក្នុងប្រទេសកម្ពុជាជាតួអង្គសំខាន់មួយក្នុងការសម្រេចចិត្តធ្វើចំណាកស្រុកដើម្បីរៀបការ និងមានឥទ្ធិពលលើភាពងាយរងគ្រោះដោយការកេងប្រវ័ញ្ច ក្នុងនោះគឺការរៀបការដោយបង្ខំ។ បន្ទាប់មកគឺមេខ្យល់ ជាធម្មតាតែងតែពាក់ព័ន្ធនៅថ្នាក់សហគមន៍ក្នុងការធ្វើចំណាកស្រុកដើម្បីរៀបការ ហើយចុងក្រោយគឺពលរដ្ឋដើរតួសំខាន់ណាស់ក្នុងការតាមដានរាល់ការធ្វើចំណាកស្រុក និងរាយការណ៍រាល់សកម្មភាពបោកបញ្ឆោតនានា។ គ្រួសារ និងសហគមន៍ជាអ្នកជាតួអង្គសំខាន់ក្នុងការព្យាបាលរបួសផ្លូវចិត្តនិងភាពជោគជ័យនៃការធ្វើសមាហរណកម្ម បន្ទាប់ពីវិលត្រឡប់មកផ្ទះវិញ។ ដូច្នេះវាជាការចាំបាច់ក្នុងការឱ្យគ្រួសារ និងសហគមន៍ចូលរួមឱ្យបានទូលំទូលាយក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើសមាហរណកម្មជនរងគ្រោះវិញ។

- **ពន្យល់ និងបញ្ជាក់ឱ្យច្បាស់ពីដែនសមត្ថកិច្ចរវាងស្ថានកុងស៊ុល និងស្ថានទូតកម្ពុជាស្តីពីការផ្តល់សេវា និងការឧបត្ថម្ភគាំទ្រដល់ពលរដ្ឋខ្មែរ ក្នុងប្រទេសចិន និងបង្កើនការត្រួតពិនិត្យ និងគណនេយ្យភាពនៃការបំពេញភារកិច្ចរបស់ខ្លួន ។**

ស្ត្រីដែលបានរត់គេចពីការរៀបការដោយបង្ខំត្រូវការជំនួយឧបត្ថម្ភគាំទ្រពីស្ថានកុងស៊ុល និងស្ថានទូត។ ការបដិសេធន៍ការផ្តល់សេវាណាមួយដោយហេតុផលមិននៅក្រោមដែនសមត្ថកិច្ចខ្លួននោះវាមិនសមហេតុផលឡើយ ហើយវាកាន់តែធ្វើឱ្យស្ត្រីនោះកាន់តែធ្លាក់ចូលភាពងាយរងគ្រោះកាន់តែខ្លាំងឡើង មានដូចជាដោយការកេងប្រវ័ញ្ច ការចាប់និរទេស និងចំណាយប្រាក់កាន់តែច្រើនលើការផ្តល់ជំនួយ។ នីតិវិធីទាំងឡាយគួរតែអនុវត្តអនុឡោមតាមទំនួលខុសត្រូវច្បាស់លាស់ក្នុងការជួយឧបត្ថម្ភគាំទ្រដោយធានាសុវត្ថិភាព ភាពទាន់ពេលវេលា និងមិនមានការបង់ប្រាក់ចំពោះការបញ្ជូនទៅកាន់កន្លែងផ្តល់សេវាក្នុងករណីចាំបាច់។ ដូច្នេះគួរតែមានយន្តការមួយ ដើម្បីឱ្យការបំពេញភារកិច្ចរបស់មន្ត្រីស្ថានកុងស៊ុល និងមន្ត្រីស្ថានទូតកាន់តែមានការទទួលខុសត្រូវខ្ពស់ រួមមានយន្តការសម្រាប់ដាក់ពាក្យបណ្តឹងពីអ្នកទទួលសេវាទាំងនោះ និង វិធានការដាក់វិន័យ ដល់មន្ត្រីណាដែលគេរកឃើញថាបានរំលោភបទដ្ឋាន អាកប្បកិរិយាក្នុងវិជ្ជាជីវៈ។

- **ធ្វើកំណែទម្រង់ក្នុងការផ្តល់លិខិតបញ្ជាក់ភាពនៅលីវសម្រាប់ស្ត្រីខ្មែរនៅប្រទេសចិន**

ការចេញលិខិតបញ្ជាក់ភាពនៅលីវតាមរយៈស្ថានកុងស៊ុល និងស្ថានទូតកម្ពុជាត្រូវបានផ្អាកនាពេលថ្មីៗនេះ ទោះបីពុំមាននរណាម្នាក់ដឹងច្បាស់ថាការអនុវត្តគោលនយោបាយនេះនឹងបន្តរហូតដល់ពេលណាក្តី។ ក្នុងបរិបទបច្ចុប្បន្ននេះ យើងមានអនុសាសន៍មួយចំនួន៖ ១) ផ្តល់លិខិតបញ្ជាក់ភាពនៅលីវឡើងវិញដោយមារការកែទម្រង់លើដំណាក់កាលនៃការចេញលិខិតបញ្ជាក់នេះ ដោយរួមទាំងកិច្ចសម្ភាសន៍ស្ត្រីខ្មែរដែលដាក់ពាក្យស្នើសុំដើម្បីបញ្ជាក់ពីការយល់ព្រមដោយមិនមានការបង្ខិតបង្ខំក្នុងការសម្រេចចិត្តរៀបការនោះ។ ២)លិខិតបញ្ជាក់ភាពនៅលីវគួរតែបង្ហាញពីមូលហេតុនៃការស្នើសុំ។ ការធ្វើបែបនេះអាចឱ្យបុគ្គលដាក់ពាក្យស្នើសុំនោះដឹងខ្លួនឯងថាលិខិតបញ្ជាក់នេះយកទៅប្រើប្រាស់ក្នុងគោលបំណងជាក់លាក់មួយ។ វៀតណាមបានអនុវត្តបែបនេះ ដូច្នេះគួរតែយកបទពិសោធន៍ល្អនេះមកអនុវត្តដែរ។

## សម្រាប់អ្នកធ្វើការងារពាក់ព័ន្ធនៅប្រទេសចិន៖

- ពង្រឹងនីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយជនបរទេស ដោយពិនិត្យឱ្យបានជិតដល់លើ"ការយល់ព្រមរៀបការ"

ការទាមទារឱ្យជនបរទេសបញ្ជាក់ពីការយល់ព្រមរៀបការដោយពុំមានការបង្ខិតបង្ខំចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសចិន នេះគឺជាការផ្តល់ឱកាសមួយដល់បុគ្គលម្នាក់ទទួលបានជំនួយក្នុងករណីចាំបាច់។ ប៉ុន្តែ ដើម្បីឱ្យស្ត្រីខ្មែរបង្ហាញពីឆន្ទៈពិតរបស់ខ្លួន មន្ត្រីត្រូវតែមានជំនាញស្តីពីការប៉ាន់ប្រមាណ "ការយល់ព្រម" ដោយគ្មានការបង្ខិតបង្ខំ ហើយនីតិវិធីនេះទាមទារឱ្យមានអ្នកបកប្រែភាសាគ្រប់គ្រាន់ និងដោយឯករាជ្យ ក៏ដូចជាការចូលរួមពីសំណាក់អ្នកធ្វើការងារពាក់ព័ន្ធ ប្តី និងមេខ្យល់ផងដែរ។

- ការគាំទ្រដល់ស្ត្រីខ្មែរជាប្រពន្ធដែលមានប្តីជាជនជាតិចិន ក្នុងការធ្វើសមាហរណកម្មក្នុងសង្គមចិន

ស្ត្រីខ្មែរដែលមកដល់ប្រទេសចិនជាលើកដំបូងរមែងជួបប្រទះបញ្ហាមួយចំនួនមានដូចជាភាសា មិនទាន់ស្គាល់ទំនៀមទម្លាប់ និងបែបផែនរស់នៅជាច្រើនទៀត។ ភាគីពាក់ព័ន្ធទាំងអស់ត្រូវធ្វើឱ្យសមាហរណកម្មនេះដំណើរការទៅដោយរលូន។ ដើម្បីសម្រេចបានវាទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមជាអាទិ៍វិស័យសាធារណៈនិងសង្គមស៊ីវិល រួមទាំង ថ្នាក់បង្រៀនភាសា និងវប្បធម៌ ការជួយបង្កើតបណ្តាញក្នុងចំណោមស្ត្រីខ្មែរដែលរស់នៅតាមមូលដ្ឋាន ឱកាសចូលរួមជាមួយពលរដ្ឋចិន ឬណែនាំឱ្យដឹងពីសេវានានារបស់រដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាល។

- ជួយឱ្យស្ត្រីខ្មែរជាប្រពន្ធរកបានការងារធ្វើឆាប់រហ័ស និងអាចប្រើប្រាស់សេវាសាធារណៈសំខាន់ៗ

ស្ត្រីខ្មែរភាគច្រើនមកដល់ប្រទេសចិនក្នុងគោលបំណងរកប្រាក់ដើម្បីជួយគ្រួសាររបស់ខ្លួននៅឯស្រុកកំណើត។ ឱកាសមានការងារធ្វើឱ្យគេរីករាយនឹងសម្រេចចិត្តស្នាក់នៅក្នុងប្រទេសចិន អ្នកតបសំណួរមួយចំនួនក្នុងការសិក្សាស្រាវជ្រាវនេះបានប្រាប់ថាគេអាចរកការងារធ្វើបាននៅតាមរោងជាង ភោជនីយដ្ឋាន ឬតាមរោងចក្រ តែការងារទាំងនេះមិនជាប់លាប់ទេ។ ទិដ្ឋាការតាមរយៈការរៀបការមិនអាចឱ្យពួកគេរកការងារស្របច្បាប់នៅប្រទេសចិនបាន

ទេ គឺពួកគេត្រូវរស់នៅទីនោះស្របច្បាប់បានយ៉ាងហោចណាស់ ៥ ឆ្នាំសិនមុននឹងពួកគេអាចរកការងារស្របច្បាប់ធ្វើបាន ។ ដូច្នេះវាមិនអាចទាក់ទាញស្ត្រីខ្មែរឱ្យមកប្រទេសចិនដើម្បីជួយបំពេញភាពខ្វះខាតនៃចំនួនស្ត្រីក្នុងសង្គមនេះឡើយ។ សេវាសាធារណៈ និងការធានារ៉ាប់រងសំខាន់ៗដែលពាក់ព័ន្ធនឹងសុខភាពមាតាអាចទទួលបានដរាបណាស្ត្រីនោះរស់នៅក្នុងប្រទេសចិនជាច្រើនឆ្នាំសិន។ ការអនុវត្តបែបនេះធ្វើឱ្យសុខភាពមាតា និងទារកដែលកើតនៅប្រទេសចិនប្រឈមនឹងហានិភ័យដោយមិនសមហេតុផលឡើយ។

- **ផ្តល់សេវាគាំទ្ររបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ឱ្យដល់ជនរងគ្រោះដោយការជួញដូរជាជនបរទេស និងធានាឱ្យមានយន្តការបញ្ជូន គ្រប់គ្រាន់**

រដ្ឋាភិបាលចិនមានបណ្តាញទូលំទូលាយក្នុងការផ្តល់មជ្ឈមណ្ឌលស្នាក់នៅពាសពេញផ្ទៃប្រទេស ដោយផ្តល់ម្ហូបអាហារ កន្លែងស្នាក់នៅ និងសេវាដទៃទៀតដល់ពលរដ្ឋចិនដែលមានវិបត្តិ។ ប៉ុន្តែ ប្រព័ន្ធនេះពុំទាន់មានបទពិសោធន៍ជួយដល់ជនបរទេសដែលកំពុងត្រូវការជំនួយឡើយ។ ភស្តុតាងជាក់ស្តែងបង្ហាញថាស្ត្រីខ្មែររត់គេចពីជីវិតរៀបការដោយបង្ខំដែលមានផ្ទៃពោះ មិនមានលទ្ធភាពចូលស្នាក់នៅ និងទទួលសេវាពីមជ្ឈមណ្ឌលឡើយ។ ដោយសារកំណើននៃជនបរទេសរងគ្រោះដោយសារការរៀបការដោយបង្ខំ និងការកេងប្រវ័ញ្ចនានា ចាំបាច់គួរតែអនុញ្ញាតឱ្យជនបរទេសទាំងនោះទទួលបានសេវានេះផង។ អ្នកធ្វើការងារពាក់ព័ន្ធមិនមែនរដ្ឋាភិបាលគួរតែចូលរួមផ្តល់កិច្ចគាំទ្រដល់ជនរងគ្រោះ ហើយចាំបាច់ត្រូវមានយន្តការបញ្ជូន ដែលមានការចូលរួមពីតួអង្គរដ្ឋាភិបាលនិងសង្គមស៊ីវិល ដោយធ្វើការរួមគ្នាជាបណ្តាញដើម្បីផ្តល់ជំនួយជាកញ្ចប់ពេញលេញដល់ជនរងគ្រោះ។

UNDP partners with people at all levels of society to help build nations that can withstand crisis, and drive and sustain the kind of growth that improves the quality of life for everyone. On the ground in more than 170 countries and territories, we offer global perspective and local insight to help empower lives and build resilient nations.

UN-ACT
United Nations Action for Cooperation against Trafficking in Persons

UNDP
*Empowered lives. Resilient nations.*

UN-ACT Regional Management Office
1st Floor, United Nations Service Building
Rajdamnern Nok Avenue
Bangkok 10200

Tel: (66) 2 304 9100 ext. 2310

www.un-act.org
www.facebook.com/notrafficking
Twitter: UN_ACT

United Nations Development Programme
Bangkok Regional Hub
3rd Floor, United Nations Service Building
Rajdamnern Nok Avenue
Bangkok 10200

Tel: (66) 2 304 9100

www.asia-pacific.undp.org
www.facebook.com/undpasiapac
Twitter: UNDPasiapac